ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- សិទ្ធិមនុស្ស និងអនុសញ្ញាបង្ការនិងផ្ដន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
- អនុស្សាវរីយ៍ថ្ងៃ ២ធ្នូ ឆ្នាំ១៩៧៨
- ការពិតមិនអាចប្រកែកបានស្ដីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥២ ខែធ្នូ ឆ្នាំ២០២០

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥២ ខែធ្នូ ឆ្នាំ២០២០

## មាតិកា

**សំបុត្រ**

◆ សិទ្ធិមនុស្ស និងអនុសញ្ញាបង្ការនិង ..........១

**ផ្នែកឯកសារ**

◆ ឥន សាវ៉ុន ហៅ ជុន អនុប្រធានកងការពារ .. ៥

◆ ទូន ចាន់ដារ៉ា ហៅ ភាន់ យុទ្ធនារី .......... ១០

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ព្រះតេជគុណ សៀវ ស៊ីឈុន ............... ១៣

◆ ជុំ យ៉ាន់ ៖ គ្រូបង្រៀនកុមារ ..................១៦

◆ ហ៊ុយ យាន ៖ អតីតយុទ្ធនារីខ្មែរក្រហម .... ១៩

◆ សេង ហុក ៖ ខ្ញុំបានរស់ជីវិតពីសង្គ្រាមរ៉ាំរ៉ៃ . ២១

◆ ទៀន នី ៖ ដំណើរជីវិតមក ..................២៤

◆ អនុស្សាវរីយ៍ថ្ងៃ ២ធ្នូ ឆ្នាំ១៩៧៨ ......... ២៦

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ ........... ៣១

**ផ្នែកវេទិកាសាធារណៈ**

◆ ការពិតមិនអាចប្រកែកបាន ............... ៤៣

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

◆ ម៉ី មុន្នីរដ្ឋ ៖ សិស្ស ........................ ៤៧

◆ សោម សីលា និង ឡាំ សេណា ៖ និស្សិត .. ៥០

◆ ភិន រដ្ឋា ៖ និស្សិត ........................ ៥៣

◆ ស្ដាបនិកពីរង្គ (បទកាកគតិ) ............... ៥៥

◆ រឿងពិតរបស់ខ្ញុំ ជីវិតក្រោយថ្ងៃ ១៧ ....... ៥៧



សេក សាយ ស្ដាប់កូនស្រីដែលកំពុងអានចម្លើយសារភាពរបស់តា ដែលត្រូវបានខ្មែរក្រហមចាប់ខ្លួន និងសម្លាប់ៗ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ឆាំង យុ, ប៉ាង ពីរីន្ត, វេនី ខកហ្មៀល, គាត ស្រីឡែន, រី លក្ខិណា, មេក វិន, ហ៊ាន ពិសី, សួត វិចិត្រ, សុខ វណ្ណៈ, លី សុខឃាង, ជាតិ ប៉ុណ្ណារី

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ាវរដ្ឋ មេត្តា, **អ្នកបកប្រែ៖** ហួយ លីឃាង

**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** អ៊ុន សុជាវី

**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# សិទ្ធិមនុស្ស និងអនុសញ្ញាបង្ការនិងផ្តន្ទាទោស លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ឆាំង យុ



*ប្រជាជននៅសហករណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

កាលពី៧២ឆ្នាំមុន នាថ្ងៃទី៩ ខែធ្នូ អង្គមហាសន្និបាតនៃអង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញាបង្ការនិងផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ត្រូវបានស្គាល់ជាទូទៅថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍)។ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ គឺជាសន្ធិសញ្ញាដំបូងបង្អស់ ដែលទទួលស្គាល់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងជានិមិត្តរូបនៃសន្ធិសញ្ញាសិទ្ធិមនុស្សដំបូងបំផុតដែលត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិ។ ខណៈដែលយើងចងចាំថ្ងៃកំណើតនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដោយផ្តោតទៅលើអត្ថន័យនៃការបង្ការនិងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ យើងគួរតែពិចារណាថាតើអនុសញ្ញានេះមានអត្ថន័យយ៉ាងដូចម្តេច ចំពោះសិទ្ធិមនុស្ស និងថា តើយើងគួរខិតខំប្រឹងប្រែងបន្ថែមក្នុងកម្រិតប៉ុណ្ណាទៀតដើម្បីទទួលបានពិភពលោកមួយដែលគ្មានអំពើប្រល័យពូជសាសន៍។

អនុសញ្ញាបង្ការនិងផ្ដន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បកស្រាយអំពីវិធីដែលភាគីរដ្ឋអាចផ្ដន្ទាទោសលើអំពើប្រល័យពូជសាសន៍ ដោយការបង្កើតច្បាប់ដែលធានាឲ្យមានការកាត់ទោសឧក្រិដ្ឋជននៃអំពើនេះ។ ទោះជាយ៉ាងណាក៏ដោយ អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ មិនមានចែងច្បាស់អំពីវិធីសាស្ត្រជាក់លាក់ដែលភាគីរដ្ឋអាចធ្វើឡើង ដើម្បីបង្ការប្រល័យពូជសាសន៍នោះទេ។ ក្នុងហេតុផលច្រើនកាតព្វកិច្ចក្នុងការបង្ការអាចប្រឈមនឹងឧបសគ្គនានាលើការកំណត់ និងអនុវត្ត ក៏ប៉ុន្តែនេះមិនមែនមានន័យថា កាតព្វកិច្ចខាងលើមិនអាចប្រព្រឹត្តទៅបាននោះឡើយ ហើយផលពិបាកទាំងនេះមិនគួររារាំងយើងចេញពីការអនុវត្តវិធានានានាដែលអាចប្រព្រឹត្តទៅបានក្នុងការបង្ការអំពើប្រល័យពូជសាសន៍នោះដែរ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ប្ដេជ្ញាចំពោះគំនិតមួយដែលថា ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺជាការបង្ការអំពើប្រល័យពូជសាសន៍។ ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺមិនមែនមានន័យត្រឹមតែជាការសិក្សាអំពីហេតុផលប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍តែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការរួមបញ្ចូលនូវការស្វែងយល់អំពីបទពិសោធន៍របស់មនុស្សជុំវិញវត្តមាននៃអំពើប្រល័យពូជសាសន៍។ តើបទពិសោធន៍ ជំនឿ ឬគំនិតបែបណា ដែលអនុញ្ញាតឲ្យមនុស្សមានហេតុផលក្នុងការប្រព្រឹត្តអំពើហិង្សាទៅលើអ្នកដទៃ ជាទង្វើត្រឹមត្រូវ និងថា តើបទពិសោធន៍របស់បុគ្គលស្របគ្នាទៅនឹងកាលៈទេសៈ និងការយល់ឃើញរបស់សហគមន៍ប្រជាជាតិ និងអន្តរជាតិ ជុំវិញព្រឹត្តិការណ៍ដែលបង្កជំរុញ ឬបន្តឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើងដោយរបៀបណា?

មជ្ឈមណ្ឌលឯកសារកម្ពុជា មើលឃើញថាការអប់រំពីអំពើប្រល័យពូជសាសន៍ និងការអប់រំស្ដីពីសិទ្ធិមនុស្ស គឺជាសកម្មភាពតែមួយនិងដូចគ្នា។ ចេតនាក្នុងការសម្លាប់ឬបង្កគ្រោះថ្នាក់លើក្រុមមនុស្សណាមួយ គឺតែងតែផ្ដើមឡើងដោយការផ្ដល់ហេតុផលថា អំពើហិង្សាទៅលើអ្នកដទៃគឺជាទង្វើត្រឹមត្រូវ ហើយការផ្ដល់ហេតុផលបែបនេះ គឺរមែងផ្ដើមចេញដោយសកម្មភាពនានា ក្នុងបំណងលុបបំបាត់ភាពជាមនុស្សលើក្រុមមនុស្សណាមួយ។ តាមរយៈការសិក្សាដោយមិនលម្អៀងអំពីដំណើរការនៃការលុបបំបាត់ភាពជាមនុស្សនោះ ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺជាការសិក្សាផ្ទាល់ពីអំពើមនុស្សធម៌ និងអំពើអមនុស្សធម៌ ព្រមទាំងជាការសិក្សាដោយប្រយោលថា តើសិទ្ធិមនុស្សមានសារសំខាន់យ៉ាងដូចម្ដេច ក្នុងការបង្ការវត្តមាននៃឧក្រិដ្ឋកម្មដ៏ឃោរឃៅបំផុត។



សេក សាយ ជាកូនស្រីរបស់អ្នកទោសមន្ទីរស-២១ ឈ្មោះ សេក សាត ហៅ ប្រាក់ អតីតគណៈតំបន់២៥ និង ចាន់ គីមស្រ៊ុន ហៅ សាង។ សេក សាយ រស់នៅក្នុងខេត្តកំពង់ស្ពឺ និងកំពុងកាន់រូបថតម្ដាយ និងឪពុករបស់ខ្លួននៅឆ្នាំ២០១៩។ សេក សាយ គឺជាកូនស្រីតែម្នាក់គត់ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ ឪពុក ម្ដាយ និងប្អូនប្រុស ត្រូវខ្មែរក្រហមសម្លាប់ក្នុងឆ្នាំ១៩៧៨។ ប្អូនស្រីរបស់សេក សាយ ឈ្មោះ ច្រឹប បានស្លាប់ដោយសារជំងឺ នៅក្រោយពីរបបខ្មែរក្រហមដួលរលំបន្តិច។
ប្រភព៖ សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា។




សេក សាត ហៅ ប្រាក់ អតីតគណៈ តំបន់២៥ នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានឃាត់ខ្លួននិង ឃុំខ្លួននៅមន្ទីរស-២១។ រឿងរ៉ាវរបស់ សេក សាត បង្ហាញអំពីសាវតារដ៏ស្មុគស្មាញរបស់ជនរងគ្រោះជាច្រើនដទៃទៀតរបស់ខ្មែរក្រហម។ ក្នុងករណីជាច្រើន ជនរងគ្រោះគឺជាកម្មាភិបាលខ្មែរក្រហម។ ការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹង សេក សាត បង្ហាញថា គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ដែលចូលរួមក្នុងចលនាខ្មែរក្រហមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ ១៩៧០ ដើម្បីតស៊ូប្រឆាំងនឹងភាពអយុត្តិធម៌ក្នុងសង្គម។ នៅចុងបញ្ចប់គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៨។ ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា




ចាន់ គីមស្រ៊ុន ដំណើរស្វែងរកការពិតអស់ជាង៤០ឆ្នាំរបស់កូនស្រីម្នាក់តាមរយៈរូបថតដែលបន្សល់ពីរបបខ្មែរក្រហម។ នេះជារូបថត ចាន់ គីមស្រ៊ុន ហៅ សាង ដែលត្រូវបានចាប់ខ្លួននិងឃុំខ្លួនក្នុងមន្ទីរ ស-២១ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៨។ ប្ដីរបស់ គីមស្រ៊ុន ឈ្មោះ សេក សាត ក៏ត្រូវបានចាប់ខ្លួននិងជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ដែរ គឺនៅថ្ងៃ ទី២៨ ខែមិថុនា ឆ្នាំ១៩៧៨។ សេក សាយ ដែលកាលនោះមានអាយុ១១ឆ្នាំ គឺជាកូនស្រីច្បង ដែលបានឃើញហេតុការណ៍កងសន្តិសុខខ្មែរក្រហមមកនាំឪពុក ម្ដាយនិងប្អូនប្រុសអាយុប្រាំខែរបស់ខ្លួនចាកចេញទៅ។ គីមស្រ៊ុន ត្រូវបានសម្លាប់ ហើយកូនតូចរបស់គាត់ក៏ត្រូវបានសម្លាប់ជាមួយនឹងម្ដាយដែរ។ រូបថតមួយសន្លឹកនេះ មិនត្រឹមតែបានលងបន្លាច សេក សាយ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញអំពីអារម្មណ៍ឈឺចាប់ វិបត្តិផ្លូវចិត្ត ភាពសោកសង្រេង និងទារុណកម្មផ្លូវកាយដែលបន្តលើជនរងគ្រោះនៅមុនពេលត្រូវសម្លាប់។ រូបថត ចាន់ គីមស្រ៊ុន ត្រូវបានដាក់តាំងបង្ហាញនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

រឿងរ៉ាវរបស់បុគ្គល ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ការអំពើប្រល័យពូជសាសន៍ និងគាំទ្រសិទ្ធិមនុស្ស ពីព្រោះថា រឿងរ៉ាវទាំងនោះផ្ដល់ឱកាសឲ្យមនុស្សអាចយល់ដោយផ្ទាល់អំពីស្ថានភាពរបស់ជនរងគ្រោះ។ នេះប្រហែលជាគ្មានបរិក្ខារអប់រំណាមួយប្រសើរជាងនេះ ក្នុងការផ្ដល់ចំណេះដឹង ឬបង្ហាញពីលទ្ធផលនៃ

ការអប់រំពីអំពើប្រល័យពូជសាសន៍ឬការអប់រំស្តីពីសិទ្ធិមនុស្ស ដើម្បីបណ្តុះសេចក្តីមេត្តានោះឡើយ។ សេចក្តីមេត្តាបង្អាក់សកម្មភាពលុបបំបាត់ភាពជាមនុស្សតាមរយៈការផ្ទុះបញ្ឆេះផ្ទាល់ខ្លួនចំពោះមនុស្សជាតិជារួម។ នៅពេលដែលសិស្សានុសិស្សវ័យក្មេង ដាក់ខ្លួនទៅក្នុងគំនិតនិងបទពិសោធន៍របស់អ្នកដទៃទៀត អ្នកទាំងនោះមានឱកាសទទួលយកការយល់ដឹងថ្មី (ឬយ៉ាងហោចណាស់ទស្សនៈថ្មី) ថាតើអំពើប្រល័យពូជសាសន៍ ឬការបំពានសិទ្ធិមនុស្សអាចកើតឡើងយ៉ាងដូចម្តេច, ដោយមូលហេតុអ្វី និងផលវិបាកដ៏សោកសង្រេងនៃទង្វើទាំងនេះ។

ផលវិបាកដ៏សោកសង្រេងនៃអំពើប្រល័យពូជសាសន៍ឆ្លងគ្រប់ពេលវេលា ហើយឥទ្ធិពលនៃផលវិបាកនេះអាចប៉ះពាល់លើច្រើនជំនាន់ និងរាប់ទសវត្សរ៍។ ក្នុងពេលដែលខ្ញុំកំពុងសរសេរអត្ថបទនេះ ខ្ញុំបាននឹកឃើញទៅដល់រឿងរបស់ សេក សាយ។ អស់រយៈពេល ៤០ឆ្នាំជាង សេក សាយ បានព្យាយាមស្វែងរកការពិតជុំវិញការស្លាប់របស់ឪពុកម្តាយនិងបងប្អូនប្រុសរបស់គាត់ បន្តឡើងដោយរបបខ្មែរក្រហម ដែលនាំឲ្យប្រជាជនជាង ២លាននាក់បាត់បង់ជីវិត នៅរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ម្តាយរបស់គាត់គឺ ចាន់ គឹមស្រ៊ុន។ ឪពុករបស់គាត់គឺ សេក សាត ដែលត្រូវបានចាប់ខ្លួនដោយខ្មែរក្រហមនៅឆ្នាំ១៩៧៨ ប៉ុន្តែ សេក សាយ មិនបានដឹងពីស្ថានភាពជាក់ស្តែងជុំវិញការចាប់ខ្លួន និងការស្លាប់របស់ឪពុកម្តាយខ្លួនឡើយ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានស្រាវជ្រាវឃើញនិងប្រគល់ជូនគាត់នូវកំណត់ត្រាពាក់ព័ន្ធទៅនឹងគ្រួសាររបស់គាត់។ នៅក្នុងរូបថតនេះគឺ ចាន់ គឹមស្រ៊ុន ដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីរស-២១ដ៏អសោច។ ចាន់ គឹមស្រ៊ុន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៨។ សេក សាត ត្រូវបានចាប់ខ្លួនមួយខែបន្ទាប់មក។ សេក សាយ មានអាយុ ១១ឆ្នាំ នៅពេលដែលឪពុកម្តាយរបស់គាត់ត្រូវបានចាប់ខ្លួន។ នៅក្នុងរូបថតដដែលបង្ហាញថា ចាន់ គឹមស្រ៊ុន កំពុងពរប្អូនប្រុសរបស់ សេក សាយ ដែលមានអាយុ ៥ខែ នៅពេលដែលទារករូបនេះត្រូវបានសម្លាប់រួមជាមួយម្តាយរបស់ខ្លួន។ រូបថតមួយសន្លឹកនេះ មិនត្រឹមតែបានលងបន្លាច សេក សាយ តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញអំពីអារម្មណ៍ឈឺចាប់ វិបត្តិផ្លូវចិត្ត ភាពសោកសង្រេង និងទារុណកម្មផ្លូវកាយ ដែលបន្តលើជនរងគ្រោះនៅមុនពេលត្រូវបានសម្លាប់។

ទិវាគម្រប់ខួបនៃការអនុម័តអនុសញ្ញាបង្ការនិងផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនគួរត្រូវបានសាទរនោះទេ ពីព្រោះថា បរាជ័យរបស់ពិភពលោកក្នុងការគោរពកាតព្វកិច្ចរបស់អនុសញ្ញានេះ គឺមានច្រើនជាងជោគជ័យ ឬមានដំណើរទៅមុខបន្តិចបន្តួចប៉ុណ្ណោះ។ ផ្ទុយទៅវិញ យើងគួរតែប្រើប្រាស់ឱកាសដ៏សំខាន់នេះ ដើម្បីឆ្លុះបញ្ចាំងអ្វីដែលយើងអាចធ្វើបានឈានទៅបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់យើងឲ្យសម្រេចការប្តេជ្ញាដែលយើងមានចំពោះមនុស្សជាតិ។ ការប្តេជ្ញារបស់យើងចំពោះមនុស្សជាតិនៅក្នុងអនុសញ្ញាបង្ការ និងផ្តន្ទាលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនគួរចាប់ផ្តើមដោយការវិភាគទៅលើជោគជ័យ និងបរាជ័យនៅក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ ប៉ុន្តែយើងគួរតែចាប់ផ្តើមវិភាគទៅលើកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការបង្ការមិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជារៀងរហូត។ ការបង្ការអំពើប្រល័យពូជសាសន៍ គឺមិនត្រឹមតែជាការប្រកាន់ជំហរនយោបាយនោះទេវា គឺជាកាតព្វកិច្ចផ្លូវច្បាប់។ ស្មារតីសិទ្ធិមនុស្ស គឺបន្តជីវិតក្នុងកាតព្វកិច្ចនេះ ហើយស្មារតីនេះអាចបំពេញបានដោយការអប់រំ។ យោងទៅលើប្រវត្តិសាស្ត្រពិភពលោក និងព្រឹត្តិការណ៍ថ្មីៗ យើងគួរយកថ្ងៃនេះដើម្បីរំឭកថា តើយើងគួរខិតខំប្រឹងប្រែងបន្ថែមក្នុងកម្រិតប៉ុណ្ណាទៀត។

លោក ឆាំង យុ គឺជានាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការកោតសរសើរ និងពានរង្វាន់ជាច្រើនសម្រាប់កិច្ចការគាំពារដល់ការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា។

# ឥន សារ៉ុន ហៅ ថុន
# អនុប្រធានកងការពាររបស់តំបន់២៣

ដារ៉ាវឌ្ឍ រមត្ថា



*អតីតព្រះវិហារវត្តបឹងវែ ស្ថិតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដែលត្រូវបានខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងអ្នកទោស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ឥត សារ៉ុន ភេទប្រុស អាយុ២៧ឆ្នាំ។ ស្រុកកំណើតរបស់ខ្ញុំនៅភូមិចំបក់ពាម ឃុំស្វាយរៀង ស្រុកប្រសូត្រ តំបន់ ២៣។ នៅក្នុងឆ្នាំ១៩៦៣ ខ្ញុំរៀននៅថ្នាក់ទី៥ នៅវិទ្យាល័យកំពង់រោទិ៍ ខេត្តស្វាយរៀង។ នៅក្រោយពេលកើតមានរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀន។

នៅខែមិថុនា ឆ្នាំ១៩៧០ ឈ្មោះ សូ អតីលេខាតំបន់២៨ បានជួបខ្ញុំ ហើយដោយសារគាត់ឃើញខ្ញុំមានមាឌតូច ទើបគាត់ហៅខ្ញុំឲ្យចូលធ្វើជាកងការពារមន្ទីរស្រុក។ ខ្ញុំបានធ្វើជាកងការពាររយៈពេលបួនទៅប្រាំខែ មានទាហានវៀតកុង ឬវៀតណាមខាងត្បូងបានមកដេញចាប់ខ្ញុំនិងអ្នកផ្សេងទៀតរត់រប៉ាត់រប៉ាយអស់។ សូ បានឲ្យខោអាវមកខ្ញុំ ដើម្បីអូសទាញទឹកចិត្តខ្ញុំឲ្យចូលជាសមាជិក សេ.អ៊ី.អា។ នៅខែធ្នូ ខ្ញុំបានសម្រេចចិត្តចូលជា សេ.អ៊ី.អា ដែលមានឈ្មោះ យ៉ាន និង សំ អឿន ជាអតីតអ្នកតស៊ូសម្ងាត់ គឺជាអ្នកបញ្ចូលឈ្មោះខ្ញុំ និងឈ្មោះ សូ គឺជាអ្នកទទួលស្គាល់។

នៅខែកញ្ញា ឆ្នាំ១៩៧៥ តាមការណែនាំរបស់ សូ, ខ្ញុំ, សាភាន់, សុន គឺជាសមាជិកមន្ទីរតំបន់២៣, យ៉ុន, ម៉ក់ និង សាក់ បានធ្វើការពិភាក្សាគ្នាដោយបានចាត់តាំង ម៉ក់ ឲ្យលាក់ស្រូវចំនួន ២០០០ថាំង ដាក់ក្នុងជង្រុករបស់តំបន់ ២៣។ មិនតែប៉ុណ្ណោះយើងថែមទាំងបានឲ្យ ម៉ក់ យកសាំងចំនួន ២០ពុយ ទៅលាក់នៅក្នុងឃ្លាំងពាណិជ្ជកម្មរបស់តំបន់ ២៣។ យើងលាក់របរទាំងនោះ ក្នុងគោលបំណងត្រៀមធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧៦។ ក្រោយមក សូ បានដកខ្ញុំពីសមាជិកមន្ទីរតំបន់ឲ្យមកទទួលជាអនុប្រធានការពារមន្ទីរតំបន់ ២៣ ។ ពេលផ្លាស់ទៅទីនោះ ខ្ញុំកសាងកម្លាំងបានចំនួនបីនាក់មានឈ្មោះ សារិត គឺជាប្រធានក្រុមការពារមន្ទីរ, សាវ៉ន គឺជាសមាជិកក្រសួងពាណិជ្ជកម្ម និងឈ្មោះ ពត ហាន។ ខ្ញុំបានអប់រំអ្នកទាំងនោះដោយបានលើកឡើងអំពីបញ្ហាសតិអារម្មណ៍ និងការធ្វើបដិវត្តន៍ មានការលំបាកគ្រប់បែបយ៉ាង។ នៅក្នុងខែតុលា ឆ្នាំ១៩៧៥ សូ បានចាត់តាំងខ្ញុំឲ្យទៅទាក់ទងឈ្មោះ ធុំ ប្រធាននីរសារតំបន់២៣។ គោលបំណងគឺចង់ឲ្យ ធុំ ចាត់តាំងកម្លាំងយកស្រូវចំនួន ៥០០ថាំង ទៅលាក់នៅម្តុំបាក់រនាស់។ ក្រោយមក សូ បានណែនាំ ម៉ក់, ខ្ញុំ និង ធុំឲ្យស្គាល់ខ្សែរបស់គាត់ឈ្មោះ ផល។ ផល គឺជា ប្រធានសហករណ៍សង្ឃ័រ ក្នុងស្រុកប្រសូត្រ ខេត្តស្វាយរៀង។ យើងបានពិភាក្សាគ្នារើសយកសមាសភាពដែលធ្លាប់ប្រឆាំងជាមួយបដិវត្តន៍មកធ្វើជាកម្លាំង និងកសាងបានឈ្មោះ សុខ យ៉ាវ គឺជាមេក្រុម ក្នុងសហករណ៍សង្ឃ័រ។ នៅក្នុងខែវិច្ឆិកា សូ បានឲ្យខ្ញុំទាក់ទងជាមួយឈ្មោះ វណ្ណា គឺជាប្រធានសិល្បៈឃោសនាតំបន់២៣។

នៅដើមឆ្នាំ១៩៧៦ ខ្ញុំ, យ៉ុន គឺជាប្រធានឈ្លបឃុំសង្ឃ័រ, សាក់ គឺជាប្រធានមន្ទីរតំបន់២៣, ថាន់ និង សាភាន់ គឺជាអនុប្រធានមន្ទីរតំបន់ ២៣ បានលួចយកថ្នាំពេទ្យចំនួន ៦០ដប ក្នុងនោះមានថ្នាំ ប៉េនីស៊ីលីន ៣០ដប និងសេរ៉ូមមួយ ឡាំង ទៅប្រគល់ឲ្យឈ្មោះ យ៉ុន គឺជាសមាជិកមន្ទីរតំបន់ ២៣ និង ណាក់ ទុកនៅក្នុងមន្ទីរតំបន់ ២៣។ ក្រោយមកនៅពេលយប់ខ្ញុំបាននាំគ្នារង់ចាំស្កាត់បាញ់ឡានពាណិជ្ជកម្ម និងឡានរបស់កម្មាភិបាលណាដែលបើកតាមផ្លូវស្វាត់។



អដ្ឋិធាតុរបស់ជនរងគ្រោះនៅវត្តឫស្សីសាញ់ ក្នុងឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ សូ បានណែនាំខ្ញុំឲ្យទៅជួបជាមួយឈ្មោះ សាលឺវ គឺជាលេខាស្រុកប្រសូត្រ។ បន្ទាប់មកកម្លាំងរបស់យើងបាននាំគ្នាទៅជួបឈ្មោះ ផន គឺជាយុទ្ធជនកងការពារ, ពេជ្រ និង សាវឿន គឺជាខ្សែចាស់តាំងពីឆ្នាំ១៩៧០។ អ្នកទាំងនោះបានធ្វើសកម្មភាពដើម្បីយកទៅរាយការណ៍ឲ្យ សូ និង ត្រៀមរៀបចំផែនការ កម្លាំងក្នុងការធ្វើរដ្ឋប្រហារនៅក្នុងខែមេសា ឆ្នាំ១៩៧៦។ នៅក្នុងខ្លឹមសារទីមួយយើងត្រូវបានណែនាំឲ្យស្គាល់កម្លាំងថ្មីមួយចំនួនគឺឈ្មោះ សាវ៉ន អនុប្រធានសន្តិសុខស្រុកកំពង់រោទិ៍, បូ សមាជិក សន្តិសុខស្រុកកំពង់រោទិ៍, សារិន អនុលេខាស្រុកកំពង់រោទិ៍ តាមរយៈយ៉ា គឺជាប្រធានយោធាស្រុកកំពង់រោទិ៍។



( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅឆ្នាំ១៩៧៦ដដែល បញ្ហាធ្វើវិទ្ធេទកម្ម គឺ យ៉ា បានចាត់តាំងកម្លាំងឲ្យលួចដុតស្រូវនៅតាមព្រំដែន ចំនួន ២០ហិកតា ហើយក៏បានលាក់ស្រូវចំនួន ១៥០០បាវ ទុកនៅក្នុងជង្រុករបស់ស្រុកកំពង់រោទិ៍ ស្ថិតនៅក្នុងភូមិត្រពាំងរោធ ឃុំត្រពាំងរោទិ៍ ដោយមិនបានរាយការណ៍ប្រាប់ថ្នាក់លើ។ ចំណែកការទំនាក់ទំនងជាមួយយួន យ៉ា ជាអ្នកក្តាប់បានច្រើន។ ខ្ញុំបានយកព័ត៌មាននេះ ទៅរាយការណ៍ប្រាប់ សូ។ សូ បានឲ្យខ្ញុំ និង សាភាន់ នាំផែនការមួយចំនួនទៅឲ្យឈ្មោះ ផន និង បក្ខពួកនៅកំពង់រោទិ៍វិញ។ ក្រោយមកយើងកសាងបានកម្លាំងម្នាក់ទៀតឈ្មោះ វ៉ុន គឺជាអ្នកបកប្រែអក្សរទូរលេខ តំបន់២៣។

នៅខែមីនា ឆ្នាំ១៩៧៦ សូ បានចាត់តាំងកម្លាំង ចំនួន១០នាក់ ដើម្បីយាមការពារជាសម្ងាត់នៅក្នុងឱកាសដែលប្រជុំជាមួយយួននៅផ្ទះសម្ងាត់មួយ នៅភូមិត្បែង សង្កាត់គគីសោម របស់ស្រុកប្រសូត្រ។ សូ ចេញដំណើរនៅវេលាម៉ោង ៣ រសៀល ដោយជិះឡានស៊ីប ជាមួយឈ្មោះ ថាន់ និង កាក់ និងមានអ្នកបើកបរឈ្មោះ សំអេន។ នៅពេលទៅដល់កន្លែងប្រជុំ ខ្ញុំឃើញមានឈ្មោះ កួន, សាលីវ, ផន, ផល, ឆែម, ស៊ើល, ពិន, សាមន និងយួនឈ្មោះ បែកាវ និង ហុក ដោយមានអ្នកការពារជាជនជាតិយួនចំនួនបីនាក់ និងគណៈយោធាខេត្តតែនិញ ចូលរួមប្រជុំដែរ។ បន្ទាប់មកអ្នកទាំងអស់នាំគ្នាទៅស៊ីផឹកនៅផ្ទះសម្ងាត់មួយ ស្ថិតនៅចុងភូមិត្បែងខាងជើង សង្កាត់គគីសោម រហូតដល់ម៉ោង១១យប់ ទើបការប្រជុំបានបញ្ចប់។ ថាន់ ដែលបានចូលរួមក្នុងការប្រជុំ បានប្រាប់ខ្ញុំអំពីផែនការរៀបចំកម្លាំងធ្វើរដ្ឋប្រហារ ផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា ដោយមានយួនជាកម្លាំងខាងក្រៅ, ការត្រៀមស្បៀង ថ្នាំពេទ្យ និងការត្រៀមឡានសម្រាប់ដឹកជញ្ជូន។

នៅខែមេសា ឆ្នាំ១៩៧៦ តាមការណែនាំរបស់ សូ, ខ្ញុំ និងឈ្មោះ ថាន់, សាក់ បាននាំគ្នាទៅជួបទាក់ទងជាមួយឈ្មោះ ផល ដើម្បីសួរអំពីសកម្មភាពរបស់បក្ខពួកនៅក្នុងស្រុកទាំងមូល ដែលបានធ្វើសកម្មភាពកន្លងមក។ នៅខែសីហា ឆ្នាំ១៩៧៦ ដដែល តាមការណែនាំរបស់ សូ, ខ្ញុំ, ថុន, ហាន គឺជាអនុក្រុមកងការពារមន្ទីរ បាននាំគ្នាយកផែនការរបស់ សូ ទៅប្រគល់ឲ្យឈ្មោះ ស៊ើល និង ឈ្មោះ ម៉ក់ អនុវត្ត ដោយអង្គភាពរបស់អ្នកទាំងពីរមានភារកិច្ចដឹកប្រឡាយ ព្រែក នៅទន្លេកំពង់ត្រាចពីស្រុករមាសហែក រហូតទៅដល់ហែកសំណាញ់ក្នុងស្រុកសំរោង។ តាមការណែនាំនោះ គឺត្រូវធ្វើយ៉ាងណារារាំងផែនការជីកប្រឡាញកុំឲ្យលឿន, បំផុសយុវជន និងយុវនារី ឲ្យរត់ចោលការដ្ឋាន និងចាត់តាំងកម្លាំងឲ្យដើរអុកឡុកពីបញ្ហាសីលធម៌បុរសនារី និងបង្កើតឲ្យមានការលួចឆក់ប្លន់ដើម្បីឲ្យប្របូកប្របល់នៅក្នុងសហករណ៍។

នៅខែវិច្ឆិកា តាមការណែនាំរបស់ សូ, ខ្ញុំ, ជុល, សាភាន់, ថាន់, សាក់ បានទាក់ទងជាមួយឈ្មោះ សាម គឺជាប្រធានសន្តិសុខតំបន់ ២៣, សាវាន់ គឺជាអនុប្រធានសន្តិសុខតំបន់ ២៣ ដែលបានមកបានបោះទីតាំងនៅវត្តក្តីរំដួល ធ្វើជាកន្លែងពន្ធនាគារសម្រាប់ដាក់អ្នកទោស។ ចំណែកកន្លែងរស់នៅគឺធ្វើផ្ទះមួយនៅខាងលិចវត្តរំដួល ចម្ងាយ១០០ម៉ែត្រ។ បន្ទាប់មកបានចាត់តាំង សាម និង សាភាន់ ឲ្យផ្សព្វផ្សាយដល់បក្ខពួកឲ្យអនុវត្ត គឺ ១) អប់រំកសាងកម្លាំងនៅក្នុងជួរអ្នកទោសតំបន់២៣ មានឈ្មោះ យឹម គឺជាអនុប្រធាននារី គឺជាអ្នកក្តាប់ ២) ចាប់មនុស្សដែលមិនអនុវត្តតាមការណែនាំពីកម្លាំងរបស់យើងដែលអូសទាញនិងកសាងកម្លាំងបន្ថែម ៣) ចម្លើយដែលឆ្លើយចំខ្សែរបស់យើងត្រូវតែបំបិទទុក ៤) បង្កើតឲ្យមានសីលធម៌ពាលានៅក្នុងមន្ទីរសន្តិសុខ។ កម្លាំងដែលយើងកសាងបាន គឺត្រូវយកទៅធ្វើស្រែនៅក្នុងការដ្ឋាន និងត្រូវមានការកិច្ចកសាងកម្លាំងពង្រីកកម្លាំងនៅតាមសហករណ៍ និងបំផុសឲ្យបង្កើតសីលធម៌នៅក្នុងសហករណ៍បន្ត។

នៅខែមេសា ឆ្នាំ១៩៧៧ តាមការណែនាំរបស់ សូ, សាក់ និង សាភាន់ យើងបាននាំគ្នាទៅទាក់ទងជាមួយឈ្មោះ ទៀប គឺជាអនុប្រធានសេដ្ឋកិច្ចតំបន់ ២៣ ដើម្បីសួរពីកម្លាំងថ្មីដែលកសាងបាន, ការត្រៀមធ្វើរដ្ឋប្រហារនៅខែកក្កដា ឆ្នាំ១៩៧៧ និងសកម្មភាពប្រឆាំងអង្គការ។ ទៀប បានឲ្យដឹងថា កម្លាំងថ្មីដែលកសាងបានចំនួនពីរនាក់មានឈ្មោះ សាវីន ត្រូវជាបងប្រុសរបស់ឈ្មោះ សាវ៉ាន គឺជាប្រធានមន្ទីរស្រុកប្រសូត្រ។ សាវីន មានតួនាទីគឺជាប្រធានគមនាគមន៍តំបន់ ២៣។ ស៊ី មន មានតួនាទីជាប្រធានសិប្បកម្មតម្បាញ និងកាត់ដេរតំបន់២៣។ អ្នកទាំងពីរបានធ្វើសកម្មភាពប្រឆាំងអង្គការដោយលួចដុតស្រូវនៅវាលដើមពោធិ៍ ក្នុងភូមិដប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទិ៍ អស់ចំនួន ២០០ហិកតា និងបានលួចលាក់ស្រូវសម្រាប់ផែនការបានចំនួន ២០០០ថាំង។ ក្រោយមកខ្ញុំ, សាក់, យ៉ូន បាននាំគ្នាលួចយកថ្នាំពេទ្យលាក់បានចំនួន ៥០០ដប តាមការណែនាំរបស់ សូ។

នៅខែសីហា ឆ្នាំ១៩៧៧ សាក់ បានហៅខ្ញុំ, សាភាន់ ទៅជួបទាក់ទងជាមួយ ទៀប, សាវីន និង ស៊ីមន ដើម្បីផ្សព្វផ្សាយអំពីផែនការដែល សូ លើកឡើងជាមួយ យួន។ ពេលនោះ យើងក៏បានលើកអំពីការលាក់ស្រូវត្រៀមទុកចំនួន ៥០០ថាំង នៅខាងជើងវត្តព្រៃឆ្លាក់ និងការត្រៀមឡាន និងប្រេងចំនួន ២០ពុយ។ រហូតដល់ខែតុលា ឆ្នាំ១៩៧៧ ខ្ញុំ, ថាន់, សាភាន់, សាម៉េត គឺជាសមាជិកមន្ទីរតំបន់ ២៣ បានទៅជួបទាក់ទងជាមួយ សាត និង សាវ៉ាក់ ដើម្បីពិភាក្សាគ្នានិងចាត់តាំងកម្លាំងមួយក្រុម ឲ្យត្រៀមកម្លាំងរង់ចាំបាញ់ឡានរបស់កម្មាភិបាល និងធ្វើសកម្មភាពអុកឡុកប្រជាជននៅតាមមូលដ្ឋាន។ សូ បានណែនាំឲ្យខ្ញុំនិងបក្ខពួកប្រាំនាក់ទៀតនៅក្នុងស្រុកកំពង់រោទិ៍ នាំកងទ័ពយួនចូលមកស្រុកកំពង់រោទិ៍និងស្រុកប្រសូត្រ, ប្រមូលស្បៀងស្រូវអង្ករ គោ ក្របី ឲ្យយួនពេលយួនចូលមកដល់ និងឲ្យ យ៉ា ប្រាប់យួនពីជង្រុកស្រូវធំៗ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ពេលកងទ័ពយួនវាយបុកចូលមកខ្លាំង ខ្ញុំបានគេចទៅនៅភូមិតាពិច ឃុំស្វាយជ្រំ ស្រុកមានជ័យថ្មី។ សូ បាននាំខ្ញុំឲ្យទៅស្គាល់ អូ និងប្រគល់ខ្ញុំឲ្យរស់នៅផ្ទាល់ជាមួយគាត់។ អូ គឺជាអនុប្រធានសេដ្ឋកិច្ចស្រុកមានជ័យថ្មី ដែលមានទីតាំងនៅភូមិតាពេជ គឺជាខ្សែស.អ៊ិ.អា របស់ សូ និង ឈៀវ លេខាឃុំស្វាយយា ស្រុកមានជ័យថ្មី។ ខ្ញុំ, អូ,ថាន់,អឿន គឺជាប្រធានក្រុមកងការពារមន្ទីរតំបន់ បាននាំគ្នាធ្វើសកម្មភាពឃោសនាបំផុសចលនានៅតាមមូលដ្ឋានដោយនិយាយថាកាំភ្លើងបេ៤០ និងបេ៤១ របស់ខ្មែរក្រហម បាញ់រថក្រោះរបស់យួនមិនឆេះទេ។ ខ្ញុំនៅជាមួយ អូ បានរយៈពេលកន្លះខែ ខ្ញុំនិងបក្ខពួកបានរត់ទៅនៅមន្ទីរសង្កាត់ស្វាយយាវិញ ដើម្បីបន្តទាក់ទងជាមួយ ឈាវ គឺជាលេខាសង្កាត់ស្វាយយា។ ខ្ញុំនៅតែធ្វើសកម្មភាពបំផុសបំផុល និងទាក់ទងជាមួយកម្លាំងរបស់ខ្ញុំ ។

នៅចុងខែធ្នូ ឆ្នាំ១៩៧៧ សូ បានចេញពីសាលារៀនជាមួយអង្គការ ហើយបានប្រមូលបក្ខពួកមួយចំនួនទៅប្រជុំរៀបចំផែនការថ្មី នៅភូមិកីស្វា ស្ថិតនៅឃុំ

ស្វាយយា ស្រុកមានជ័យថ្មីៗ អ្នកដែលបានចូលរួមប្រជុំ រួមមាន ១) សាក់ ២) ឈាន ៣) យ៉ាន គឺជាប្រធានពេទ្យតំបន់ ៤)ទៀប, ៥) ម៉ក់ គឺជាប្រធានពាណិជ្ជកម្មតំបន់ ២៣ ៦) វុធ្វី ៧) ធុំ ៨) ចាន់ គឺជាអនុលេខាស្រុកប្រសូត្រ ៩) ឆែម ១០) សឿល ១១) ផន ១២) ផល គឺជាលេខាស្រុករមាសហែក និងសាលីវ។ នៅក្នុងខ្លឹមសារ ប្រជុំ សូ បានណែនាំ ឆែម និង សឿល ឲ្យប្រមូលកម្លាំងទ័ពតំបន់ ២៣ និងទ័ពស្រុកទាំងអស់នៅក្នុងតំបន់ ២៣ ដែលត្រូវរត់ចេញពីអង្គភាព និងជាកម្លាំងដែលត្រូវជាខ្សែរបស់យើង ដោយបំផុស និងឲ្យរត់ចេញពីសមរភូមិ និងរត់ចេញពីកងពល ២៩០ នៅខាងលិចទីរួមខេត្តស្វាយរៀង ដើម្បីបើកផ្លូវឲ្យយួនអាចចូលបាន និងឲ្យរៀបចំកម្លាំងរង់ចាំបាញ់កម្មាភិបាលរបស់អង្គការ ជាពិសេសកម្មាភិបាលកងពល។ ប៉ុន្តែដោយកងទ័ពស្រុក និងកងទ័ពតំបន់មួយចំនួនត្រូវបានបែកខ្ញែកកម្លាំង ដូច្នេះការអនុវត្តផែនការនេះត្រូវទទួលបរាជ័យ។ ក្រោយមកទ័ពរបស់អង្គការត្រូវបានបញ្ចូលមកកាន់តែច្រើន ហើយបានវាយទ័ពបណ្តេញកងទ័ពយួនឲ្យចេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨។ បន្ទាប់មកអង្គភាពរបស់ខ្ញុំបានត្រឡប់ទៅស្វាយរៀងវិញ។

នៅខែមករា ឆ្នាំ១៩៧៨ មានការប្រជុំមួយទៀត សូ បានណែនាំថា មានតែគណៈយោធាដែលអាចទាក់ទងជាមួយយួនបាន ព្រោះគណៈយោធាមានភារកិច្ចត្រួតពិនិត្យសមរភូមិ។ មុខសញ្ញាខាងជើងដូងមាន សឿល ធ្វើជានីរសារទាក់ទងយួន ។

ចំណែកខាងត្បូងស្រុកចន្ទ្រាមាន ឆែម។ ក្រោយមក សូ បានឲ្យខ្ញុំដំឡើងវិទ្យុចំនួនពីរគ្រឿងសម្រាប់ទាក់ទងជាមួយយួន មានសេ២៥ និង សេ៧៧ ដោយប្រគល់ឲ្យអ្នកកាន់គេអូ គឺមានខ្ញុំ និង ថាន់។ លេខសម្ងាត់ក្នុងការប្រើមានពីរសម្រាប់ ពេលព្រឹកនិងពេលល្ងាច។ ពេលព្រឹកប្រើលេខ ៤០ និង ៤៥ ដោយបានកំណត់ចាប់ពីម៉ោង ៦ព្រឹក និងពេលល្ងាច ចាប់ពីម៉ោង ៦ល្ងាច កំណត់លេខប្រើ ៦៥ និង២៥ ។ នៅពេលទាក់ទងជាសម្ងាត់សម្រាប់តំបន់២៣ ហៅ ០១៩ ។ ប្រសិនបើចង់ទាក់ទងហៅទៅយួន គណៈយោធាខេត្តតៃនិញ គឺ អ៊ី-សូន្យ ៧ (I07) មុខសញ្ញាសម្រាប់ខេត្តឡុងអានប្រើ អ៊ី-សូន្យ៥ (I05) និងសម្រាប់ទាក់ទងជាមួយឈ្មោះ បៃការ និង បុកមុខសញ្ញាផ្លូវជាតិលេខ១ប្រើ អ៊ី-សូន្យ៩ (I09)។

ក្រោយមកគណៈយោធាខេត្តតៃនិញ បានទាក់ទងយើងអំពីសភាពការណ៍យោធារបស់ប្រទេសកម្ពុជា នៅតាមព្រំដែន និងក្រុងស្វាយរៀង ដោយចង់ដឹងពីកម្លាំងតិចឬច្រើន អាវុធ និង មានរថក្រោះឬទេ ហើយត្រៀមវាយប្រទេសរបស់ខ្លួនពេលណា។ តាមការណែនាំរបស់ សូ ខ្ញុំបានរាយការណ៍ទៅឲ្យយួន និងបានប្រាប់អំពីទ័ពស្រួចរបស់អង្គការ មានកាំភ្លើងធំធុន ១៣០ ចល័តដាប់ៗ ចំណែកសភាពការណ៍ខាងខ្សែរបក្ខពួករបស់ខ្ញុំកំពុងបែកការ ដោយអង្គការតាមស្រាវជ្រាវ និងចាប់បានមួយចំនួនជាបន្តបន្ទាប់។ នៅខែសីហា ឆ្នាំ១៩៧៨ បានជួបជាមួយ ម៉ន គឺជាលេខាវរសេនាធំតំបន់ ២៣ ។ ម៉ន បានប្រាប់ខ្ញុំឲ្យបានដឹងអំពីសកម្មភាពដែលបានយកកាំភ្លើងប្រហែលជាមួយ ឡានលាក់ទុកនៅរណ្តៅចាស់មួយនៅក្នុងជំរំបុស្ស៊ី ដែលស្ថិតនៅខាងកើតវត្តសំបួរប្រហែលជា ១០០ម៉ែត្រ។ កាំភ្លើងលាក់ទុកទាំងនោះសម្រាប់យកអនុវត្តសកម្មភាពនៅពេលខាងមុខ។

នៅចុងខែ កុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំឈឺគ្រុនញាក់និងបានដេកពេទ្យរបស់តំបន់ ២៣ ។ រហូតដល់ថ្ងៃទី ១២ ខែមីនា សូ បានមកយកខ្ញុំចេញពីតំបន់ ២៣ ទៅនៅតំបន់ ២៤។ ខ្ញុំបាននៅជាមួយ សូ បានរយៈពេលបួនថ្ងៃ គឺនៅថ្ងៃទី១៣ ខែមីនា សូ ត្រូវបានអង្គការចាប់ខ្លួន។ លុះរំលងបានប៉ុន្មានថ្ងៃ នៅព្រឹកឡើងថ្ងៃទី១៧ ខែមីនា ឆ្នាំ ១៩៧៨ រូបខ្ញុំត្រូវអង្គការចាប់ខ្លួនដែរ។

កំណត់ចំណាំ៖ អត្ថបទនេះសង្ខេបចេញពីឯកសារចម្លើយសារភាពលេខD១៣៨៣៨៩។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានទេថាចម្លើយសារភាពរបស់ ឥន សារ៉ុន ហៅ ផុល ពិតប៉ុណ្ណាណា... 

# ទូន ចាន់ដារ៉ា ហៅ ភាន់
## យុទ្ធនារីក្រសួងសាធារណការ និងប្តីត្រូវចាប់ខ្លួន មកឃុំឃាំងនៅក្នុងគុកទួលស្លែង

*អ៊ុន សុជាទី*




*រូបខាងស្តាំ៖ ទូន សុផល្លា និង នួន ឃឿន (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ខ្ញុំឈ្មោះ ទូន ចាន់ដារ៉ា ហៅ ភាន់ កើតនៅក្នុងឆ្នាំ១៩៤៦។ ខ្ញុំមានស្រុកកំណើតនៅភូមិ ជ្រោយថ្ម ឃុំកំពង់សៀម ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ទូន ឡាង គឺជាអតីតចៅហ្វាយខេត្ត និងតំណាងរាស្ត្រនៅមណ្ឌលស្ទួង ខេត្តកំពង់ចាម។ នៅក្នុងឆ្នាំ១៩៦១ ឪពុកខ្ញុំបានផ្លាស់មករស់នៅទីក្រុងភ្នំពេញ។ នៅពេលដែលឪពុករបស់ខ្ញុំផ្លាស់មករស់នៅទី ក្រុងភ្នំពេញ ខ្ញុំបានស្នាក់នៅជាមួយឪពុកធំរបស់ខ្ញុំឈ្មោះ ទូន គឹមសៀ។ ឪពុកធំរបស់ខ្ញុំ គឺជាគ្រូបង្រៀន។ ខ្ញុំបានរៀនសូត្រនៅក្នុងវិទ្យាល័យសីហនុកំពង់ចាម។*

*នៅអំឡុងឆ្នាំ១៩៦២ ខ្ញុំបានផ្លាស់មករស់នៅជាមួយឪពុកម្តាយខ្ញុំនៅឯទីក្រុងភ្នំពេញវិញ។ ផ្ទះរបស់ខ្ញុំ ស្ថិតនៅម្តុំមេភ្លើង ពេទ្យចិន។ ខ្ញុំបានបន្តចូលរៀននៅឯវិទ្យាល័យយុគន្ធរ រហូតដល់ថ្នាក់ទី៤ ទើបខ្ញុំសម្រេចចិត្តឈប់រៀន។*

*នៅក្នុងឆ្នាំ១៩៦៤ ខ្ញុំបានរៀបការជាមួយ ទូន សុផល្លា ហៅភឿន។ ប្តីរបស់ខ្ញុំនិងខ្ញុំ ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។យើងមានកូនចំនួន ៦នាក់។ ប្តីរបស់ខ្ញុំ ក៏មានស្រុកកំណើតនៅក្នុងខេត្តកំពង់ចាមដែរ។ គាត់បានមកបន្តការសិក្សានៅក្នុងវិទ្យាល័យស៊ីសុវត្ថិឯទីក្រុងភ្នំពេញ មុនពេលដែលខ្ញុំមកដល់។*

*នៅក្នុងខែមករា ឆ្នាំ១៩៦៥ សមាគមនិស្សិត ត្រូវបានបង្កើតឡើងជាផ្លូវការនៅទីក្រុងភ្នំពេញ។ ភោគ ឆាយ ត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធានសមាគមនិស្សិត ចំណែកឯប្តីរបស់ ខ្ញុំគឺជាអគ្គលេខាធិការ។ ក្រោយពីសមាគមនិស្សិតនេះបង្កើតបានរយៈពេលប្រហែលកន្លះខែ គិញបានចាប់ខ្លួនប្តីរបស់ខ្ញុំយកទៅឃុំឃាំង ព្រោះប្តី*

*របស់ខ្ញុំបានធ្វើសកម្មភាពបាចខិតប័ណ្ណ។ បន្ទាប់ពីប្តីរបស់ខ្ញុំជាប់ឃុំឈ្មោះ ឈុន សុខន្ធួន បានធ្វើការងារជំនួសគាត់។*

*នៅក្នុងគុក ប្តីរបស់ខ្ញុំមិនបានធ្វើសកម្មភាពអ្វីទៀតនោះទេ។ កន្លងផុតអស់រយៈពេលប្រហែល១ឆ្នាំ ឪពុករបស់ខ្ញុំបានទៅធានាប្តីរបស់ខ្ញុំឲ្យចេញពីគុកវិញ និងណែនាំប្តីរបស់ខ្ញុំឲ្យចូលខ្មែរសេអ៊ីអា។*

*ឈ្មោះ ហ៊ុយ ម៉ោង ដែលមាននាទីជាប្រធានគណបក្សប្រជាធិបតេយ្យ គឺជាអ្នកទទួលស្គាល់ប្តីរបស់ខ្ញុំ។ ក្រោយមក ខ្ញុំត្រូវបានចាត់តាំងឲ្យចូលបង្កប់ក្នុងចលនាតស៊ូនៅក្នុងក្រុងជាមួយប្តីរបស់ខ្ញុំ។ នៅក្នុងចលនានេះ យើងបានរៀបចំផែនការ កសាងកម្លាំង សេ.អ៊ី.អា, ស៊ើបការណ៍ពីទីស្នាក់ការរបស់បដិវត្តន៍នៅក្នុងក្រុង, ឃោសនាបំផុសប្រជាជនឲ្យប្រឆាំងនឹងបដិវត្តន៍ និងបំបែកបំបាក់ចលនាតស៊ូរបស់និស្សិតក្នុងក្រុង។ អ្នកដែលចូលខ្មែរ សេ.អ៊ី.អា តាមរយៈប្តីរបស់ខ្ញុំចាប់ពីឆ្នាំ១៩៦៨ ដល់ ឆ្នាំ១៩៧៣ ដែលមានបង្កប់ក្នុងចលនាតស៊ូក្នុងក្រុង មានឈ្មោះ អ៊ិត ហេង គឺជាចាងហ្វាងរោងពុម្ពវត្តភ្នំ, ម៉ៅ រុន គឺជាសាស្ត្រាចារ្យ, នុត គីមឡេង ជាពេទ្យសត្វ, សៀង ប៉ោសែ ជាចាងហ្វាងភូមិសាស្ត្រ, ម៉ៃ សាខន ហៅ សំ ផ្នែកត្រាវ៉ូ និង ឌី ផុន ហៅ ផុក គឺជាពេទ្យធ្មេញ។*

*នៅខែមីនា ឆ្នាំ១៩៧៣ ប្តីរបស់ខ្ញុំបានចេញទៅបង្កប់ខ្លួនក្នុងជួរបដិវត្តន៍នៅតំបន់រំដោះ។ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៣ ដដែល ខ្ញុំបានចេញទៅតាមប្តីរបស់ខ្ញុំ។ ខ្ញុំចេញទៅនេះ តាមរយៈ អ៊ិត ហេង ដើម្បីឲ្យខ្ញុំយកផែនការទៅទំនាក់ទំនងជាមួយនឹង សៀង ប៉ោសែ និងប្តីរបស់ខ្ញុំ។ ពេលខ្ញុំចេញទៅនៅពេលនោះ ខ្ញុំបានត្រឹមតែជួបជាមួយ សៀង ប៉ោសែ និងប្រាប់គាត់អំពីផែនការដែល អ៊ិត ហេង បានដាក់ឲ្យតែប៉ុណ្ណោះ ប៉ុន្តែមិនទាន់បានអនុវត្តនោះទេ។*

*នៅខែមេសា ឆ្នាំ១៩៧៤ អង្គការបានឲ្យខ្ញុំត្រឡប់ទៅបង្កបង្កើនផលនៅឯមន្ទីរក-៣០០ អង្គភាពស.៧១ ស្ថិតក្នុងភូមិភាគឧត្តរ។ ពេលនោះ សៀង ប៉ោសែ បានឲ្យខ្ញុំទាក់ទងជាមួយខ្មែរ សេ.អ៊ី.អា នៅក្នុងមន្ទីរដែលមានឈ្មោះថា នារី អេម អតីតធ្វើស្រែ និងធ្វើពេទ្យនៅក្នុងមន្ទីរនោះ។ ខ្ញុំបានជួបប្តីរបស់ខ្ញុំដែលកំពុងតែបង្កបង្កើនផលនៅក្នុងអង្គភាព ស.៧១ នោះដែរ។ នារី អេម បានប្រាប់ខ្ញុំឲ្យស្គាល់ ហ៊ូ នឹម ហៅភាស់, គួច គឿន ហៅ ភិន, នារីភី ដែលជាជនជាតិលាវ និងនារី វ៉ាន។ សកម្មភាពរបស់ក្រុមខ្ញុំគឺបំផ្លាញស្រូវនៅក្នុងជង្រុកដោយធ្វើឲ្យរហែកដំបូល ទទឹកស្រូវ និងអំបិលដែលត្រៀមទុកសម្រាប់សមរភូមិឆ្នាំ១៩៧៥។ ក្រុមខ្ញុំក៏បានបំផុសពីបញ្ហាមិនចាយលុយនៅក្នុងអង្គភាពដើម្បីឲ្យមានទំនាស់ជាមួយអង្គការ។*

*ក្រោយមកនៅក្នុងខែមីនា ឆ្នាំ១៩៧៥ ប្តីរបស់ខ្ញុំត្រូវបានអង្គការដកយកទៅតំបន់ ១០៣ ។ ៣ខែកន្លងទៅ អង្គការក៏បានដកខ្ញុំ, ទី, កុច, ផង់ និងរិន ឲ្យទៅតំបន់១០៣ដែរ ហើយ អេម បានឲ្យយើងទាក់ទងអ្នកនៅតំបន់១០៣ ដើម្បីអនុវត្តផែនការបន្តទៀត។ អង្គការបានចាត់តាំងឲ្យខ្ញុំធ្វើជាអ្នកធ្វើប្រវត្តិរូបនៅក្នុងពាណិជ្ជកម្មស្រុករវៀងអស់រយៈពេល១ខែ។ អំឡុងពេលនោះ ខ្ញុំក៏បានបែកចេញពីប្តីរបស់ខ្ញុំម្តងទៀត។ អង្គការបានដកគាត់ឲ្យមកនៅ ភ្នំពេញវិញ។*

*នៅក្នុងខែសីហា ឆ្នាំ១៩៧៥ អង្គការបានដកខ្ញុំចេញពីពាណិជ្ជកម្មស្រុករវៀង ឲ្យទៅរស់នៅក្នុងសហករណ៍វិញ។ ខ្ញុំក៏បានទាក់ទងនឹងខ្មែរ សេ.អ៊ី.អា ថ្មីមានឈ្មោះ សេន និង ភី ដើម្បីអនុវត្តផែនការបន្តទៀត។ សកម្មភាពរបស់ខ្ញុំ បានកសាងកម្លាំងចំនួន ៥នាក់ បន្ថែមទៀត គឺ នុត, ជុំ, នារីនឹម, នារីថន និងនារីផស់ ដែលអ្នកទាំងអស់ គឺជាប្រជាជននៅទីនោះ។ យើងបាននាំគ្នាបំផុសប្រជាជននៅក្រុមទី១ ឲ្យប្រឆាំងនឹងអង្គការចែករំលែកស្រូវឲ្យប្រជាជនថ្មី និងលាក់ស្រូវទុកដាំបាយហូបនៅក្នុងក្រុម។ ថ្ងៃមួយឈ្មោះ រឹត បានឲ្យខ្ញុំយកថ្នាំពេទ្យទៅចែក ប្រជាជននៅក្នុងក្រុមដើម្បីឲ្យប្រជាជនមានគំនិតប្រឆាំងនឹងអង្គការ ដោយសារតែមិនគិតគូរដោះស្រាយថ្នាំពេទ្យឲ្យប្រជាជន និងទុកឲ្យប្រជាជនស្លាប់។*

*នៅក្នុងខែតុលា ឆ្នាំ១៩៧៥ ខ្ញុំធ្លាក់ខ្លួនឈឺគ្រុន ហើយមកដេកពេទ្យនៅក្នុងស្រុករវៀងអស់រយៈពេល ៣ខែ។ ក្រោយមកនៅដើមឆ្នាំ ១៩៧៦ អង្គការបានបញ្ជូនខ្ញុំឲ្យមករស់នៅជាមួយប្តីរបស់ខ្ញុំនៅឯក្រសួងសាធារណការវិញ។ ខ្ញុំក៏បានបន្តដេកពេទ្យព.១៧ អស់រយៈពេល ៣ខែទៀត។*

នៅដើមឆ្នាំ១៩៧៦ដដែល ខ្ញុំបានចេញពីពេទ្យមកនៅសាធារណការមន្ទីរស៨ ជាមួយប្តីរបស់ខ្ញុំ។ ខ្ញុំបានជួបនឹងប្តីរបស់ខ្ញុំមិនទាន់បានប៉ុន្មានផង អង្គការបានចាត់ឲ្យគាត់ទៅបំពេញភារកិច្ចនៅការដ្ឋានវារីអគ្គិសនីនៅគិរីរម្យ។ ចំណែកខ្ញុំ បានទំនាក់ទំនងជាប់ជាមួយនឹងនារី អេម ធ្វើពេទ្យនៅក្នុងមន្ទីរ, នារី ផស់ អ្នកមើលថែកុមារ, ម៉ៃ សាខន អនុប្រធានមន្ទីរស-៨, តូច ភឿន ប្រធានក្រសួងសាធារណការ និងប្រពន្ធរបស់គាត់គឺជាប្រធានមន្ទីរកុមារ។ តូច ភឿន បានរៀបចំមន្ទីរកុមារនៅបឹងត្របែក ហើយក្រោយមកបានផ្លាស់ប្តូរទីតាំងទៅក្រោយរោងកុន មេគង្គ ស្ថិតនៅក្រោយផ្សារដើមគរវិញ។ រហូតដល់ខែឧសភា ឆ្នាំ១៩៧៦ ប្តីរបស់ខ្ញុំបានត្រឡប់មកពីការដ្ឋានវារីអគ្គិសនីគិរីរម្យ មកសាធារណការមន្ទីរស៨វិញ។

នៅក្នុងខែកក្កដា ខ្ញុំ, ទូច និង ផស់ បានទទួលផែនការរដ្ឋប្រហារឆ្នាំ១៩៧៧ ពីនារី អេម ។ នារីអេម បានឲ្យយើងខិតខំកសាងកម្លាំងឲ្យបានច្រើននិងរៀបចំកន្លែងលាក់ថ្នាំពេទ្យ។ ក្រោយមក ម៉ៃ សាខន បានដឹកថ្នាំពេទ្យយកមកឲ្យខ្ញុំ, ទូច និងផស់ យកទៅទុកនៅក្នុងមន្ទីរកុមារ។



កម្មករនៅស្រុកមង្គលបុរី ភូមិភាគពាយ័ព្យ កំពុងចងដែកយកទៅធ្វើទ្វារទឹក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែកញ្ញាឆ្នាំ១៩៧៦ ខ្ញុំនិងប្តី បានទៅទាក់ទងសៀង ប៉ោសែ ដើម្បីសួរពីផែនការធ្វើរដ្ឋប្រហារឆ្នាំ១៩៧៧។ សៀង ប៉ោសែ ក៏ប្រាប់ប្តីរបស់ខ្ញុំវិញថា ផែនការរៀបចំសម្ភារ, ស្បៀង និងកម្លាំងរួចអស់ហើយ។ សៀង ប៉ោសែ ក៏បានដាក់ផែនការឲ្យប្តីរបស់ខ្ញុំរៀបចំត្រៀមកម្លាំងពិសេស។ ចំណែកខ្ញុំ និងនារីអេម បានទៅទាក់ទងនារីវ៉ាន និងនារីទី នៅក្រសួងឃោសនាការវត្តភ្នំ ដើម្បីដាក់ផែនការឲ្យអនុវត្ត។ ផែនការនោះគឺ ឲ្យកសាងកម្លាំងនៅក្នុងក្រសួងឃោសនាការ និងត្រៀមសម្ភារសម្រាប់ធ្វើរដ្ឋប្រហារ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ នារីអេម បានដកខ្ញុំឲ្យមកនៅដាំបាយក្នុងមន្ទីរស.៨។ ខ្ញុំក៏បានទាក់ទងជាមួយឈ្មោះភី ជាអ្នកដាំបាយជាមួយខ្ញុំ និងខ្សែថ្មីទៀតដែលនារីអេម កសាងបាន គឺយុទ្ធនារីឈ្មោះ យោ, រី និង ណូយ។ យើងបាននាំគ្នាបំផ្លិចបំផ្លាញចានអស់ជាង ១០០ចាន, ស្លាបព្រា២០០ និងឆ្នាំងធំៗអស់ចំនួន៣។

នៅខែមករា ឆ្នាំ១៩៧៧ អង្គការបានដកប្តីរបស់ខ្ញុំចេញពីក្រសួងសាធារណការស៨ និងចាប់ខ្លួនយកមកគុកទួលស្លែង។ ក្រោយមកបាន១០ថ្ងៃ អង្គការបានដកខ្ញុំឲ្យទៅធ្វើស្រែនៅមន្ទីរស.៧១ ព្រែកប្រា។ ខ្ញុំធ្វើការនៅទីនោះបាន១៥ថ្ងៃ អង្គការបានដកខ្ញុំឲ្យទៅនៅមន្ទីរក.១៦ ភូមិតាឡី។ ពេលនោះខ្ញុំដាច់ខ្សែទាក់ទងទាំងអស់ និងមិនបានបន្តធ្វើសកម្មភាពអ្វីទៀតនោះទេ។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្ញុំបញ្ជូនមកទួលស្លែងតែម្តង។ ឈ្មោះ ហ៊ាង, ទូច និង ប៉ូ គឺជាអ្នកសួរចម្លើយខ្ញុំ។

កំណត់ចំណាំ ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD០០១៨៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថាចម្លើយរបស់ ទូន ចាន់ដារ៉ា ហៅ ភាន់ ពិតប៉ុយ៉ាងណានោះទេ។

# ព្រះតេជគុណ សៀវ ស៊ីឈុន៖
## បានរស់ ដោយសារលាក់ប្រវត្តិរូប

គាត ស្រីឡែន



ព្រះតេជគុណ ហែម ជាវ ព្រះជន្ម៦៩ព្រះវស្សា គង់នៅវត្តថ្មដា ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះតេជគុណ សៀវ ស៊ីឈុន ព្រះជន្ម ៦៧ព្រះវស្សា សព្វថ្ងៃគង់នៅវត្តថ្មដា ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ បានមានសង្ឃដីការៀបរាប់ពីរឿងរ៉ាវជីវិតផ្ទាល់របស់ព្រះតេជគុណដូចខាងក្រោម ៖

អាត្មាមានស្រុកកំណើតនៅភូមិអូរំចេក ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។ អតីតប្រពន្ធរបស់អាត្មាឈ្មោះ អ៊ីម សាំងគី និងមានកូន៦នាក់ ក្នុងនោះប្រុស៤នាក់ និងស្រី២នាក់។ ម្តាយអាត្មាឈ្មោះ ជា តាំងហួន និងឪពុកឈ្មោះ ញឹក សៀវ។ អាត្មាជាប់សែស្រឡាយចិន និងយួនខ្លះ ពីព្រោះជីដូនរបស់អាត្មា គឺជាជនជាតិវៀតណាម និងជីតារបស់អាត្មា គឺជាជនជាតិចិន។

បន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ អាត្មាបានប្រឡងជាប់ឌីប្លូម និងត្រូវបានរបបសាធារណរដ្ឋខ្មែរកំណែនឲ្យចូលធ្វើទាហាន ប៉ុន្តែអាត្មា និងសិស្សផ្សេងទៀតបានបដិសេធ។ ពេលនោះ គ្រូរបស់អាត្មាបានណែនាំឲ្យសិស្សទាំងអស់រួមទាំងអាត្មាផង បួសជាព្រះសង្ឃទាំងយប់ដើម្បីគេចពីការចាប់ឲ្យធ្វើទាហាន។ នៅពេលព្រឹកថ្ងៃបន្ទាប់ មន្ត្រីខាងរបបសាធារណរដ្ឋខ្មែរបានមកយករូបអាត្មា និងសិស្សទាំងអស់ទៅបំពេញប្រវត្តិរូបចូលធ្វើទាហានប៉ុន្តែត្រូវបានលោកគ្រូរបស់អាត្មាប្រាប់ថា សិស្សបានបួសអស់ហើយ ទើបអាត្មា និងអ្នកផ្សេងទៀតបានរួចផុតពីការចាប់យកទៅធ្វើជាទាហាន។ ក្រោយមក អាត្មាបានរៀនបាលី និងរៀនធម៌នៅវត្តកែងសុវណ្ណ បានរយៈពេលជិតមួយឆ្នាំ ទើបអាត្មាសឹកមករស់នៅជាមួយឪពុកមានៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ឪពុកមារបស់អាត្មា គឺជាមេទាហានម្នាក់នៃរបបសាធារណរដ្ឋខ្មែរប្រចាំនៅស្រុកមោងឫស្សី។ នៅពេលនោះឪពុកមារបស់អាត្មា បានឲ្យអាត្មាចូលធ្វើទាហាន និងនៅជាមួយគាត់។ អាត្មាបានចូលធ្វើទាហានរយៈពេលខ្លីប៉ុណ្ណោះ ក៏សុំឪពុកមាលាឈប់ ពីព្រោះអាត្មាបានឃើញទាហានស្លាប់ និងរបួសច្រើននៅពេលប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមម្តងៗ។ បន្ទាប់មកអាត្មាក៏បានបួសម្តងទៀតនៅវត្តសូរិយាមោង និងប្រឡងជាប់

បាលីរងដោយទទួលបាននិទ្ទេសល្អ។ ដោយមានការជំរុញលើកទឹកចិត្តពីលោកគ្រូ អាត្មាក៏បានដាក់ពាក្យប្រឡងចូលរៀននៅសាលាអេទង់ ខេត្តបាត់ដំបង និងបានគង់នៅវត្តពោធិ៍វាល រយៈពេលមួយឆ្នាំទើបប្រឡងបញ្ចប់ថ្នាក់។

នៅចុងឆ្នាំ១៩៧២ អាត្មា ត្រូវបានកំណែនឲ្យធ្វើទាហានម្តងទៀត។ កាលនោះ អាត្មា គឺជានាយទាហានពាក់ស័ក្តិពីរប្រចាំនៅពេជ្រនិល ខេត្តកំពង់ស្ពឺ។ នៅខណៈនោះ អង្គភាពរបស់អាត្មា បានឡើងទៅជួយអន្តរាគមន៍នៅក្នុងខេត្តកំពង់ធំ, ខេត្តកំពង់ចាម និងខេត្តព្រៃវែង។ អង្គភាពអាត្មាក៏ត្រូវបានបញ្ជូនទៅវាយតទល់នឹងកម្លាំងខ្មែរក្រហមនៅម្តុំអង្គតាសោម ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ហើយបន្ទាប់ពីបាក់ទ័ពនៅត្រាំកក់ អង្គភាពរបស់អាត្មាត្រូវបានដកមកឈរជើងនៅចោមចៅ ក្នុងក្រុងភ្នំពេញវិញ។

នៅរវាងឆ្នាំ១៩៧២-១៩៧៣ ទាហាន លន់ នល់ បានវាយប្រយុទ្ធគ្នាជាមួយកងទ័ពវៀតកុងដែលសហការជាមួយខ្មែរក្រហម ឬ ហៅថាប្រតិបត្តិការចេនឡាទី១។ ការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពវៀតកុងនៅចេនឡាទី ១ គឺមានទ្រង់ទ្រាយមធ្យម ប៉ុន្តែការប្រយុទ្ធនៅអំឡុងប្រតិបត្តិការចេនឡាទី២ គឺមានទ្រង់ទ្រាយធំ ដែលជាសមរភូមិក្តៅ។ បន្ទាប់ពីប្រតិបត្តិការចេនឡាទី១ និងទី២ អង្គភាពអាត្មាត្រូវបានបញ្ជូនទៅវាយនៅខេត្តកំពង់ចាម បន្ទាប់មក អាត្មាបន្តទៅវាយនៅខេត្តព្រៃវែង នៅព្រែកតាមាក់ និងព្រៃបាំង។ អាត្មាបានតាំងចិត្តថា អាត្មាត្រូវតែហ៊ាន និងត្រូវតែក្លាហាន។ នៅក្នុងអង្គភាព អាត្មាកាចខ្លាំងណាស់ និងហ្មត់ចត់នឹងការងារ។ កូនទាហានណាហ៊ានប្រព្រឹត្តបទល្មើស និងខុសវិន័យ អាត្មាបានដាក់ទណ្ឌកម្ម។ អាត្មាបានប្រើប្រាស់យុទ្ធសាស្ត្រ និងវិធីសាស្ត្រផ្សេងៗ ដែលអាត្មាចេះដឹង ដើម្បីដឹកនាំកូនទាហាន នៅក្នុងសមរភូមិនិងនៅក្នុងបន្ទាយ។

អាត្មាបានឃើញទាហានស្លាប់ច្រើន ជាពិសេសការប្រយុទ្ធគ្នានៅក្នុងខេត្តកំពង់ធំ ដែលពេលនោះ អាត្មា



ព្រះវិហារវត្តថ្មដា ដែលសាងសង់មិនទាន់ហើយរួចរាល់ ស្ថិតនៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទើបតែឡើងបានស័ក្តិ១ កាន់មួយកងអនុសេនាធំ ដែលមានកូនទាហានជាង១០០នាក់។ នៅពេលវាយប្រយុទ្ធគ្នាម្តងៗ មានកូនទាហានស្លាប់ ២ទៅ៣នាក់ ហើយថ្ងៃខ្លះបានស្លាប់ច្រើនជាងនេះទៅទៀត។

រហូតដល់ពេលខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អាត្មាមិនបានត្រឡប់មករស់នៅក្នុងស្រុកកំណើតវិញទេ គឺអាត្មាបានទៅរស់នៅក្នុងភូមិមួយនៃស្រុកកណ្តៀង តំបន់៧ ភូមិភាគពាយ័ព្យ។ អាត្មា បានលាក់ប្រវត្តិរូប និងក្លែងខ្លួនជាប្រជាជនធម្មតា។ នៅអំឡុងពេលនោះ ក៏នៅតែមានប្រជាជនខ្លះបានស្គាល់ និងដឹងថា អាត្មាធ្លាប់បានបួស និងរៀនសូត្របានច្រើន។ ប៉ុន្តែប្រជាជនទាំងនោះមិនបានដឹងថា អាត្មាធ្លាប់ធ្វើទាហាន លន់ នល់ និងបានពាក់ស័ក្តិពីរនោះទេ។ ប្រសិនជាខ្មែរក្រហមបានដឹងថា អាត្មាធ្លាប់ធ្វើទាហាន លន់ នល់

និងបានពាក់ស័ក្តិពីរ ប្រហែលជាអាត្មា គ្មានជីវិតរស់នៅដូចរាល់ថ្ងៃនេះទេ។ ខ្មែរក្រហមបានស្រាវជ្រាវរកទាហាន លន់ នល់ គ្រូបង្រៀន និងនិស្សិតស្ទើររាល់ថ្ងៃនៅក្នុងរបបនោះ។ អាត្មាបានប្រាប់ប្រធានកងថា អាត្មាធ្លាប់បានបួស និងរៀនសូត្រនៅវត្តបានបន្តិចបន្តួចប៉ុណ្ណោះ។

នៅក្នុងរបបខ្មែរក្រហម អាត្មាត្រូវបានចាត់តាំងឲ្យធ្វើការខាងដឹកជញ្ជូនសម្ភារ និងស្បៀងពីសហករណ៍ទៅផ្គត់ផ្គង់កងចល័ត និងកងទ័ព។ នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាត់តាំងអាត្មា ឲ្យដឹកជញ្ជូនអ្នកជម្លៀសមកពីខេត្តស្វាយរៀង និងខេត្តព្រៃវែង ដោយប្រាប់ថាផ្លាស់ឲ្យទៅនៅសហករណ៍ផ្សេងទៀត ឬទៅច្រូតស្រូវ ប៉ុន្តែតាមការពិត ខ្មែរក្រហមបានចាត់តាំងអាត្មាឲ្យដឹកប្រជាជនជម្លៀសទាំងនោះទៅឲ្យកងឈ្លបខ្មែរក្រហម។ អ្នកជម្លៀសទាំងនោះ រួមមាន មនុស្សចាស់ និងក្មេងៗរាប់រយនាក់ត្រូវបានឈ្លបយកទៅសម្លាប់ចោល ដោយខ្មោចត្រូវបានគរទុកចោលនៅមួយកន្លែងៗ ខ្មែរក្រហមបានសម្លាប់ប្រជាជន ទាំងអស់នោះគ្មានប្រណីឡើយ។ នៅពេលអាត្មាបានឃើញទិដ្ឋភាពទាំងនោះហើយ អាត្មាមានសេចក្តីរន្ធត់ និងអាណិតពន់ពេកដល់ប្រជាជនទាំងនោះ។ កន្លែងដែលខ្មែរក្រហមសម្លាប់ប្រជាជននោះគឺស្ថិតនៅក្នុងព្រៃ និងក្បែរបឹង ក្នុងស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ អាត្មាបានផ្លាស់មកនៅរស់នៅភូមិពោធិ៍វង្ស ហើយត្រូវបានរដ្ឋអំណាចចាត់តាំងឲ្យធ្វើជាប្រធានភូមិ។ ក្រោយមកអាត្មាបានឡើងធ្វើប្រធានយុវជនឃុំ និងប្រធានឃុំកោះជុំ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ មិនយូរប៉ុន្មាន អាត្មាបានចូលធ្វើកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងត្រូវបែកពីប្រពន្ធកូន នៅពេលរដ្ឋាភិបាលបញ្ជូនអាត្មាឡើងទៅវាយតទល់នឹងខ្មែរក្រហមនៅរលាក់កងជើង ក្នុងខេត្តកំពង់ស្ពឺ និងនៅភ្នំខ្មោចៗ ពេលនោះអាត្មា នៅក្នុងកងពលលេខ១៤ ហើយអង្គភាពអាត្មាបានផ្លាស់មកឈរជើងនៅថ្មដា និងទឹកធ្លាក់ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ ពេលនោះកងទ័ពរដ្ឋាភិបាលបានសហការជាមួយកងទ័ពវៀតណាម ដើម្បីវាយតទល់ជាមួយកងទ័ពខ្មែរក្រហម។

នៅពេលបោះឆ្នោតសកលលើកទី១ ដែលរៀបចំដោយអ៊ុន តាក់ នៅឆ្នាំ១៩៩៣ អាត្មាបាននៅរៀបចំការបោះឆ្នោតនៅតំបន់ប៉ៃលិន។ បន្ទាប់ពីបោះឆ្នោតរួច កងពលរបស់អាត្មាបានបន្តវាយជាមួយកម្លាំងខ្មែរក្រហមនៅតំបន់ប៉ៃលិន ហើយអាត្មាបានត្រូវរបួស។ បន្ទាប់ពីព្យាបាលបានជាសះស្បើយហើយ អាត្មាក៏បានឈប់ធ្វើទាហាន។ នៅឆ្នាំ ២០១២ អាត្មាបានបួសជាព្រះសង្ឃម្តងទៀត និងបានគង់នៅវត្តថ្មដា រហូតមកដល់សព្វថ្ងៃ។



ជណ្តើរដែលត្រូវបានសាងសង់ឡើងអំពីថ្មសម្រាប់ពុទ្ធបរិស័ទ និងប្រជាជនដើរឡើងទៅវត្តថ្មដា។ (រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជុំ យ៉ាន់ ៖ គ្រូបង្រៀនកុមារ

**វី លក្ខិណា**



ជុំ យ៉ាន់ រស់នៅភូមិចន្ទ្រីទី១ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០។
(វី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជុំ យ៉ាន់ មានអាយុ៦៥ឆ្នាំ រស់នៅភូមិចន្ទ្រីទី១ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ជុំ យ៉ាន មានប្រពន្ធឈ្មោះ ស្បូយ ហើយ និងមានកូន៨នាក់ (ស្រី៥នាក់ ប្រុស៣នាក់)។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជុំ យ៉ាន់ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាគ្រូបង្រៀនកុមារនៅក្នុងភូមិចន្ទ្រី។

ជុំ យ៉ាន់បានរៀបរាប់ថា ខ្ញុំគឺជាជនជាតិស្ទៀង កាត់លាវ។ ឪពុករបស់ខ្ញុំឈ្មោះ ជុំ គឺជាជនជាតិស្ទៀង និងម្ដាយឈ្មោះ ផាន់ គឺជាជនជាតិលាវ។ សព្វថ្ងៃខ្ញុំនៅចេះនិយាយភាសាស្ទៀងខ្លះៗ ប៉ុន្តែមិនចេះនិយាយភាសាលាវទេ ព្រោះម្ដាយខ្ញុំមិនបានបង្រៀន។ ខ្ញុំមានបងប្អូន ៨នាក់ ស្លាប់ម្នាក់នៅសល់តែ៧នាក់តែប៉ុណ្ណោះ។

កាលពីតូចៗ ក្នុងភូមិរបស់ខ្ញុំអត់មានសាលារៀនទេ គឺខ្ញុំបានទៅរៀនក្នុងវត្តជាមួយព្រះសង្ឃ រហូតដល់មានរដ្ឋប្រហារទម្លាក់សម្ដេច ព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០។ ខ្ញុំនៅចាំថា ឪពុកម្ដាយខ្ញុំ និងប្រជាជននៅក្នុងភូមិចន្ទ្រីបានប្រកបការងារធ្វើស្រែចម្ការ និងដាំស្រូវវិលជុំ។ នៅសម័យនោះ ប្រជាជនមិនមានកម្មសិទ្ធិដីធ្លីច្បាស់លាស់ទេ គឺប្រជាជនទៅកាប់សម្អាតព្រៃស្បូវដើម្បីដាំស្រូវ។ បន្ទាប់ពីប្រមូលផលស្រូវបានហើយ ក៏បោះបង់ទីតាំងចាស់ចោល ទៅកាប់ឆ្ការព្រៃនៅទីតាំងថ្មីដើម្បីដាំស្រូវនៅរដូវបន្ទាប់ទៀត។ នៅចុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០ អ្នកភូមិចន្ទ្រី បានរកស៊ីលក់អង្ករឲ្យកងទ័ពវៀតកុង ដែលបានមកបោះទីតាំងនៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម ក្នុងភូមិសាស្ត្រចន្ទ្រី ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ នៅខណៈពេលនោះ មានការទម្លាក់គ្រាប់បែកច្រើននៅក្នុងភូមិរបស់ខ្ញុំ ដូច្នេះឪពុកម្ដាយរបស់ខ្ញុំបាននាំកូនៗចូលក្នុងត្រង់សេ ដែលបានជីកនៅជាប់ផ្ទះដើម្បីលាក់ខ្លួន។

បន្ទាប់ពីខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសាឆ្នាំ១៩៧៥ ខ្ញុំត្រូវបានមេភូមិចន្ទ្រី ចាត់តាំងឲ្យធ្វើជាគ្រូបង្រៀនក្មេងតូចៗប្រចាំនៅក្នុងភូមិ។ ការបង្រៀនកុមារ គឺមានរយៈពេលមួយម៉ោងគឺចាប់ផ្ដើមនៅម៉ោង៧ព្រឹក និងបញ្ចប់នៅម៉ោង៨ព្រឹក។ កុមារត្រូវរៀនសរសេរអក្សរ និងលេខនៅលើក្ដារឈ្នួនជាមួយដីស ដែលសុទ្ធតែពីដីក្រហម។ នៅក្នុងរបបខ្មែរ



ផ្លូវនៅក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០។ (រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រហម កុមារមានម៉ោងរៀនតិចជាងម៉ោងធ្វើការងារពលកម្ម។ ចំណែកបន្ទប់រៀនត្រូវបានសង់ឡើងអំពីកូនឈើប្រក់ស្លឹកទ្រាំង និងជញ្ជាំងក្តូល។

ក្រៅពីបង្រៀនកុមារតូចៗនៅពេលព្រឹករយៈពេលមួយម៉ោង ខ្ញុំត្រូវដឹកនាំកងកុមារដាំបន្លែ កើបអាចម៍គោ និងកាប់ដើមទន្ទ្រានខែត្រយកមកធ្វើជីដាក់ស្រែ បន្ទាប់មកទើបនាំកុមារៗឲ្យមកហូបបាយថ្ងៃត្រង់។ នៅពេលរសៀលខ្ញុំត្រូវដឹកនាំកងកុមារចុះជួយជញ្ជូនស្រូវកងចល័ត និងធ្វើការងារដែលស្រាលៗ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលដែលសមមិត្ត ហ៊ុន សែន ហៅ ណាល់ ដែលបច្ចុប្បន្នគឺសម្តេច ហ៊ុន សែន និងសហការីចំនួន៤នាក់ទៀត បានភៀសខ្លួនចេញទៅប្រទេសវៀតណាម ដើម្បីធ្វើការរៀបចំតស៊ូវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ (១៩ ៧៥-១៩៧៩) ខ្មែរក្រហមបានកោះហៅមេឃុំ មេភូមិ និងកម្មាភិបាលមួយចំនួនទៀតទៅរៀនសូត្រ ហើយបានបាត់ខ្លួនរហូត។

បន្ទាប់មកខ្មែរក្រហមបានបញ្ជូនកងទ័ព និងកម្មាភិបាលមជ្ឈិមមកជម្លៀសប្រជាជនទាំងអស់ចេញពីស្រុកត្រមូងឲ្យទៅនៅស្រុកស្នួល ខេត្តក្រចេះវិញ។ ចំណែកខ្ញុំបានឈប់បង្រៀនកងកុមារតាំងពីពេលនោះមក។

កងទ័ព និងកម្មាភិបាលដែលដឹកនាំនៅស្រុកស្នួលបានហៅប្រជាជនដែលជម្លៀសមកពីស្រុកត្រមូងថា គឺជាមនុស្សដែលមាន ក្បាលយួន ខ្លួនខ្មែរ។ ប្រជាជនដែលជម្លៀសមកពីស្រុកត្រមូងបានប្រឈមនឹងការលំបាកវេទនាខ្លាំង ដោយសារខ្មែរក្រហមបង្ខំឲ្យធ្វើពលកម្មធ្ងន់ធ្ងរ និងមិនមានអាហារហូបចុកគ្រប់គ្រាន់។ ប្រជាជនជាច្រើនបានស្លាប់ដោយសារអត់អាហារ និងធ្វើការហួសកម្លាំង។

ប្រជាជន និងអតីតកម្មាភិបាលដែលជម្លៀសមកពីស្រុកត្រមូង បានព្យាយាមលាក់ប្រវត្តិរបស់ខ្លួន នៅកម្មាភិបាលដឹកនាំមូលដ្ឋាននៅស្រុកស្នួលសួរពីប្រវត្តិរូប ហើយភាគច្រើនបានឆ្លើយថា ខ្លួនគឺជាប្រជាជនធម្មតា ប្រធ្វើការនៅកងចល័ត។ ខ្ញុំបានបោះសៀវភៅចោលដើម្បីកុំឲ្យកម្មាភិបាលនៅមូលដ្ឋានដឹងថា ខ្ញុំចេះអក្សរ។ ចំណែកប្រជាជនដែលជម្លៀសមកជាមួយគ្នាក៏មិនបានរាយការណ៍ពីប្រវត្តិរបស់ខ្ញុំប្រាប់កម្មាភិបាលមូលដ្ឋានដែរ ដូច្នេះយើងបានរួចផុតពីការតាមដានរបស់ខ្មែរក្រហម។

នៅពេលខ្ញុំរស់នៅសហករណ៍ក្នុងស្រុកស្នួល ខ្ញុំទទួលរបបអាហារ គឺមានតែកន្ទក់ប៉ុណ្ណោះ។ របបកន្ទក់នេះត្រូវបានចែកសម្រាប់តែអ្នកដែលទៅធ្វើការប៉ុណ្ណោះ ចំណែក អ្នកមិនបានទៅធ្វើការ គឺមិនទទួលបានឡើយ។ នៅពេលនោះ ឪពុកម្ដាយរបស់ខ្ញុំបានស្លាប់ ដោយសារតែមិនមានអាហារហូបចុកគ្រប់គ្រាន់។ ចំណែកខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងចល័តដែលមានសមាជិកប្រហែលមួយពាន់នាក់។ កម្មាភិបាលដឹកនាំកងចល័តនោះ គឺជាមនុស្សឃោរឃៅ បានសម្លាប់មនុស្សប្រុសស្រីពីរនាក់ឈ្មោះខាត់ និងឈ្មោះច័ន្ទ នៅមុខកងចល័តទាំងអស់ ដោយប្រាប់ថា ពីរនាក់នេះ គឺជាជនក្បត់។ បន្ទាប់ពីសម្លាប់អ្នកទាំងពីរហើយ ប្រធានកងចល័តនោះបានយកសាកសពទៅកប់ក្នុងរណ្ដៅតែមួយ។

នៅពេលដែលកងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកដល់ស្រុកស្នួល នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនពីស្រុកស្នួលមកទីរួមខេត្តក្រចេះវិញ។ បន្ទាប់មកខ្មែរក្រហមបានដឹកប្រជាជនតាមកប៉ាល់ពីខេត្តក្រចេះមកស្រុកស្ទឹងត្រង់ ភូមិភាគកណ្ដាល និងបានបញ្ជូនបន្តទៅស្រុកចម្ការលើ។

ខ្ញុំបានស្នាក់នៅស្រុកចម្ការលើរយៈពេលប្រហែល ៧ ថ្ងៃ ក៏មានយន្តហោះវៀតណាមបានហោះបន្ទាបខ្លួន និងប្រកាសប្រាប់ប្រជាជនដែលកំពុងលើកទំនប់ថា បងប្អូននៅស្រុកណាត្រូវត្រឡប់ទៅស្រុកនោះវិញ។ ខ្ញុំត្រេកអរយ៉ាងខ្លាំង ព្រោះខ្ញុំតែងតែបន់ស្រន់ក្នុងចិត្តដើម្បីបានត្រឡប់ទៅស្រុកកំណើតវិញ។ នៅពេលរៀបនឹងត្រឡប់មកផ្ទះវិញ យោធាខ្មែរក្រហមបានស្ទាក់រាំងផ្លូវ ប៉ុន្តែសំណាងល្អកងទ័ពវៀតណាមមកដល់។ កងទ័ពវៀតណាមបានអមដំណើរប្រជាជនឲ្យឆ្លងផុតពីស្រុកចម្ការលើ ទើបខ្ញុំនិងប្រជាជនដែលធ្លាប់រស់នៅក្នុងភូមិជាមួយគ្នាបន្តដំណើរមកស្រុកកំណើតវិញ។ ខ្ញុំធ្វើដំណើររយៈពេលប្រហែលមួយសប្ដាហ៍ទើបបានមកដល់ផ្ទះវិញ ។

ពេលត្រឡប់មកដល់ភូមិកំណើតវិញ ខ្ញុំបានចូលបម្រើការងារសន្តិសុខ ដើម្បីការពារសុវត្ថិភាពក្នុងភូមិ។

ខ្ញុំរៀបការនៅដើមឆ្នាំ១៩៨០ និងប្រកបរបរដាំស្រូវ និងធ្វើចម្ការ។ នៅចន្លោះឆ្នាំ១៩៨៤-១៩៨៥ ខ្ញុំត្រូវបានជ្រើសរើសជាកងទ័ពការពារពលករ ក-៥។ ខ្ញុំបានបម្រើការងារនៅក្នុងអង្គភាពវិទ្យុទាក់ទង។ អង្គភាពរបស់ខ្ញុំធ្លាប់ប្រយុទ្ធជាមួយកងយោធាខ្មែរក្រហម និងទាហានប៉ារ៉ា នៅខេត្តបន្ទាយមានជ័យបានម្ដង។ បន្ទាប់ពីខ្ញុំបានចប់បេសកកម្ម ក៏បានត្រឡប់មករស់ស្រុកកំណើតរហូតមកដល់សព្វថ្ងៃ។

# ហ៊ុយ យ៉ាន ៖ អតីតយុទ្ធនារីខ្មែរក្រហម

***មេក វិន***

ហ៊ុយ យាន មានអាយុ៦២ឆ្នាំ មានទីកន្លែងកំណើតនៅភូមិត្នោតជុំ ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ យាន បានរៀបរាប់ពីដំណើរជីវិតតស៊ូរបស់ខ្លួនថា «នៅក្នុងឆ្នាំ១៩៧០ ខ្ញុំបានបោះបង់ការសិក្សានៅត្រឹមថ្នាក់ទី៨ ដោយសារតែប្រទេសចាប់ផ្តើមធ្លាក់ក្នុងសង្គ្រាម។ ក្នុងចន្លោះឆ្នាំ១៩៧០-១៩៧៣ ខ្ញុំរស់នៅស្រុកកំណើត និងជួយធ្វើស្រែចម្ការឪពុកម្តាយរបស់ខ្ញុំ។ លុះដល់ឆ្នាំ១៩៧៤ ខ្ញុំបានសម្រេចចិត្តចូលបម្រើការងារជាកងទ័ពនារីរបស់ខ្មែរក្រហម ដែលត្រូវចល័តទៅគ្រប់ទីកន្លែង។ ចាប់តាំងពីពេលនោះមកខ្ញុំត្រូវបែកឆ្ងាយពីគ្រួសារ។ ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវក្រោកពីព្រលឹមដើម្បីទៅកាប់ដីចម្ការដាំដំណាំ ស្ទូង និងប្រូតស្រូវ ចំណែកការហូបចុកមិនខ្វះខាតទេនៅពេលនោះ។ មិនយូរប៉ុន្មាន ខ្ញុំទទួលបានការបង្ហាត់បង្រៀនពីវិធីសាស្ត្រធ្វើសឹកសង្គ្រាម។

លុះដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅនៅទួលគោក នៅពេលដែលយោធា ខ្មែរក្រហមវាយរំដោះបានទីក្រុងភ្នំពេញ។ បន្ទាប់មក កងពល ៩២០ របស់ខ្ញុំ ត្រូវបានផ្លាស់ឲ្យទៅឈរជើងនៅមណ្ឌលគិរីវិញ។ នៅទីនោះខ្មែរក្រហមបានប្រើឲ្យខ្ញុំធ្វើស្រែ និងធ្វើចម្ការ រហូតដល់ឆ្នាំ១៩៧៩។ ការរស់នៅទីនោះហាក់ដូចជាមានភាពល្អប្រសើរ ហើយការហូបចុករបស់ខ្ញុំទទួលបានរបបអាហារក្នុងមួយថ្ងៃបីពេល។ ការរស់នៅរបស់ខ្ញុំគឺត្រូវមានវិន័យ និង ទម្លាប់ល្អ ហើយក៏មិនមានការវាយធ្វើបាប ឬចាប់បង្ខំដែរ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយលុកចូលមកខេត្តមណ្ឌលគិរី។ ខ្ញុំចាំបានថា កាលណោះ



*ហ៊ុយ យាន មានអាយុ៦២ឆ្នាំ មានស្រុកកំណើតនៅភូមិត្នោតជុំ ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ហ៊ុយ យាន បានផ្តល់បទសម្ភាសន៍ដល់ មេក វិន អំពីជីវិតរបស់គាត់ជាយុទ្ធនារីរបស់ខ្មែរក្រហម ដែលត្រូវចល័តទៅគ្រប់ទីកន្លែងរហូតមកដល់ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (មេក វិន/ជ្ឈមណ្ឌលឯកសារកម្ពុជា)*

កងពល៩២០ របស់ខ្ញុំ មានកម្លាំងជាង៣០០នាក់ រួមជាមួយប្រជាជនជាច្រើននាក់ទៀត ដែលបានភៀសខ្លួនចូលទៅក្នុងព្រៃ។ យើងបានបន្តរស់នៅក្នុងព្រៃដោយគ្មានអាហារហូបចុកគ្រប់គ្រាន់។ ជារៀងរាល់ថ្ងៃយើង

តែងតែនាំគ្នាដើររកដំឡូងព្រៃដើម្បីបរិភោគ ហើយសូម្បីតែអំបិលក៏គ្មានហូបដែរ។ ជីវិតរបស់ខ្ញុំ គឺពិតជាវេទនាខ្លាំងណាស់រយៈពេលដែលរស់នៅក្នុងព្រៃ។

នៅឆ្នាំ១៩៨០ តាទេម បានចាត់កងកម្លាំងឲ្យមកទទួលប្រជាជនដែលរស់នៅក្នុងព្រៃស្ថិតនៅខេត្តមណ្ឌលគិរីទាំងអស់ ឲ្យមករស់នៅលើភ្នំដងរែក។ កងកម្លាំងរបស់តាទេម បាននិយាយថា លុះត្រា បងប្អូន ពុក ម៉ែ រួមទាំងប្រជាជនទាំងអស់ព្រមទៅរស់នៅលើភ្នំដងរែកទើបបងប្អូនមានសុវត្ថិភាព មានបាយហូប និងរួចផុតពីការគំរាមកំហែងពីកងទ័ពវៀតណាម។ ខ្ញុំរួមជាមួយប្រជាជនជាច្រើននាក់ទៀត បានសម្រេចចិត្តធ្វើដំណើរទៅតាមកងកម្លាំងរបស់ តាទេម ទៅរស់នៅលើភ្នំដងរែក។

ខ្ញុំបានចំណាយពេល២ខែ ធ្វើដំណើរទើបទៅដល់ភ្នំដងរែក។ ការធ្វើដំណើររបស់ខ្ញុំបានប្រឈមនឹងគ្រោះថ្នាក់ជាច្រើន ព្រោះកងទ័ពវៀតណាមចាំវាយប្រហារមកលើកងកម្លាំងរបស់ តាទេម និងប្រជាជនដែលរួមដំណើរទាំងនោះ។ ប្រជាជនមួយភាគតូចដែលបានរួមដំណើរឆ្ពោះទៅកាន់តំបន់ភ្នំដងរែក ត្រូវបានស្លាប់ដោយសារការវាយប្រហារពីកងទ័ពវៀតណាម។ ខ្ញុំចាំបានថា កាលណោះ ប្រសិនបើមានអ្នកស្លាប់នៅតាមផ្លូវដែលកំពុងធ្វើដំណើរ សាកសពទាំងនោះ ត្រូវទុកចោលដោយសារខ្លាចកងទ័ពវៀតណាមមកទាន់ ហើយម្យ៉ាងទៀតកម្លាំងម្នាក់ៗ ក៏កាន់តែខ្សោយទៅៗ ដោយសារការហូបចុកមិនគ្រប់គ្រាន់។

នៅតាមផ្លូវខ្ញុំបានរស់ជីវិតដោយសារការហូបដំឡូងព្រៃ។ មិនយូរប៉ុន្មានខ្ញុំ និងប្រជាជនដែលនៅសេសសល់បានបន្តដំណើរកាត់តាមខេត្តព្រះវិហារទៅដល់ភ្នំដងរែកដោយសុវត្ថិភាព។ ខ្ញុំរស់នៅច្រក១០០១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន។ ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំង ហាក់ដូចបានកើតជាថ្មីម្តងទៀត។ ខ្ញុំទទួលបានរបបអាហារជារៀងរាល់អាទិត្យ និងបានហូបចុកគ្រប់គ្រាន់ ព្រមទាំងមានពេទ្យចាំព្យាបាលអ្នកជំងឺ។

នៅទីនោះ ខ្ញុំត្រូវដឹកជញ្ជូនគ្រាប់ និងអង្ករ ទៅផ្តល់ឲ្យយោធាខ្មែរក្រហមនៅខាងក្រោមភ្នំ។ ខ្ញុំធ្វើការនៅកងដឹកជញ្ជូននៅតំបន់១០០១ រហូតដល់ឆ្នាំ១៩៨៥ ក៏មានគ្រួសារ ដោយប្តីរបស់ខ្ញុំគឺជាយោធាក្រោមការដឹកនាំរបស់ សុន សេន។ ចាប់តាំងពីពេលនោះមកខ្ញុំឈប់នៅកងដឹកជញ្ជូនទៀតហើយ គឺខ្ញុំរស់នៅជាប្រជាជនប្រកបរបរធ្វើស្រែ ដាំដំណាំបន្តិចបន្តួចទុកសម្រាប់ហូបក្នុងគ្រួសារ។ សុន សេន បានជួយឧត្ថម្ភ អង្ករ អំបិល ប៊ីចេង ត្រីខ នំចំណី សម្រាប់ហូបគ្រប់គ្រាន់។

មិនយូរប៉ុន្មាន កងទ័ពវៀតណាមបានវាយចូលមកដល់ច្រក១០០១។ ខ្ញុំនិងប្តីបានសម្រេចចិត្តចាកចេញពីច្រក១០០១ ទៅរស់ជំរំអូត្រាវវិញ។ បន្ទាប់មក ខ្ញុំនិងប្រជាជនផ្សេងទៀត បានសម្រេចចិត្តចុះមករស់នៅតំបន់អន្លង់វែង ដែលពីមុនគឺភូមិចម្ការចេក ហើយបច្ចុប្បន្នប្តូរឈ្មោះមកភូមិសន្តិភាពវិញ។ ខ្ញុំចាំបានថា នៅក្នុងឆ្នាំ១៩៩១ នៅតំបន់អន្លង់វែង មិនទាន់មានអ្នកលក់ដូរទំនិញ និងមិនទាន់អនុញ្ញាតឲ្យចាយលុយទេ គឺប្រជាជនត្រូវបើកស្បៀងអាហារពីខ្មែរក្រហម។ មួយរយៈក្រោយមក កងទ័ពវៀតណាម បានវាយកាន់កាប់តំបន់អន្លង់វែង ខ្ញុំនិងគ្រួសាររបស់ខ្ញុំបានគេចខ្លួនទៅរស់នៅតំបន់ផ្សេងៗក្នុងស្រុកអន្លង់វែង។ រហូតដល់ឆ្នាំ១៩៩៧ បានខ្ញុំបានរត់ភៀសខ្លួនទៅនៅជំរំកូណាយ ក្នុងទឹកដីថៃ។ តាម៉ុក គឺជាអ្នកគ្រប់គ្រង និងជាអ្នកផ្គត់ផ្គង់ស្បៀងអាហារដល់ប្រជាជននៅជំរំ។ នៅទីនោះ ប្រជាជនចាប់ផ្តើមចាយលុយ ដូច្នេះខ្ញុំបានដើរទិញស្បូវដើម្បីក្រងលក់ឲ្យឈ្មួញថៃក្នុងតម្លៃសមរម្យ។ ខ្ញុំរស់នៅជំរំកូណាយបានរយៈពេលមួយឆ្នាំ។ នៅឆ្នាំ១៩៩៨ តាម៉ុក បានអនុញ្ញាតឲ្យប្រជាជនចុះមករស់នៅស្រុកអន្លង់វែងវិញ ដោយឲ្យទៅនៅតាមភូមិចាស់ពីមុនមក។ ចាប់តាំងពីពេលនោះមកប្រជាជនទាំងអស់ដែលចុះមកពីជំរំកូណាយ បានចាប់ផ្តើមធ្វើផ្ទះថ្មី រៀបចំរានដីធ្លីធ្វើស្រែ ចម្ការ ដាំដំណាំ ចិញ្ចឹមគោ ក្របី សម្រាប់ផ្គត់ផ្គង់ជីវិតប្រចាំថ្ងៃរៀងៗខ្លួន។

# សេង ហុក ៖ ខ្ញុំបានរស់ជីវិតពីសង្គ្រាមរ៉ាំរ៉ៃ

**ស្លូត វិចិត្រ**



*សេង ហុក ភេទប្រុស អាយុ៦៦ឆ្នាំមានទីកន្លែងកំណើតនៅភូមិឈើទាលជ្រុំ ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ សេង ហុក បានផ្តល់បទសម្ភាសន៍ដល់ ស្លូត វិចិត្រ អំពីជីវិតរបស់គាត់ដែលបានបួសជាសង្ឃនៅក្នុងខេត្តកំពង់ស្ពឺ និងក្រោយមកចូលធ្វើយោធានៅក្នុងកងពល៨០១របស់ខ្មែរក្រហម ហើយចុងក្រោយបានមករស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ស្លូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

សេង ហុក ភេទប្រុស អាយុ៦៦ឆ្នាំមានទីកន្លែងកំណើតនៅភូមិឈើទាលជ្រុំ ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

សេង ហុក បានរៀបរាប់អំពីការតស៊ូរបស់ខ្លួនចាប់តាំងពីគ្រាដំបូងដែលខ្លួនបានបួសជាសង្ឃនៅក្នុងខេត្តកំពង់ស្ពឺ រហូតបានក្លាយជាយោធានៅក្នុងកងពល ៨០១ របស់ខ្មែរក្រហមថា នៅក្នុងឆ្នាំ១៩៧១ ខ្ញុំបានបួសជាសង្ឃនៅវត្តថ្មហោង ក្នុងខេត្តកំពង់ស្ពឺ។ កាលណោះខ្ញុំបានឈប់រៀនដោយសារស្រុកទេសមានភាពចលាចល បន្ទាប់មកខ្ញុំបានបួសជាព្រះសង្ឃ។ ជីវិតរបស់ខ្ញុំបានផ្សារភ្ជាប់ទៅនឹងព្រះពុទ្ធសាសនារហូតដល់ឆ្នាំ១៩៧៣ ទើបខ្មែរក្រហមបានជម្រឹកខ្ញុំ និងព្រះសង្ឃជាច្រើនអង្គទៀតឲ្យចូលបម្រើយោធាប្រឆាំងនឹងរបប លន់ នល់។ ដំបូងខ្មែរក្រហមបានបើកអង្គសន្និបាតមួយ និងឲ្យព្រះសង្ឃឡើងប្តេជ្ញាចិត្តពីការលះបង់ និងការរួមចំណែកក្នុងការជួយរំដោះជាតិមាតុភូមិរបស់ខ្លួនចេញពីការគាបសង្កត់ពីរបប លន់ នល់។ ខ្ញុំយល់ថា ការបួសជាព្រះសង្ឃ គឺដើម្បីសន្សំបុណ្យកុសល និងការកសាងអំពើល្អ ប៉ុន្តែផ្ទុយទៅវិញ

អ្វីៗក៏ត្រូវបានផ្លាស់ប្តូរទាំងស្រុង នៅពេលខ្មែរក្រហមបានចូលមកដល់ភូមិរបស់ខ្ញុំ។

បន្ទាប់ពីអន្តសន្និបាតចប់ ខ្មែរក្រហមបានបញ្ជូនខ្ញុំ និងកងកម្លាំងមួយចំនួនទៅកាន់តំបន់ឈើជ្រុងនៃខេត្តកំពង់ស្ពឺរយៈពេលកន្លះខែ ដើម្បីហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធា។ ខ្ញុំរស់នៅក្នុងខេត្តកំពង់ស្ពឺរហូតដល់ចុងឆ្នាំ១៩៧៥ ទើបខ្មែរក្រហមបានបញ្ជូនខ្ញុំទៅកាន់ខេត្តក្រចេះ ដើម្បីវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម។ ខ្ញុំចាំបានថា កងទ័ពរបស់ខ្មែរក្រហម បានស្លាប់ច្រើនណាស់ ហើយកងទ័ពវៀតណាមក៏បានបាត់បង់ជីវិតនៅក្នុងពេលវាយប្រយុទ្ធដែរ។ ពីមួយថ្ងៃទៅមួយថ្ងៃ សមរភូមិខេត្តក្រចេះ បានចាប់ផ្តើមតានតឹងឡើងៗ និងបើកការវាយប្រយុទ្ធគ្នាឥតឈប់ឈរ។ ក្រោយមក កងកម្លាំងរបស់ខ្មែរក្រហមបានចាប់ផ្តើមចុះខ្សោយទៅៗ ខណៈដែលកងកម្លាំងវៀតណាមចាប់ផ្តើមកើនឡើងជាលំដាប់។ ដោយសារកងទ័ពវៀតណាមមានចំនួនច្រើនលើសលប់ ទើបបណ្តាលឲ្យកងកម្លាំងរបស់ខ្ញុំចាប់ផ្តើមបែកខ្ញែកខ្ចាត់ខ្ចាយ និងរត់ចូលទៅសម្ងំលាក់ខ្លួនក្នុងព្រៃនៅដើមឆ្នាំ១៩៧៩។

ជីវិតរបស់ខ្ញុំនិងកងកម្លាំងខ្មែរក្រហមនៅពេលនោះ គឺក្រខ្សត់និងលំបាកខ្លាំងណាស់។ យើងមានតែវ៉ាល់ឡមួយ និងសម្ភារបន្តិចបន្តួចប៉ុណ្ណោះនៅជាប់នឹងខ្លួន។ ខ្ញុំបានកាន់កាំភ្លើងមួយដើម និងមានគ្រាប់ប្រមាណតែ៥គ្រាប់ប៉ុណ្ណោះនៅជាប់នឹងបង់ដើម្បីការពារខ្លួននៅពេលទាល់ច្រកៗ ជារឿយៗខ្ញុំដក់បារីមូស្លឹកសង្កែរួចឃ្លាំមើលហេតុការណ៍ទាំងឡាយដែលកើតមានឡើងនៅជុំវិញខ្លួន។ ខ្ញុំនឹកស្រមៃថា ជីវិតរបស់ខ្ញុំមិនគួរជួបការលំបាកបែបនេះទេ។

ខ្ញុំបានពឹងផ្អែកទាំងស្រុងទៅលើព្រៃឈើ។ ជារៀងរាល់ថ្ងៃ ខ្ញុំបាននាំគ្នាជីកដំឡូងព្រៃ និងមើមក្តួចមកធ្វើជាអាហារ។ ពេលខ្លះ ខ្ញុំបានធ្វើដំណើរចូលទៅក្នុងភូមិដែលមានប្រជាជនរស់នៅដើម្បីសុំស្បៀងអាហារ ផ្លែចេក និងផលដំណាំផ្សេងៗ យកមកហូបនៅក្នុងក្រុម។ យើងមានអង្ករចំនួន៥កំប៉ុង ដែលយើងបានលាក់ទុកជាយូរមកហើយ គឺសម្រាប់តែបរិភោគនៅពេលណាដែលចាំបាច់ប៉ុណ្ណោះ ដូចជា នៅពេលឈឺថ្កាត់ ឬហូបអ្វីលែងកើត។ ដោយសារការអត់ឃ្លានខ្លាំងពេក នៅពេលប្រយុទ្ធម្តងគ្នាម្តងៗ និងនៅពេលគ្រាប់ផ្លោងធ្លាក់ចូលទៅក្នុងបឹង ខ្ញុំបានប្តូរជីវិតចុះក្នុងបឹងនោះ ដើម្បីហែលចាប់ត្រីមកដុតធ្វើជាអាហារ។

ពេលខ្លះ ខ្ញុំបានយករបបអាហារពីមិត្តរួមក្រុមដែលបានស្លាប់បាត់បង់ជីវិតនៅពេលប្រយុទ្ធក្នុងសមរភូមិមកហូបចម្អែតក្រពះ ដើម្បីរួចផុតពីការដាច់ពោះស្លាប់។ មុនពេលយប់ងងឹតចូលមកដល់ យើងបាននាំគ្នាកាប់ដើមឫស្សី រួចជ្រៀកជាចម្រៀកតូចៗ ដើម្បីធ្វើជាអគ្រើងសម្រាប់ដេកបណ្តោះអាសន្ន។ ខ្ញុំកម្រស្នាក់នៅទីកន្លែងណាមួយឲ្យលើសពីពីរយប់ណាស់ បើមិនដូច្នោះទេ កងទ័ពវៀតណាមនឹងវាយប្រហារយើង និងអាចបណ្តាលឲ្យស្លាប់។ កងកម្លាំងនៅក្នុងអង្គភាពរបស់ខ្ញុំប្រមាណមួយពាន់នាក់ បានធ្វើដំណើរដោយថ្មើរជើងឆ្ពោះទៅខេត្តស្ទឹងត្រែង ដោយឆ្លងកាត់ទឹកទន្លេមេគង្គ។ យើងមិនមានទូកសម្រាប់ជិះឆ្លងទេនៅពេលនោះ។ យើងបានយកដើមឫស្សីមកចងផ្គួបជាបាច់ ដើម្បីតោងឆ្លងទៅកាន់ត្រើយម្ខាងទៀត។ ការឆ្លងទឹក គឺប្រឈមនឹងគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារកងកម្លាំងភាគច្រើនរបស់យើងមិនចេះហែលទឹក ហើយទឹកនៅពេលនោះ គឺហូរខ្លាំងណាស់។ កងកម្លាំងប្រមាណជិតពាក់កណ្តាលនៅក្នុងអង្គភាពរបស់ខ្ញុំបានលង់ស្លាប់បាត់បង់ជីវិតគួរឲ្យសង្វេគ។ កងកម្លាំងដែលនៅរស់ ហាក់មានភាពទ្រុឌទ្រោម ប៉ុន្តែយើងនៅតែអាចធ្វើដំណើរទៅមុខបាន។ យើងបានបន្តដំណើរទៅមុខទាំងលំបាកលំបិនដើម្បីឲ្យបានដល់សមរភូមិក្នុងខេត្តស្ទឹងត្រែង។

យើងធ្វើដំណើរជាច្រើនសប្តាហ៍ទើបទៅដល់ខេត្តស្ទឹងត្រែង ហើយបានរស់ទីនោះអស់រយៈពេល១ឆ្នាំ។ ក្រោយមកថ្នាក់លើ បានប្តូរអង្គភាពរបស់ខ្ញុំឲ្យទៅកាន់មុំបី ឬតំបន់១០០១។ នៅទីនោះ ខ្មែរក្រហមបានផ្គត់ផ្គង់ស្បៀងអាហារ និងបំពាក់បំប៉នខាងផ្នែកយោធាដល់យើងដើម្បីត្រៀមវាយបកទៅកងទ័ពវៀតណាមនៅសមរភូមិខាងក្នុងប្រទេស។ រាល់ពេលចេញទៅសមរភូមិខាងក្នុងប្រទេសម្តងៗ យើងបានវាយប្រយុទ្ធផង និងដើរធ្វើគោលនយោបាយទាក់ទាញកម្លាំងប្រជាជនឲ្យចូលក្នុង

ចលនារបស់យើងផង ពីព្រោះកងកម្លាំងរបស់យើងចាប់ផ្តើមថយចុះបណ្តើរៗ។

ប្រជាជនជាច្រើននាក់បានមកតាមយើង ដោយសារការភ័យខ្លាចចំពោះកងទ័ពវៀតណាម ដែលបន្តរាតត្បាតនៅក្នុងភូមិស្ថានដែលខ្លួនរស់នៅ។ ជាពិសេសប្រជាជនមួយចំនួនបានមើលឃើញអំពីភាពប្រសើរឡើងវិញនៃការរស់នៅ និងការទទួលបានស្បៀងអាហារនៅតាមបណ្តោយព្រំដែនក្នុងតំបន់ខ្មែរក្រហម។ ក្រុមរបស់ខ្ញុំបានផ្សព្វផ្សាយការប្រមែរប្រមូលប្រជាជនទៅគោលនយោបាយដែលបំផុសនូវកំហឹង ចំពោះការឈ្លានពានរបស់កងទ័ពវៀតណាមមកលើប្រទេសកម្ពុជា។ មកទល់នឹងឆ្នាំ១៩៨៦ កងកម្លាំងរបស់ខ្ញុំបានចូលទៅរស់នៅក្នុងទឹកដីថៃមួយរយៈ ព្រោះកងទ័ពវៀតណាមបានវាយរុញច្រានយើងឲ្យចេញពីតំបន់១០០១។ ក្រោយមក ខ្មែរក្រហមក៏ចាប់ផ្តើមរៀបចំផែនការដឹកជញ្ជូនរំសេវបុប្ផា មកកាន់តំបន់អន្លង់វែង ដើម្បីវាយរំដោះយកទីតាំងឈរជើងរបស់ខ្លួនដែលបានបាត់បង់ទៅ។

កងកម្លាំងរបសខ្ញុំបានដឹកជញ្ជូនរំសេវ ១០០បន្ទុះក្នុងម្នាក់ ដើម្បីទៅដាក់នៅក្នុងឃុងសាំងធំមួយៗនៅអន្លង់វែង។ បន្ទាប់មក យើងបានបំផ្ទុះឃុងសាំងនោះតាមរយៈខ្សែភ្ជាប់វែងមួយនៅពេលកងទ័ពវៀតណាមធ្វើដំណើរមកដល់។ កងទ័ពវៀតណាមមួយចំនួនបានស្លាប់ដោយសារការដាច់ទងសួត ឬបេះដូង នៅពេលរំសេវនោះបានផ្ទុះកក្រើកនៅលើដី។ យើងបានរំដោះទឹកដីអន្លង់វែងពីការគ្រប់គ្រងរបស់កងទ័ពវៀតណាមនៅដើមឆ្នាំ១៩៩០។ ក្រោយមក យើងបានមកបោះទីតាំងឈរជើងនៅទីនោះសាជាថ្មី។

ការគ្រប់គ្រងរបស់ តាម៉ុក នៅតំបន់អន្លង់វែងនៅពេលនោះ ហាក់បានផ្តល់នូវភាពកក់ក្តៅទៅលើការសាមគ្គីរវាងយុទ្ធមិត្តនៃកងយោធាខ្មែរក្រហមដើម្បីវាយរុញច្រានកងទ័ពវៀតណាមចេញពីទឹកដីអន្លង់វែង។ តាម៉ុក បានផ្គត់ផ្គង់ស្បៀងអាហារ និងថ្នាំពេទ្យសម្រាប់កងទ័ព និងប្រជាជនបានល្អប្រសើរឡើងវិញ។ ប៉ុន្តែខ្ញុំអស់ជំនឿបន្តិចម្តងៗនៅពេល តាម៉ុក បានបែងចែកប្រជាជនមួយចំនួនចេញជាសមាសភាពល្អ និងមិនល្អ។ ខ្ញុំបានរស់ជីវិតពីសង្គ្រាមរ៉ាំរ៉ៃ ហើយនៅពេលសង្គ្រាមត្រូវបានបញ្ចប់នៅចុងឆ្នាំ១៩៩៨ ខ្ញុំបានកសាងជីវភាពរស់ឯកជនពីបាតដៃទទេ រហូតមានភាពប្រសើរមកដល់ពេលបច្ចុប្បន្ននេះ។



អតីតទីតាំងការដ្ឋានដឹកជញ្ជូនរបស់ តាម៉ុក ឬ ឃ្លាំងកណ្តាល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទៀន នី ៖ ដំណើរជីវិតមកកាន់ស្រុកអន្លង់វែង

ហ៊ាន ពិសី



ទៀន នី អាយុ៧០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិខ្ពប ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៀន នី ភេទប្រុស អាយុ៧០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិខ្ពប ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។ ទៀន នី បានរៀបរាប់ពីជីវិតជាយោធារបស់គាត់ ដែលបានបម្រើឲ្យចលនាបដិវត្តន៍ខ្មែរក្រហមរហូតមកដល់តំបន់អន្លង់វែង ដូចខាងក្រោម៖

ខ្ញុំគឺជាក្មេងកំព្រា តាំងតែពីខ្ញុំអាយុ៧ឆ្នាំ។ លុះខ្ញុំអាយុបាន១៦ឆ្នាំ ខ្ញុំបានសម្រេចចិត្តបួសជាព្រះសង្ឃក្នុងខេត្តកណ្តាល។ បន្ទាប់ពីបួសបាន៤ព្រះវស្សា ខ្ញុំបានលាចាកសិក្ខាបទនៅពេលដែលមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុនៅឆ្នាំ១៩៧០។ ដោយសារមានការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ ឲ្យប្រជាជនទាំងអស់ដែលគាំទ្រព្រះអង្គចូលតស៊ូក្នុងព្រៃម៉ាគី ខ្ញុំក៏សម្រេចចិត្តចូលបម្រើយោធាជាមួយខ្មែរក្រហមនៅពេលនោះដែរ។ យើងបានតស៊ូប្រយុទ្ធជាច្រើនឆ្នាំតទល់ជាមួយទាហាន លន់ នល់ រហូតដល់ទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥។ នៅពេលនោះខ្ញុំគិតថាការតស៊ូរបស់ខ្ញុំបានឈានចូលដល់ការបញ្ចប់សង្គ្រាម ប៉ុន្តែអ្វីៗបានផ្ទុយទៅនឹងការគិតរបស់ខ្ញុំ ហើយក៏ជាការចាប់ផ្តើមនៃរបបកុម្មុយនីស្តដែរ។

បន្ទាប់មក ខ្មែរក្រហមបានបញ្ជូនខ្ញុំមកកាន់ទីក្រុងភ្នំពេញ ដើម្បីការពារ និងរៀបចំសណ្តាប់ធ្នាប់នៅក្នុងទីក្រុងឡើងវិញ។ នៅទីនោះ មិនមានប្រជាជនរស់នៅទេ ហើយទីក្រុងទាំងមូលត្រូវបានផ្លាស់ប្តូរទាំងស្រុង។ ខ្ញុំបានរស់នៅទីក្រុងភ្នំពេញរហូតដល់ឆ្នាំ១៩៧៦ ថ្នាក់លើក៏បានបញ្ជូនខ្ញុំទៅខេត្តមណ្ឌលគិរី ដើម្បីបង្កបង្កើនផល។ នៅទីនោះ ខ្ញុំបានជួបការលំបាក ដោយសារធ្វើការងាររហូសកម្លាំង និងជួបភាពអត់ឃ្លាន។ ខ្ញុំពុំមានគោក្របី ដើម្បីភ្ជួរស្រែនោះទេ។ ខ្ញុំបានប្រើប្រាស់ចបកាប់ដីដើម្បីធ្វើស្រែ។ អង្គភាពរបស់ខ្ញុំត្រូវរកស្បៀងអាហារដោយខ្លួនឯង ដោយមិនទទួលបានការផ្គត់ផ្គង់ពីភ្នំពេញឡើយ។ ប៉ុន្តែអង្គភាពរបស់ខ្ញុំបានទទួលថ្នាំពេទ្យជំនួសវិញ។ យើងបានធ្វើស្រែនៅទីនោះអស់ជាច្រើនឆ្នាំ និងហត់នឿយយ៉ាងខ្លាំង។ ជារៀងរាល់ថ្ងៃ ខ្ញុំទទួលបានរបបអាហារពីរពេល គឺថ្ងៃត្រង់ និងល្ងាច។ ទោះជាយ៉ាងនេះក្តី ជារឿយៗ ខ្ញុំទទួលបាន ពោត និងដំឡូង មុនពេលចេញទៅធ្វើការនៅពេលព្រឹក។ ក្រៅពីនោះខ្ញុំទទួល

បានរបបបាយ ឬបបរមួយកូនចានតូចប៉ុណ្ណោះ។ ខ្ញុំហូបមិនឆ្អែតទេ ប៉ុន្តែក៏មិនហ៊ានប្រកែកតវ៉ាដែរ។ នៅមណ្ឌលគិរី ប្រជាជនបានស្លាប់ជាបន្តបន្ទាប់ដោយសារការធ្វើការងារហួសកម្លាំង ហូបមិនគ្រប់គ្រាន់ និងជំងឺ។ ខ្ញុំចាំបានថា ប្រជាជនជាច្រើនបានស្លាប់ដោយសារជំងឺគ្រុនចាញ់ ហើយមិនមានពេទ្យព្យាបាល។ នៅពេលមានបងប្អូន ឬសមាជិកនៅក្នុងអង្គភាពឈឺ យើងបាននាំគ្នាស្វះស្វែងរកឫសឈើព្រៃសម្រាប់ធ្វើថ្នាំឲ្យអ្នកជំងឺផឹក ហើយខ្លះបានធូរស្រាលឡើងវិញ។

ខ្ញុំបានបន្តរស់នៅខេត្តមណ្ឌលគិរី រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមក៏បានវាយរុញច្រានខ្ញុំចូលទៅក្នុងព្រៃ។ នៅពេលនោះខ្ញុំបានឈប់ធ្វើស្រែ ហើយបានចូលរួមតស៊ូនៅក្នុងព្រៃប្រឆាំងវៀតណាម។ យើងបានជួបការលំបាកជាថ្មីម្តងទៀតនៅក្នុងព្រៃ។ ជីវិតរបស់ខ្ញុំបានពឹងផ្អែកទាំងស្រុងទៅលើភោគផលព្រៃឈើ។ ខ្ញុំបានដើរជីកមើមក្តួច និងដំឡូងព្រៃ មកធ្វើជាអាហារ។

ក្រោយមកខ្ញុំបានរៀបការនៅឆ្នាំ១៩៨១ នៅក្នុងព្រៃ។ ខ្ញុំបានបន្តរស់នៅក្នុងព្រៃ អស់ពេលជាច្រើនឆ្នាំ បន្ទាប់មកខ្ញុំក៏បានធ្វើដំណើរមកកាន់ព្រំដែនថៃ។ ខ្ញុំបានមកដល់ជំរំ «គ៧» ស្រុកឃុនហាន ប្រទេសថៃ នៅឆ្នាំ១៩៨៩។ នៅទីនោះ ជីវិតរបស់ខ្ញុំហាក់មានភាពប្រសើរឡើងវិញ ព្រោះយើងទទួលបានការផ្គត់ផ្គង់ស្បៀងអាហាររៀងរាល់មួយសប្តាហ៍ម្តង។ ខ្ញុំទទួលបានអង្ករ ត្រី សាច់ និងសម្ភារប្រើប្រាស់ផ្សេងៗជាច្រើនទៀតដែលអាចជួយសម្រួលដល់ការរស់នៅរបស់យើង។ យើងអាចដូរញដូរទំនិញ និងអនុផលព្រៃឈើមួយចំនួនដែលរកបានពីក្នុងព្រៃ ជាមួយឈ្មួញជនជាតិថៃ។

នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ខ្ញុំនិងគ្រួសារ រួមទាំងប្រជាជនដទៃដែលរស់នៅក្នុងជំរំ បានវិលត្រឡប់មករស់នៅតំបន់អន្លង់វែង ប្រទេសកម្ពុជាវិញ។ យើងបានរស់នៅក្រោមការគ្រប់គ្រងរបស់អង្គភាពទ័ព ពីព្រោះមិនទាន់មានការរៀបចំជាភូមិឋាន។ ដំបូងយើងចាប់ផ្តើមសង់ផ្ទះសម្រាប់ស្នាក់នៅ បន្ទាប់មកយើងកាប់ឆ្ការព្រៃ និងកាប់ដីដើម្បីដាំដំណាំនិងបង្កបង្កើនផល។ គ្រួសារនីមួយៗចាំបាច់ត្រូវផ្គត់ផ្គង់ជីវភាពដោយការធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វ ទៅតាមកម្លាំងរៀងៗខ្លួន។ ខណៈពេលដែលជំនួយចាប់ផ្តើមកាត់បន្ថយ ហើយមិនអាចផ្គត់ផ្គង់ជីវភាពប្រជាជនបាន ជីវិតរស់នៅគឺជួបខបសគ្គជាច្រើន ប៉ុន្តែយើងនៅតែតស៊ូ។ រហូតដល់ចុងឆ្នាំ១៩៩៧ កងកម្លាំងរបស់ខ្មែរក្រហមទាំងមូលបានបែកខ្ញែកគ្នា។ ប្រជាជនចាប់ផ្តើមភៀសខ្លួនចោលផ្ទះសម្បែងសាជាថ្មីម្តងទៀត។ ប្រជាជនមួយចំនួនបានរត់ភៀសឡើងទៅលើភ្នំតាមតាម៉ុក មួយចំនួនទៀត បានរត់ទៅផ្តាច់ខ្លួននៅអូរបែតាប់ ចំណែកខ្ញុំសម្រេចចិត្តមកផ្តាច់ខ្លួន និងចុះចូលជាមួយរាជរដ្ឋាភិបាលនៅស្រែណូយ និងបានរស់នៅទីនោះ។

បន្ទាប់ពីសមាហរណកម្មនៅអន្លង់វែង នៅចុងឆ្នាំ១៩៩៨ ខ្ញុំនិងគ្រួសារបានវិលត្រឡប់មករស់នៅអន្លង់វែងវិញ។ យើងបានខិតខំប្រឹងប្រែងកសាងជីវិតសាជាថ្មី ដោយការតស៊ូពីបាតដៃទទេ រហូតបានមកដល់ពេលបច្ចុប្បន្ន។ ដោយសារឆ្លៀយឆ្លងណាយជាមួយនឹងសង្គ្រាម ខ្ញុំសូមផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយ ត្រូវខិតខំប្រឹងធ្វើការងារយ៉ាងណាកុំឲ្យប្រទេសវិលទៅរកអតីតកាលដ៏ឃោរឃៅមួយនេះទៀត។



ទៀន នី បានផ្តល់បទសម្ភាសន៍ពីជីវិតជាយោធារបស់គាត់ដែលបានបម្រើឲ្យចលនាបដិវត្តន៍ខ្មែរក្រហមរហូតមកដល់តំបន់អន្លង់វែង ដល់ ហ៊ាន ពិសី អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# អនុស្សាវរីយ៍ថ្ងៃ ២ធ្នូ ឆ្នាំ១៩៧៨

*សុខ វណ្ណៈ*


*អេង ពេជ្រ ហៅ ប៉ិច មានកូនចំនួន៤នាក់ ហើយសព្វថ្ងៃគាត់រស់នៅភូមិក្តុល ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

អេង ពេជ្រ ហៅ ប៉ិច ភេទស្រី អាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិស្វាកេត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ប៉ិច មានឪពុកឈ្មោះ លី ឆេង មានស្រុកកំណើតនៅខេត្តកណ្តាល និងមានម្តាយឈ្មោះ វ៉ូច ហៀង មានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ។ ប៉ិច បានចេញពីស្រុកកំណើតតាំងពីអាយុ ៩ឆ្នាំ មករស់នៅតាមឪពុកម្តាយនៅភូមិក្តុល ឃុំទន្លូង ស្រុកមេមត់ខេត្តកំពង់ចាម ដោយសារតែឪពុករបស់ ប៉ិច បានទទួលម៉ៅការសាងសង់ផ្លូវជាតិលេខ៧ ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។ កាលពីក្មេង ប៉ិច បានចូលរៀននៅសាលាបឋមសិក្សាក្តុលត្រឹមថ្នាក់ទី៩ចាស់ ក៏ឈប់រៀន។

ប៉ិច បានរៀបរាប់ថា នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ខ្ញុំបានស្គាល់ឈ្មោះ ណាល់ ដែលមានឪពុកមាឈ្មោះ តាង៉ាន់ រស់នៅចម្ការថ្មី ក្នុងភូមិស្វា ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ជាប់នឹងនឹងប្រទេសវៀតណាម។ នៅពេលនោះ ប្រទេសវៀតណាមបានកើតសង្គ្រាមរវាងវៀតណាមខាងជើង ដែលមានកងទ័ពវៀតកុង និងវៀតណាមខាងត្បូងដែលមានកងទ័ពធីវគី។ កងទ័ពវៀតកុងមួយចំនួនបានចូលមកលាក់ខ្លួននៅក្នុងព្រៃតាម ព្រំដែនកម្ពុជា-វៀតណាម ដូច្នេះហើយ ទើបប្រជាជននៅក្នុងភូមិកោះថ្ម បុ ភូមិអញ្ចាញ, ភូមិស្វា, ភូមិក្តុល, ភូមិចង្កុំ ក្នុងឃុំទន្លូង និងប្រជាជនដែលមកពីតំបន់ផ្សេងៗទៀត ជាប់ព្រំដែនវៀតណាមបាននាំគ្នាទិញអង្ករ និងថ្នាំពេទ្យ ដឹកទៅលក់ឲ្យកងទ័ពវៀតកុងនៅម្តុំព្រៃទួលនេត ដើម្បីបានប្រាក់ចំណេញ។ កាលនោះឪពុកម្តាយខ្ញុំ បានបើកលក់អង្ករនៅផ្ទះ ដូច្នេះទើបប្រជាជនក្នុងភូមិនាំគ្នាមកទិញអង្កររបស់គាត់យកទៅលក់បន្តឲ្យកងទ័ពវៀតកុង។

នៅឆ្នាំ១៩៧០ ប្រទេសកម្ពុជា ចាប់ផ្តើមកើតចលាចល និងសង្គ្រាមដោយសារលោកសេនាប្រមុខលោក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ប្រជាជននៅតាមស្រុកស្រែចម្ការមិនសប្បាយចិត្តនឹងរដ្ឋប្រហារនេះឡើយ។ យុវជនមួយចំនួនបានធ្វើបាតុកម្ម និងហែរក្បួនតាមបណ្តោយផ្លូវជាតិ ប៉ុន្តែត្រូវបានទាហាន លន់ នល់ បាញ់បង្ក្រាបបណ្តាលឲ្យបាតុករមួយចំនួនរងរបួស និងមួយចំនួនបានវិលត្រឡប់ទៅភូមិកំណើតវិញ។ បើតាមខ្ញុំដឹង បងណាល់ និងមិត្តភក្តិរបស់គាត់ឈ្មោះ វណ្ណៈ បានចូលរួមបាតុកម្មនោះដែរ។ បន្ទាប់មកទៀត តាមការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ ពីទីក្រុងប៉េកាំង ប្រទេសចិនឲ្យកូនចៅចូលព្រៃម៉ាគីតស៊ូ

ដើម្បីរំដោះជាតិ ទើបយុវជននៅក្នុងភូមិក្តុល និងភូមិមួយចំនួនទៀតបានស្ម័គ្រចូលរួមចលនាតស៊ូ ហើយក្នុងចំណោមយុវជនទាំងនោះក៏មានបង ណាល់ និងមិត្តភក្តិរបស់គាត់ដែរ។ កាលនោះ ខ្ញុំបានឃើញយុវជនខ្លះរត់ត្រឡប់មកផ្ទះវិញដែរ ដោយសារខ្លាចការវាយប្រយុទ្ធគ្នា។

នៅអំឡុងឆ្នាំ១៩៧០ដដែល ខ្ញុំបានឃើញទាហានអាមេរិកាំងមកតាំងបន្ទាយនៅកោះថ្ម, ពងទឹក, ភូមិក្តុល និងវាលស្រែក្បែរផ្ទះរបស់ខ្ញុំ។ ទាហានអាមេរិកាំងខ្លះមានស្បែកខ្មៅ ខ្លះទៀតមានស្បែកស និងមាឌធំៗដើរចូលមកក្នុងភូមិរបស់ខ្ញុំ ដោយមានកាន់កាំភ្លើងគ្រប់ដៃ និងមានរថក្រោះបើកអមមកជាមួយ។ នៅពេលនោះ ប្រជាជនក្នុងភូមិ បានរស់នៅក្នុងស្ថានភាពភ័យខ្លាច ដោយសារការវាយប្រយុទ្ធគ្នា គ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែកៗ ចំណែក កងទ័ពវៀតកុង បានស្លៀកពាក់ខោអាវស៊ីវិលដូចប្រជាជនខ្មែរ ដើម្បីបន្លំខ្លួនចូលមកក្នុងភូមិស៊ើបការណ៍ ដែលធ្វើឲ្យទាហានអាមេរិកាំងពិបាកបែងចែករវាងប្រជាជនខ្មែរ និងវៀតកុង។ បើតាមកងទ័ពវៀតកុងឈ្មោះ អុង ជិន ដែលធ្លាប់យកគ្រាប់មីនមកលាក់ទុកនៅផ្ទះរបស់ខ្ញុំបាននិយាយថា ទាហានអាមេរិកាំងត្រូវបានកងទ័ពវៀតកុងលបបាញ់បណ្តាលឲ្យស្លាប់ និងរងរបួសជាច្រើននាក់។ ពេលនោះរថក្រោះរបស់ទាហានអាមេរិកាំងប្រហែលជា ៣០គ្រឿង មិនអាចមកជួយអន្តរាគមន៍ទាន់ពេលវេលាឡើយ។ កងទ័ពវៀតកុងមានជំនាញខាងជីកផ្លូវក្រោមដីដើម្បីលាក់ខ្លួន និងស៊ើបការណ៍ ហើយប្រជាជនខ្មែរខ្លះបានជួយលាក់បាំងទាហានវៀតកុងថែមទៀត ដែលធ្វើឲ្យទាហានអាមេរិចកាំងកាន់តែពិបាកក្នុងការស្វែងរកទីតាំងរបស់កងទ័ពវៀតកុង។ នៅពេលយប់កងទ័ពវៀតកុងយ៉ាងច្រើនសន្ធឹកសន្ធាប់បានធ្វើដំណើរចេញពីព្រំដែនវៀតណាម ឆ្លងកាត់ភូមិកោះថ្ម ភូមិក្តុល ចូលទៅខាងក្នុងប្រទេសកម្ពុជា។ ប្រជាជនខ្មែរមួយចំនួនបានជួយយាមផ្លូវឲ្យកងទ័ពវៀតកុង ព្រោះខ្លាចក្រែងកងទ័ពវៀតកុងដើរចំខ្សែត្រៀម និងបន្ទាយទាហានអាមេរិកាំងទៀតផង។ ទាហានអាមេរិកាំងបានតាំងបន្ទាយនៅក្នុងភូមិមួយរយៈក៏ដកចេញទៅវិញអស់។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានឡើងកាន់អំណាច ហើយទ្រព្យសម្បត្តិរបស់ប្រជាជននៅភូមិកោះថ្ម ភូមិក្តុល និងភូមិស្វា ត្រូវបានខ្មែរក្រហមប្រមូលដាក់រួមទាំងអស់។ ខ្មែរក្រហមបានចាត់តាំងប្រជាជននៅក្នុងភូមិឲ្យធ្វើការងាររួម និងហូបបាយរួមតាមសហករណ៍។ នៅក្នុងឆ្នាំ១៩៧៥ ដដែល ខ្ញុំបានឃើញ បងណាល់ និងយោធាខ្មែរក្រហមជាច្រើននាក់ទៀត បានដើរឆ្លងកាត់ភូមិដោយស្លៀកពាក់ឯកសណ្ឋានយោធា។ ខ្ញុំដឹងថាបងណាល់ ស្នាក់នៅបន្ទាយនៅភូមិកោះថ្ម។ នៅក្នុងសម័យខ្មែរក្រហម ទោះបីជាយើងធ្លាប់ស្គាល់គ្នា ប៉ុក៏ជាប់សាច់ញាតិ និងបងប្អូនគ្នា ក៏យើងមិនអាចទៅរាក់ទាក់បានដែរ។ នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៦ ប្រជាជននៅក្នុងភូមិក្តុលមិនសូវជួបការលំបាកក្នុងការហូបចុកប៉ុន្មានទេ ប៉ុន្តែប្រជាជនក៏ត្រូវធ្វើការងារលើកទំនប់ប្រឡាយគ្មានពេលសម្រាកដែរ។ នៅអំឡុងឆ្នាំ១៩៧៧ ប្រជាជនរស់នៅក្នុងភូមិចាប់ផ្តើមខ្វះខាត និងហូបចុកមិនបានគ្រប់គ្រាន់។ លើសពីនោះ យោធាមជ្ឈិមបានចុះមកចាប់យោធា និងកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ាមួយចំនួនថែមទៀត។ ថ្ងៃមួយ ខ្ញុំបានជួប តាញ៉ាល់ ប្រជាជននៅក្នុងភូមិកោះថ្ម។ តាញ៉ាល់បានលួចខ្សឹបប្រាប់ខ្ញុំថា «អញបានជូន ណាល់ ដើរកាត់ព្រៃទៅដល់ព្រំដែនវៀតណាមហើយ ប៉ុន្តែកុំមាត់ឲ្យអង្គការដឹងប្រយ័ត្នងាប់ទាំងអស់គ្នា»។ ពេលខ្ញុំឮតាញ៉ាល់ និយាយដូច្នេះ ខ្ញុំក៏មិនហ៊ានសួរដេញដោលច្រើនដែរ ព្រោះយោធាមជ្ឈិមបានចូលមកដល់ភូមិហើយ។ សភាពការណ៍នៅក្នុងភូមិកាន់តែច្របូកច្របល់ ហើយមួយរយៈក្រោយមក ស្រាប់តែខ្មែរក្រហមចេញផែនការជម្លៀសប្រជាជនក្នុងភូមិកោះថ្ម, ភូមិក្តុល, ភូមិស្វា, ភូមិចង្កុំ ឲ្យទៅរស់នៅតំបន់ផ្សេងវិញ។ ខ្ញុំនិងគ្រួសារបានប្តូរទៅរស់នៅស្វាយជ្រះ និង ស្រែចារ ក្នុងស្រុកស្នួល ខេត្តក្រចេះ។ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅធ្វើការក្នុងកងចល័ត ប៉ុន្តែមិនមានអាហារហូបគ្រប់គ្រាន់ឡើយ។ មានយុវជន និងយុវនារីមួយចំនួនបានស្លាប់ដោយសារអត់អាហារ និងមួយចំនួនទៀតត្រូវអង្គការបោកបញ្ឆោតយកទៅសម្លាប់ដោយកុហកថា ឲ្យទៅធ្វើត្រីប្រហុក។ ពេលនោះ ខ្ញុំក៏បានស្នើសុំប្រធានយោធាឈ្មោះ ទិ ទៅធ្វើត្រីប្រហុកដែរ ព្រោះគិតថានឹងទទួល

បានត្រីខ្លះយកមកហូប ប៉ុន្តែប្រធានយោធាតបមកខ្ញុំវិញថា មិត្តឯងចង់ទៅងាប់នឹងគេដែរឬ? ពេលនោះទើបខ្ញុំដឹងថា អង្គការយកអ្នកដែលមានឈ្មោះទៅធ្វើត្រីប្រហុកទៅសម្លាប់។

នៅខែតុលា ឆ្នាំ១៩៧៨ អង្គការបានប្រមូលកងនារី និងកងយុវជនទាំងអស់ ឲ្យទៅជួយសែងយោធាដែលរងរបួស និងស្លាប់ពេលដែលវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅសមរភូមិ។ យើងសែងយោធាខ្មែរក្រហមជាច្រើននាក់ដែលរងរបួសបណ្ដាក់គ្នា សំដៅទៅផ្លូវជាតិ ដើម្បីដឹកតាមរថយន្តយកទៅព្យាបាល។ ខ្ញុំខ្លាចខ្មោចខ្លាំងណាស់ ប៉ុន្តែពេលអង្គការប្រើឲ្យសែងខ្មោចខ្ញុំលែងខ្លាចអ្វីទាំងអស់។ នៅពេលខ្ញុំសែងខ្មោច និងអ្នករបួសខ្ញុំទទួលបានបាយហូបគ្រប់គ្រាន់។ ខ្ញុំធ្វើកិច្ចការនេះរយៈពេលប្រហែលជាមួយខែ ខ្មែរក្រហមបានចាប់ផ្ដើមកៀរប្រជាជនឲ្យទៅរស់នៅភាគខាងលិច ប៉ុន្តែខ្ញុំបានគេចខ្លួនមិនព្រមទៅតាមការចាត់តាំងរបស់ខ្មែរក្រហមឡើយ គឺខ្ញុំចង់នៅខាងវៀតណាម ព្រោះខ្ញុំអាចនិយាយភាសាវៀតណាមបានខ្លះ។ ជាសំណាងល្អខ្ញុំបានជួបកងទ័ពវៀតណាម និងបានជួបប្រជាជនមួយចំនួនដែលភៀសខ្លួនចូលទៅខាងវៀតណាម។

បន្ទាប់មក ខ្ញុំបានជិះរថយន្តជាមួយកងទ័ពវៀតណាមទៅចូលរួមការប្រារព្ធពិធីបង្កើតរណសិរ្ស ២ធ្នូ ឆ្នាំ១៩៧៨។ ខ្ញុំបានជួបតា បាក់ សព្វថ្ងៃរស់នៅភូមិក្តុល, កាណា សព្វថ្ងៃរស់នៅផ្សារស្នួល, យាយពេញ គឺជាអ្នកជម្លៀសមកពីភ្នំពេញដែលអ្នកភូមិហៅគាត់ថា យាយអំពេញៗ ដែលសព្វថ្ងៃគាត់ស្លាប់ហើយ។ ខ្ញុំបានឃើញកងទ័ព ប្រជាជនខ្មែរ រួមទាំងមន្ត្រីទូតមកចូលរួមក្នុងកម្មពិធីនេះ។ នៅពេលនោះមានកងទ័ពវៀតណាមប្រមាណមួយកងពល រួមជាមួយកាំភ្លើងតូចធំ រថក្រោះ និងរថយន្តរាប់រយគ្រឿង ចាំការពារបរិវេណខាងក្រៅ។

នៅពេលកម្មវិធីជិតចាប់ផ្ដើម ស្រាប់តែមនុស្សមនុស្សពីរបីនាក់ដើរសំដៅរកខ្ញុំ និង កាណា ដោយប្រាប់ខ្ញុំថា ជួយកាន់បដាពាក្យស្លោកផង។ ខ្ញុំ និង កាណា បានឈរកាន់បដាទាំងឃ្លាន ព្រោះមិនទាន់ហូបអាហារ។ ខ្ញុំក្រឡេកឃើញ បងណាល់ ដើរមកចំពីមុខយើងដែលកំពុងឈរ។ ខ្ញុំបានស្រែកប្រាប់ កាណា ថាដូចជា បងណាល់។ កាណា បានឆ្លើយតបថា ហ្នឹងហើយ បងណាល់។ បងណាល់ បានឃើញខ្ញុំដែរ ប៉ុន្តែគាត់ប្រញាប់ប្រញាល់ ហើយគាត់ក៏បានផ្ដាំខ្ញុំថា បន្តិចទៀតជួបគ្នា។ ពេលនោះ បង ណាល់ មានកងការពារដើរតាមក្រោយគាត់ ដោយមានស្ពាយកាំភ្លើងអាកាថ្មីៗ។ ខ្ញុំបានឃើញគាត់ដើរសួរសុខទុក្ខកងទ័ពខ្មែរ ដែលបានចូលរួមពិធីនោះ។ ខ្ញុំមិនដឹងថា បងណាល់ ធ្វើការងារអ្វី និងមានតួនាទីអ្វីទេ។ ពេលប្រជុំចប់ កងការពារពីរនាក់ដែលមានស្ពាយកាំភ្លើងបានដើរមកដល់ហើយប្រាប់ខ្ញុំថា លោក ហ៊ុន សែន ហៅយើងខ្ញុំទៅជួបគាត់។ ខ្ញុំចាប់ផ្ដើមភ័យម្ដងទៀត ព្រោះមិនដែលស្គាល់ លោក ហ៊ុន សែន ជានរណា ប៉ុន្តែពេលទៅដល់ក៏ឃើញ បងណាល់។ ខ្ញុំមិនហ៊ានសួរគាត់ច្រើនទេ ហើយគាត់ក៏ដឹងថាខ្ញុំឃ្លានដែរ។ គាត់បានប្រាប់ខ្ញុំថា ហូបនំសិនទៅ ហើយគាត់ហុចផ្លែឈើមកឲ្យខ្ញុំហូបថែមទៀត។ ពេលខ្ញុំហូបហើយ បងណាល់ បានសួរទុក្ខខ្ញុំ និងសួរនាំអំពីប្រពន្ធរបស់គាត់ថា ប៊ុច ឯងដែលឃើញប្រពន្ធរបស់ខ្ញុំទេ? ខ្ញុំបានឆ្លើយប្រាប់គាត់ថា ឃើញបង ខ្ញុំឃើញច្បាស់ណាស់ ពេលខ្ញុំត្រឡប់មកពីធ្វើការនៅបឹងក្រចាប់វិញ។ ខ្ញុំបានឃើញបងស្រីនៅគោកចារ។ បងស្រីជិះរទេះដោយដៃកំពុងពរកូនតូចមួយ សំដៅទៅលើ ប៉ុន្តែខ្ញុំមិនដឹងថាទៅទីណាឡើយ។ ពេលឮខ្ញុំនិយាយពាក្យនេះ បងណាល់ ចាប់ផ្ដើមយំ ហើយខ្ញុំក៏នាំគ្នាយំទាំងអស់គ្នា។ បងណាល់ មិនបានសួរនាំខ្ញុំទៀតទេ ព្រោះគាត់មានកិច្ចការ។ គាត់គ្រាន់តែផ្ដាំខ្ញុំថា ទៅហូបបាយសិនទៅចាំថ្ងៃក្រោយជួបគ្នា។ នៅកន្លែងប្រារព្ធពិធីថ្ងៃបង្កើតរណសិរ្ស ២ ធ្នូ មានការរៀបចំម្ហូបអាហារច្រើនណាស់ រួមទាំងផ្លែឈើ និងមានរោងបាយវែងមួយ។ មានមនុស្សច្រើនណាស់បានចូលរួមពិធីនេះ។ ពេលហូបបាយរួចអ្នកចូលរួមបានរំសាយបន្តិចម្ដងៗ ចេញទៅកន្លែងរៀងៗខ្លួនវិញ។ ចំណែកតា បាក់, កាណា, យាយពេញ បានត្រឡប់ទៅភូមិ គឺនៅសល់តែខ្ញុំនៅឈរវេរាមិនដឹងជាទៅណា ព្រោះបែកបាក់បងប្អូន។ ពេលនោះខ្ញុំបានឃើញរថយន្តកងទ័ពវៀតណាមរៀបចំវិលត្រឡប់ចូលទៅក្នុងប្រទេសវៀតណាមវិញ ខ្ញុំក៏បានដើរទៅសួរទើបដឹងថា លោក ហ៊ុន សែន នៅវៀតណាម។ ខ្ញុំបានសុំកងទ័ពវៀតណាមជិះរថយន្តទៅ ឡុងខាញ់ (ឡុង យ៉ាវ)

ក្នុងបំណាំងផ្ដោះព្រៃនគរ។ ពេលខ្ញុំទៅដល់ ឡុងខាញ់ភ្លាម ខ្ញុំបានចូលបម្រើកងទ័ពវៀតណាមនៅទីនោះ។ បន្ទាប់មក វៀតណាម បានចាត់តាំងខ្ញុំឲ្យធ្វើជានីរសារឲ្យប្រធានវរសេនាធំឈ្មោះ ឡាង។ ខ្ញុំបានសួររកលោក ហ៊ុន សែន ពេលនោះ ខាងវៀតណាមបានប្រាប់ខ្ញុំថា លោក ហ៊ុន សែន ចេញមកប្រទេសកម្ពុជាហើយ។ ខ្ញុំលែងបានជួបគាត់រហូតមក។ មានថ្ងៃមួយខ្ញុំបានធ្វើជាចុងភៅឲ្យមេបញ្ជាធំៗ ព្រោះខាងវៀតណាមប្រាប់ថា មានភ្ញៀវពិសេសមកពីខ្មែរ ដូច្នេះចុងភៅត្រូវស្ល សម្លកកូររបៀបខ្មែរ។ ខ្ញុំមិនបានចាប់អារម្មណ៍ទេ ស្រាប់តែមានកងការពារជនជាតិវៀតណាមម្នាក់និយាយប្រាប់ខ្ញុំថា ខ្មែរដែលមកចូលរួមជាមួយថ្នាក់លើវៀតណាមសុទ្ធតែអ្នកធំ ក្នុងចំណោមនោះក៏មានលោក ហេង សំរិន ដែរ។ ខ្ញុំមិនបានស្គាល់លោក ហេង សំរិន ពីមុនមកទេ ខ្ញុំក៏មិនហ៊ានទៅជួបគាត់ដែរ។ ពេលហូបបាយរួចហើយ លោកហេង សំរិន បានចាកចេញទៅ ហើយខ្ញុំក៏មិនដែលបានឃើញគាត់ត្រឡប់មកកន្លែងទៀតដែរ។

នៅឆ្នាំ១៩៧៩ នៅពេលដែលប្រទេសកម្ពុជាត្រូវបានរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានទៅដល់ភ្នំពេញ ចូលរួមមហាសន្និបាតនៅស្ដាតអូឡាំពិក ជាមួយថ្នាក់ដឹកនាំវៀតណាម និងខ្មែរជាច្រើននាក់។ ខ្ញុំបានស្នាក់នៅភ្នំពេញរយៈពេលបីថ្ងៃ ក៏ត្រឡប់មកប្រទេសវៀតណាមវិញ ព្រោះខ្ញុំមានឈ្មោះក្នុងកងទ័ពវៀតណាម។ នៅឆ្នាំ១៩៧៩ ខ្ញុំបាននៅឈរជើងការពារព្រំដែននៅម្ដុំខ្មុម ជាប់ព្រំដែនវៀតណាមនិងកម្ពុជា។ នៅក្នុងឆ្នាំ ១៩៧៩ ដដែល មានហេតុការណ៍មួយបានកើតឡើងនៅព្រំដែន ដោយខ្ញុំមិនបានដឹងថា ភាគីខាងណាបានចូលមកបាញ់ប្រធានវរសេនាធំឈ្មោះ ឡាង និងកងយោធាខ្មែរពីរនាក់ស្លាប់នៅក្នុងខ្មុមតូចមួយក្នុងទឹកដីវៀតណាមឡើយ។ ពេលនោះវៀតណាម បានយកសាកសពប្រធានវរសេនាធំឈ្មោះ ឡាង ទៅធ្វើបុណ្យតាមព្រពៃណីវៀតណាម ចំណែកសាកសពជនជាតិខ្មែរអង្គភាពបានចាត់តាំងខ្ញុំរួមជាមួយកងទ័ពវៀតណាមជាច្រើននាក់ដឹកមកកប់ក្នុងទឹកដីខ្មែរវិញ។ បន្ទាប់មកយើងបាននាំគ្នាមកដឹកទឹកអំពៅនៅផ្សារខ្មុម ហើយពេលនោះខ្ញុំបានឃើញអ្នកភូមិម្នាក់ឈ្មោះ ដឿង។ ខ្ញុំបានស្រែកសួរថា ដឿង ម៉ែអញនៅរស់ទេ ឌឿង បានតបមកថា នៅរស់រាល់ថ្ងៃនៅភូមិក្ដុល។ ពេលបានទទួលដំណឹងនេះហើយ ខ្ញុំបានព្យាយាមសុំវៀតណាមមកលេងផ្ទះ ប៉ុន្តែខាងវៀតណាមមិនអនុញ្ញាតទេ។ ក្រោយមក ខ្ញុំបានជួបឈ្មោះ ម៉ូវ ត្រូវជាប្អូនធម៌ និងចេះវៀតណាមច្បាស់។ ម៉ូវ បានទៅជួយនិយាយជាមួយភាគីវៀតណាមថា ម្ដាយរបស់ខ្ញុំគ្មានបងប្អូនទេ ហើយគាត់មានវ័យជរាណាស់ទៅនិងគ្មានអ្នកណាមើលថែ។ ប៉ុន្តែភាគីវៀតណាមមិនចង់ឲ្យខ្ញុំឈប់ពីការងារកងទ័ពឡើយ។ មួយរយៈក្រោយមក ភាគីវៀតណាមក៏អនុញ្ញាតឲ្យខ្ញុំត្រឡប់មកខ្មែរវិញ ដោយធ្វើសំបុត្រត្រឹមត្រូវ និងបើកអំណោយឲ្យជាច្រើន។ នៅពេលខ្ញុំបានត្រឡប់មកផ្ទះវិញបានជួបម្ដាយជាទីស្រឡាញ់ ហើយរួមរស់ប្រកបមុខរបរធ្វើស្រែចម្ការ ប៉ុន្តែពេលនោះនៅមានខ្មែរក្រហមចេញចូលក្នុងភូមិ ទើបខ្ញុំមិនហ៊ានទុកឯកសារដែលធ្លាប់បម្រើកងទ័ពវៀតណាម។ រយៈពេលជាង៣០ឆ្នាំក្រោយមក ខ្ញុំបានជួបសម្ដេច ហ៊ុន សែន នៅពេលសម្ដេចមកសម្ពោធសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម។ ខ្ញុំបានសុំសម្ដេចជួយកសាងវត្តក្ដុលបានមួយ។

សព្វថ្ងៃ ខ្ញុំមានប្ដីឈ្មោះ អ៊ឹង សុខគុង មានកូនចំនួន ៤នាក់ ប្រុស២ស្រី២ រស់នៅភូមិក្ដុល ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ សព្វថ្ងៃខ្ញុំធ្វើជាគណៈកម្មការវត្ត និងឆ្លៀតពេលប្រកបមុខរបររកស៊ីបន្តិចបន្តួចដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ រឿងរ៉ាវដែលកើតមានឡើងកាលពីសម័យសង្គ្រាម ខ្ញុំមិនចង់ឲ្យកើតមានសារជាថ្មីទេ ព្រោះពិបាកខ្លាំងណាស់។ សព្វថ្ងៃខ្ញុំបានប្រាប់កូនចៅជំនាន់ក្រោយពីរបបខ្មែរក្រហម ប៉ុន្តែក្មេងមិនសូវជឿឡើយ។ ខ្ញុំនិយាយថា នៅសម័យមុនមានសង្គ្រាម មានយន្តហោះអាមេរិកាំងទម្លាក់គ្រាប់ មានវៀតកុង រស់នៅក្នុងភូមិ។ ខ្ញុំមិនមានពេលហូបបាយទេ ពេលខ្លះខ្ញុំហូបក្នុងត្រង់សេ។ ចំណែកឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំមិនបានរស់នៅជុំគ្នាទេ ព្រោះគាត់ត្រូវទៅធ្វើការងារតាមការដ្ឋានរៀងៗខ្លួន។




# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។




មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។



តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។




ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ាវដ្ឋ មេត្តា

(តពីលេខមុន)

### ៤.២ លក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

**២៩៨.** ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទដោយអនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ «ដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាទូទៅនិងជាប្រព័ន្ធសំដៅទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ឬសាសនា» ដូចជា (១) ការធ្វើមនុស្សឃាត (២) ការសម្លាប់រង្គាល (៣) ការធ្វើឲ្យទៅជាទាសករ (៤) ការនិរទេស (៥) ការដាក់ក្នុងមន្ទីរឃុំឃាំង (៦) ការធ្វើទារុណកម្មក (៧) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និង (៨) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជា៖ (ក) ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស (ខ) ការរំលោភផ្លូវភេទ (គ) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ឃ) ការជម្លៀសដោយបង្ខំ (ង) ការបាត់ខ្លួនដោយបង្ខំ។

#### ៤.២.១. ច្បាប់

#### ៤.២.១.១. គោលការណ៍នីត្យានុកូលភាព

**២៩៩.** មេធាវីការពារក្តី ខៀវ សំផន បានដាក់សារណាមួយចំនួនទាក់ទងទៅនឹងវិធីសាស្ត្រដែលអង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តក្នុងសំណុំរឿង០០២/០១ចំពោះគោលការណ៍នីត្យានុកូលភាព។ ទោះបីជាសារណាទាំងនោះ ភាគច្រើនធ្វើឡើងនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ដោយ ក៏ប៉ុន្តែសារណាទាំងនោះបានលើកឡើងអំពីបញ្ហាដែលទាក់ទងជាទូទៅជាមួយគោលការណ៍នីត្យានុកូលភាព ហេតុដូច្នេះបានដោះស្រាយនៅខាងលើក្នុងផ្នែកស្តីពីបញ្ហាបឋម។ សារណាទាក់ទងនឹងឧក្រិដ្ឋកម្មជាក់លាក់ ត្រូវបានលើកឡើងនៅក្នុងផ្នែកស្តីពីច្បាស់ជាធរមាននៃឧក្រិដ្ឋកម្មនោះ។

**៣០០.** អង្គជំនុំជម្រះបញ្ជាក់ឡើងវិញអំពីការសម្រេចកន្លងមករបស់អង្គជំនុំជម្រះ ដែលត្រូវបានតម្កល់ដោយអង្គប្រជុំជម្រះតុលាការកំពូលដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មអន្តរជាតិ ចាប់តាំងពីមានធម្មនុញ្ញរបស់តុលាការ Nuremberg និងបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.។ ចំណុចនេះនៅតែមិនត្រូវបានជំទាស់ដោយភាគីណាមួយនោះឡើយ នៅក្នុងសំណុំរឿងនេះ។ ហេតុដូច្នេះ អនុលោមតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បទចោទនានា នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាទូទៅមានលក្ខណៈស្របទៅនឹងគោលការណ៍នីត្យានុកូលភាព លុះត្រាតែមានការវាយតម្លៃទៅលើនិយមន័យជាក់លាក់នៃធាតុផ្សំនានានៃឧក្រិដ្ឋកម្មទាំងអស់នេះ និងមានសេចក្តីសន្និដ្ឋានបន្ថែមថា រាល់បទល្មើសដែលបានចោទប្រកាន់ ឬ រាល់ទម្រង់នៃការទទួលខុសត្រូវ «ត្រូវមានលក្ខណៈអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ថា ជាបទល្មើស ហើយថាជនជាប់ចោទអាចដឹងពីច្បាប់ដែលចែងអំពីការទទួលខុសត្រូវផងដែរ នាពេលនោះ»។

### ៤.២.១.២. ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

**៣០១.** *បទល្មើសនានា ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាន លុះត្រាតែលក្ខខណ្ឌបរិបទ ឬលក្ខខណ្ឌទូទៅដូចតទៅនេះ ត្រូវបានបំពេញ (១) ការវាយប្រហារ (២) ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅឬជាប្រព័ន្ធ (៣) ការវាយប្រហារសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល (៤) ការវាយប្រហារត្រូវតែធ្វើឡើងដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា (៥) ត្រូវតែមានទំនាក់ទំនងរវាងអំពើរបស់ចារីផ្ទាល់និងជនជាប់ចោទ និងវាយប្រហារ និង (៦) ជនជាប់ចោទត្រូវមានការយល់ដឹងថាចាំបាច់អំពីការវាយប្រហារ។ ដូចដែលអង្គជំនុំជម្រះបានសម្រេចនាពេលកន្លងមក និងដែលត្រូវបានអង្គជំនុំជម្រះតុលាការកំពូលតម្កល់នោះ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥ មិនតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធនោះឡើយ។*

**៣០២.** *ការវាយប្រហារ៖ ការវាយប្រហារ គឺជាដំណើរការនៃអំពើរដែលពាក់ព័ន្ធនឹងការប្រព្រឹត្តនូវអំពើហិង្សាច្រើនៗ ការវាយប្រហារនេះ មិនមែនគិតត្រឹមតែការប្រើកម្លាំងប្រដាប់អាវុធប៉ុណ្ណោះនោះទេ គឺត្រូវគិតទាំងការធ្វើបាបប្រជាជនស៊ីវិលរួមទាំងអំពើទាំងឡាយដែលមាននៅក្នុងបទល្មើសជាក់លាក់ក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផងដែរ។ ការវាយប្រហារទៅលើប្រជាជនស៊ីវិលមានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធ។ ការវាយប្រហារអាចកើតមានឡើងមុន អាចអូសបន្លាយពេលយូរឬ បន្តកើតមានរហូតនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធដោយមិនចាំបាច់ថា ការវាយប្រហារនេះជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធនោះឡើយ។*

**៣០៣.** *លក្ខណៈជាទូទៅឬជាប្រព័ន្ធ៖ ពាក្យថា «លក្ខណៈជាទូទៅ» គឺសំដៅទៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើនហើយ ពាក្យថា «ជាប្រព័ន្ធ» គឺសំដៅលើអំពើហិង្សាដែលមានការរៀបចំ ហើយអំពើនោះមិនមែនកើតឡើងដោយចៃដន្យនោះទេ។ ជាទូទៅ ការវាយប្រហារជាប្រព័ន្ធ គឺជាប្រភេទបទល្មើសទាំងឡាយដែលទាក់ទងនិងការប្រព្រឹត្តអំពើឧក្រិដ្ឋប្រហាក់ប្រហែលគ្នាដដែលៗ ដែលមិនមែនជាការចៃដន្យ និងមានភាពទៀតទាត់។ ការវាយប្រហារលក្ខណៈជាទូទៅអាចសំដៅទៅលើ « ទាំងអានុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ទាំងអានុភាពនៃអំពើអមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ» ។ ភស្តុតាងដែលបង្ហាញអំពីការវាយប្រហារដែលមាន «លក្ខណៈជាទូទៅ» ឬ ជា «ប្រព័ន្ធ» គឺជាភស្តុតាងមួយដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញអំពីការទទួលខុសត្រូវ។ មានតែការវាយប្រហារប៉ុណ្ណោះ ដែលចាំបាច់តម្រូវឲ្យមានលក្ខណៈជាទូទៅ ជាប្រព័ន្ធចំណែកឯបទល្មើសជាក់លាក់នីមួយៗនោះ គឺមិនត្រូវឲ្យមានលក្ខខណ្ឌទាំងនេះទេ។ អំពើតែមួយឬអំពើដែលមានចំនួនកំណត់ មានលក្ខណៈគ្រប់គ្រាន់ អាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន លុះត្រាតែអំពើទាំងនោះមិនដាច់ចេញពីគ្នាឬមិនកើតឡើងដោយចៃដន្យ និងបានបំពេញនូវរាល់លក្ខខណ្ឌផ្សេងទៀត។*

**៣០៤.** *ទោះបីជាអត្ថិភាពនៃគោលនយោបាយ ឬផែនការមួយរបស់រដ្ឋឬរបស់អង្គការ អាចជាភស្តុតាងទាក់ទងនឹងការបង្កើតឲ្យមាននូវការវាយប្រហារដែលមានលក្ខណៈជាទូទៅឬជាប្រព័ន្ធត្រឹមឆ្នាំ១៩៧៥ ក៏ដោយក៏អត្ថិភាពនៃគោលនយោបាយនិងផែនការទាំងនោះ មិនមែនប្រាកដថាជាធាតុផ្សំបរិបទឯករាជ្យនៃនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិឡើយ។*

**៣០៥.** *សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល៖ ការវាយប្រហារត្រូវតែ «សំដៅប្រឆាំង» ទៅលើប្រជាជនស៊ីវិល។ មានន័យថាប្រជាជននោះត្រូវតែជាគោលដៅចម្បងនៃការវាយប្រហារ មិនមែនជាគោលដៅនៃការវាយប្រហារដោយចៃដន្យនោះទេ។ មិនចាំបាច់មានការបង្ហាញថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុង ទីតាំងភូមិសាស្ត្រពាក់ព័ន្ធណាមួយដែលមានការវាយប្រហារ ទើបចាត់ទុកថា ជាគោលដៅនៃការវាយប្រហារនោះ*

ឡើយ។ វាមានលក្ខណៈគ្រប់គ្រាន់ដោយគ្រាន់តែបង្ហាញថា បុគ្គលមួយចំនួននៅក្នុងក្រុមនោះ ត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារ ដើម្បីធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការវាយប្រហារនោះមានគោលដៅប្រឆាំងទៅលើ «ប្រជាជនស៊ីវិល» មិនមែនមានគោលដៅប្រឆាំងទៅលើបុគ្គលមួយចំនួនដែលបានកំណត់និងត្រូវបានជ្រើសរើសខ្លះៗនោះទេ។ បន្ថែមលើនេះ ការនិយាយយោងទៅលើប្រជាជនស៊ីវិល «ណាមួយ» មិនចាំបាច់បង្ហាញថា ជនរងគ្រោះទាំងនោះជាប់ទាក់ទងជាមួយក្រុមជាក់លាក់ណាមួយនោះទេ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចរួមបញ្ចូលទាំងការវាយប្រហាររបស់រដ្ឋមួយមកលើប្រជាជនរបស់ខ្លួនឯងផងដែរ។

**៣០៦.** ដើម្បីកំណត់ថាតើប្រជាជនអាចចាត់ទុកថាជា «ជនស៊ីវិល» បានដែរឬយ៉ាងណា អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមាននិយមន័យដែលបានកំណត់អំពីជនស៊ីវិលនៅក្នុងច្បាប់ជនស៊ីវិលអង្គជំនុំជម្រះត្រូវយោងទៅរកនិយមន័យទូទៅនៃពាក្យ «CIVILIAN» (ជាភាសាអង់គ្លេស) និង «CIVIL» (ភាសាបារាំង) ពោលគឺសំដៅលើបុគ្គលទាំងឡាយណា ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងរយៈពេលដែលពាក់ព័ន្ធនិងបទចោទនៅចំពោះមុខនេះថា ប្រជាជនស៊ីវិលរាប់បញ្ចូលនូវបុគ្គលទាំងឡាយដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬមិនមែនជាជនត្រូវបានទទួលស្គាល់ថា ជាអ្នកប្រយុទ្ធ។ ទោះបីជាអង្គជំនុំជម្រះមិនបានពឹងផ្អែកលើនិយមន័យនៃពាក្យ «ជនស៊ីវិល» ដូចមានចែងក្នុងមាត្រា៥០ នៃពិធីសារបន្ថែម I នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានអនុម័តដោយតុលាការមិនអចិន្ត្រៃយ៍នានា និងមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីឲ្យសមស្របទៅតាមស្មារតីនៃឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ ក្រោយឆ្នាំ១៩៧៧ ក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់ថា និយមន័យនេះស្របជាមួយនឹងអត្ថន័យជាទូទៅនៃពាក្យនេះ។

**៣០៧.** ផ្ទុយពីគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាបានលើកឡើងថា សញ្ញាណនៃពាក្យ«ជនស៊ីវិល» នៅក្នុងបរិបទនៃប្រជាជនស៊ីវិល រួមទាំង សមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លាំងដែរបានទម្លាក់អាវុធ ឬស្ថិតក្នុងស្ថានភាពជាទាហានដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ។ ដើម្បីគាំទ្រដល់អំណះអំណាង សហព្រះរាជអាជ្ញាបានយោងទៅរកបណ្តាយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍នានា ដែលហាក់ដូចជាទាញចេញពីការសម្រេច ដែលធ្វើឡើងពីដំបូងនៅក្នុងសាលក្រមនៃរឿងក្តី Akayesu ។ នៅក្នុងរឿងក្តីនោះ អង្គជំនុំជម្រះសាលាដំបូង«ប្រៀបធៀបនិយមន័យ«ជនស៊ីវិល» ទៅនឹងប្រភេទមនុស្សដែលត្រូវការពារស្របតាមមាត្រា ៣រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ» ដែលជាការបញ្ចូលគ្នាដោយប្រសិទ្ធភាពនូវនិយមន័យនៃ «ប្រជាជនស៊ីវិល» សម្រាប់គោលដៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាមួយនឹងនិយមន័យនៃ «បុគ្គលដែលទទួលបានការការពារ» នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ។ នេះគឺជាទស្សនៈដែលអាចអនុវត្តបាននៅក្នុងបរិបទនៃច្បាប់មនុស្សធម៌អន្តរជាតិ។ អង្គជំនុំជម្រះសាលាដំបូងមិនចាត់ទុកថា វិធីសាស្ត្រនេះបានឆ្លុះបញ្ចាំងដោយត្រឹមត្រូវអំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយទាក់ទងទៅនឹងនិយមន័យនៃ «ប្រជាជនស៊ីវិល» ត្រឹមឆ្នាំ១៩៧៥។ អង្គជំនុំជម្រះសូមរម្លឹកថា ក្នុងការសម្រេចអំពីឋានៈរបស់បុគ្គលណាម្នាក់ជាជនស៊ីវិល ឬមិនមែនជាជនស៊ីវិលនោះ ស្ថានភាពជាក់លាក់របស់បុគ្គលនោះនៅក្នុងពេលដែលមានបទឧក្រិដ្ឋកើតឡើង មិនអាចកំណត់អំពីឋានៈទាំងនោះបានឡើយ។ សមាជិកនៃអង្គការប្រដាប់អាវុធមិនត្រូវទទួលបានឋានៈជាជនស៊ីវិលនោះឡើយ ទោះបីបុគ្គលនេះមិនកាន់អាវុធឬ មិនបានចូលរួមនៅក្នុងការប្រយុទ្ធក្នុងពេលដែលមានការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះក៏ដោយ។ ហេតុដូច្នេះទាហានដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ មិនត្រូវបានចាត់ទុកថា «ជនស៊ីវិល» នោះទេផ្អែកតាមគោលបំណងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ហើយសេចក្តីអះអាងរបស់សហព្រះរាជអាជ្ញាទៅលើបញ្ហានេះត្រូវបានបដិសេធចោល។

**៣០៨.** *សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា ក្នុងករណីនៃការវាយប្រហារដែលធ្វើឡើងដោយរដ្ឋ ឬដោយអង្គការណាមួយប្រឆាំងនឹងប្រជាជនខ្លួនឯង អត្ថន័យនៃ«ប្រជាជនស៊ីវិល» នៅក្នុងឆ្នាំ១៩៧៥ បានគ្របដណ្តប់ទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋឬ របស់អង្គការនោះ លើកលែងតែកងកម្លាំងទាំងនោះមានសម្ពន្ធភាពជាមួយ ឬផ្តល់នូវការគាំទ្រពាក់ព័ន្ធផ្នែកយោធាទៅដល់ភាគីម្ខាងទៀតនៃជម្លោះ។ សហព្រះរាជអាជ្ញាបានយល់ស្របថា កងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបស់អង្គការណាមួយ មានឋានៈជាជនស៊ីវិលសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ មេធាវីការពារក្តី នួន ជា ហាក់ដូចជាឯកភាពថា ក្នុងករណីដែលមានសមាជិកកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយផ្ទាល់ បានចងសម្ព័ន្ធមិត្តជាមួយ នឹងឬផ្តល់ការគាំទ្រពាក់ព័ន្ធផ្នែកយោធាដល់គូសត្រូវនៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ ពួកគេមិនស្ថិតក្នុងនិយមន័យនៃ«ប្រជាជនស៊ីវិល» ក្នុងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ មេធាវីការពារក្តី ខៀវ សំផន មិនបានលើកឡើងនូវសារណាពាក់ព័ន្ធណាមួយឡើយចំពោះចំណុចមួយនេះ។ សារណាទាំងអស់នេះផ្អែកលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសំណុំរឿង០០៣ ដែលសម្រេចថា ការវាយប្រហាររបស់រដ្ឋ ឬអង្គការណាមួយ ទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន គឺជាការវាយប្រហារទៅលើប្រជាជនស៊ីវិលក្នុងករណីដែលកងកម្លាំងទាំងនោះពិតជាមិនមានសម្ពន្ធភាពជាមួយ ឬបានផ្តល់ការគាំទ្រពាក់ព័ន្ធផ្នែកយោធាដក់គូសត្រូវ។*

**៣០៩.** *អង្គជំនុំជម្រះមិនជឿថា នៅត្រឹមឆ្នាំ១៩៧៥ មានការទទួលស្គាល់តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលថា ការវាយប្រហារដោយរដ្ឋឬ អង្គការទៅលើកងកម្លាំងប្រដាប់ដោយអាវុធរបស់ខ្លួន អាចចាត់ទុកជាការវាយប្រហារទៅលើប្រជាជនស៊ីវិលនោះទេ។ នៅផ្នែកខាងលើអង្គជំនុំជម្រះបានសម្រេចរួចមកហើយថា សមាជិកអង្គភាពប្រដាប់អាវុធមិនត្រូវបានទទួលឋានៈជាជនស៊ីវិលនោះទេ បើទោះបីជាគាត់មិនកាន់អាវុធឬ មិន*

*កងយោធាខ្មែរក្រហមកំពុងបាញ់កាំភ្លើងធំតទល់ជាមួយកងទ័ពវៀតណាម នៅលើសមរភូមិក្នុងខេត្តស្វាយរៀង នៅដើមខែមករា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*បានចូលរួមនៅក្នុងការប្រយុទ្ធ នៅពេលដែលមានការប្រព្រឹត្តបទឧក្រិដ្ឋក៏ដោយ។ ទោះបីជាការសង្កេតនេះត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃកងទ័ពរបស់ភាគីបដិបក្ខនៃជម្លោះប្រដាប់អាវុធ ប៉ុន្តែអង្គជំនុំជម្រះពិចារណាថា ប្រការនេះ គឺត្រូវអនុវត្តដូចគ្នាចំពោះកងទ័ពនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬអង្គការ។ ក្រៅពីការយោងទៅសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានភាគីផ្សេងទៀត មិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះ បានកំណត់នូវមូលដ្ឋានត្រឹមត្រូវតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់ការសម្រេចផ្សេងពីនេះឡើយ។ លើសពីនេះទៀត ទោះបីជាការបកស្រាយអំពីការការពារដែលត្រូវបានអនុញ្ញាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមបញ្ចូលទាំងកងកម្លាំងប្រដាប់អាវុធក្នុងស្រុកអាចចាត់ទុកថាជាការប្រសើរ ប៉ុន្តែមិនមានភាពច្បាស់លាស់ដែលថា គ្រប់ខណ្ឌគតិយុទ្ធដែលផ្តល់នូវការការពារបែបនេះ អាចប្រមើលឃើញឬអាចដឹងជាមុនថាមានច្បាប់បែងនោះឡើយ នៅត្រឹមឆ្នាំ១៩៧៥។*



៣១០. អង្គជំនុំជម្រះពិចារណាឃើញថា នៅក្នុងករណីណាក៏ដោយ សេចក្តីសម្រេចលើចំណុចគតិយុត្តិមួយនេះ មិនប៉ះពាល់ជាសំខាន់ដល់លទ្ធផលនៃសំណុំរឿងនោះឡើយ ដោយសារមូលហេតុដូចតទៅ។ អង្គជំនុំជម្រះសូមរម្លឹកថា ដើម្បីមានលក្ខណៈគ្រប់គ្រាន់អាចចាត់ទុកថាជា «ប្រជាជនស៊ីវិល» ស្របគ្នាជាមួយនឹងស្មារតីនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. លុះត្រាតែ ប្រជាជនដែលជាគោលដៅនៃការវាយប្រហារនោះត្រូវតែជាជនស៊ីវិលច្រើនលើសលប់។ វត្តមានរបស់បុគ្គលមួយចំនួនក្នុងចំណោមប្រជាជនស៊ីវិល ហើយដែលបុគ្គលទាំងនោះមិនស្ថិតនៅក្នុងនិយមន័យនៃជនស៊ីវិល មិនអាចដកហូតចរិកលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនេះបានទេ។ ប្រសិនបើការវាយប្រហារ ត្រូវបានធ្វើឡើងនៅក្នុងភូមិសាស្ត្រដែលមានទាំងជនស៊ីវិលនិងទាហានផងនោះ កត្តាផ្សេងទៀតអាចមានភាពពាក់ព័ន្ធដើម្បីកំណត់ថា តើការវាយប្រហារនោះត្រូវបានប្រព្រឹត្តសំដៅទៅលើ «ប្រជាជនស៊ីវិល» ដែរឬទេ។ កត្តាទាំងនេះរួមមាន មធ្យោបាយនិងវិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងការវាយប្រហារ ឋានៈរបស់ជនរងគ្រោះចំនួនជនរងគ្រោះ លក្ខណៈរើសអើងនៃការវាយប្រហារ លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលវាយប្រហារ និងការបង្ក្រាបដល់អ្នកតស៊ូនៅពេលនោះ និងទំហំនៃកម្លាំងវាយប្រហារដែលអាចនិយាយបានថាគោរពតាម ឬមានចេតនាគោរពតាមលក្ខខណ្ឌប្រុងប្រយ័ត្នទាំងឡាយនៃច្បាប់សង្គ្រាម។ លើសពីនេះទៀត ឋានៈជាជនស៊ីវិលរបស់ជនរងគ្រោះ ចំនួនជនស៊ីវិល និងចំនួនសមាមាត្រនៃជនស៊ីវិលនៅក្នុងចំណោមប្រជាជន គឺជាកត្តាដែលពាក់ព័ន្ធនឹងការកំណត់ថា តើលក្ខខណ្ឌតម្រូវនៃការវាយប្រហារដែលត្រូវបានធ្វើឡើងប្រឆាំងនឹង «ប្រជាជនស៊ីវិល» ត្រូវបានបំពេញដែរឬទេ។

៣១១. ក្នុងករណីដែលមានការសម្រេចថា ការវាយប្រហារធ្វើឡើងសំដៅទៅលើប្រជាជនស៊ីវិលនៅក្នុងប្រទេសទាំងមូលនោះ ការពិចារណាលើលក្ខណៈរបស់ប្រជាជនដែលត្រូវទទួលរងការវាយប្រហារ គួរតែក្តោបទៅលើប្រទេសទាំងមូល ជាជាងអនុវត្តទៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗដាច់ពីគ្នា។ នៅក្នុងសំណុំរឿងនេះ ដីកាដំណោះស្រាយបានចោទប្រកាន់ថា គោលនយោបាយដែលអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យបានអនុវត្តរួមមានការវាយប្រហារប្រព័ន្ធនិងជាទូទៅតែមួយ «ប្រឆាំងទៅលើប្រជាជនស៊ីវិលទាំងអស់នៃប្រទេសកម្ពុជា»។ ហេតុដូច្នេះ ប្រសិនបើការចោទប្រកាន់នេះត្រូវបានរកឃើញថាមានមូលដ្ឋានគ្រប់គ្រាន់ អង្គជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការធ្វើសេចក្តីសម្រេចតែមួយ អំពីលក្ខណៈនៃប្រជាជនដែលជាគោលដៅសម្រាប់ប្រទេសទាំងមូលតែម្តង រួមទាំង អំពីសមាមាត្រនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់កម្ពុជាប្រជាធិបតេយ្យជាមួយនឹងចំនួនប្រជាជនសរុបដែលជាកម្មវត្ថុនៃការវាយប្រហារ និងអំពីបញ្ហាថា តើសមាមាត្រនេះមានភាពសំខាន់ដែលអាចដកហូតឋានៈជាជនស៊ីវិលពីប្រជាជនទាំងនេះបានដែរឬទេ។ ការវាយប្រហារតម្លៃនេះត្រូវបានធ្វើឡើងនៅផ្នែកខាងក្រោមនេះ។ មេធាវីការពារក្តី នួន ជា បានលើកឡើងថា ដើម្បីចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹង

មនុស្សជាតិ ជនរងគ្រោះនៃឧក្រិដ្ឋកម្មនោះចាំបាច់ត្រូវតែជាជនស៊ីវិល។ តាមរយៈការផ្តល់ឧទាហរណ៍ មេធាវីការពារក្តីបានលើកឡើងថា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខអូរកន្សែងគឺជាស្ថាប័នយោធា ដែលភាគច្រើនលើសលប់នៃអ្នកជាប់ឃុំ គឺយកមកពីកងទ័ពបដិវត្តន៍កម្ពុជា ហេតុដូច្នេះហើយ អ្នកជាប់ឃុំទាំងនោះមិនអាចជាជនរងគ្រោះនៃឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិឡើយ។ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅពេលមានការបង្ហាញថាការវាយប្រហារជាប្រព័ន្ធឬជាទូទៅ ទៅលើប្រជាជនស៊ីវិលបានលើកឡើងនោះ វាពុំមានការចាំបាច់សន្និដ្ឋានពាក់ព័ន្ធបញ្ហានេះ នោះឡើយ។

**៣១២.** អង្គជំនុំជម្រះកត់សម្គាល់ថា រឿងក្តីនានាដែលមេធាវីការពារក្តី នួន ជា បានពឹងផ្អែកទៅលើនោះ មិនបានគាំទ្រដល់ទស្សនៈដែលថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចាំបាច់ត្រូវតែជាជនស៊ីវិលនោះឡើយ។ ផ្ទុយទៅវិញរឿងក្តីទាំងនោះ ហាក់ដូចជាពាក់ព័ន្ធជាមួយនឹងការកំណត់នូវឋានៈជនរងគ្រោះដែលទទួលបានការការពារស្របតាមស្មារតីនៃអនុសញ្ញាទីក្រុងហ្សឺណែវ។ បន្ថែមលើនេះ ការអះអាងនេះ គឺមិនស៊ីសង្វាក់ជាមួយនឹងស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយនៅត្រឹមឆ្នាំ១៩៧៥។ អង្គជំនុំជម្រះសូមរម្លឹកថា នៅពេលដែលប្រជាជនស៊ីវិល គឺជាកម្មវត្ថុនៃការវាយប្រហារនោះ «មិនតម្រូវមានលក្ខខណ្ឌឬ បង្ហាញនូវធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលថាជនរងគ្រោះនៃបទល្មើសជាក់លាក់ណាមួយនោះ ត្រូវតែជាជនស៊ីវិលនោះឡើយ។ ហេតុដូច្នេះ ទាហានណាម្នាក់ដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដរាបណាលក្ខខណ្ឌចាំបាច់ដទៃទៀតត្រូវបានបំពេញ។

**៣១៣.** មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា៖ មាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ការវាយប្រហារត្រូវតែធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ដោយមូលហេតុនៃការរើសអើង ពោលគឺ មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ នេះគឺជាលក្ខខណ្ឌតម្រូវនៃយុត្តាធិការដែលកំណត់នូវវិសាលភាពមានលក្ខណៈចង្អៀតនៃយុត្តាធិការរបស់ អ.វ.ត.ក. លើឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ បើផ្អែកទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានអនុវត្តរវាងឆ្នាំ១៩៧៥-១៩៧៩។ លក្ខខណ្ឌតម្រូវនេះកំណត់យកការវាយប្រហារដែលមានទ្រង់ទ្រាយធំទូលាយ ជាជាងបទល្មើសជាក់លាក់នីមួយៗ។ ហេតុដូច្នេះ ធាតុផ្សំ



កងរថពាសដែកខ្មែរក្រហមកំពុងប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម នៅលើសមរភូមិ នៅដើមខែមករាឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*ចេតនានៃការរើសអើងមិនមែនជាធាតុផ្សំផ្លូវច្បាប់សម្រាប់គ្រប់បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ដោយសារតែលក្ខខណ្ឌតម្រូវនេះ នឹងធ្វើឲ្យការយោងដែលបានបញ្ជាក់ទៅលើការរើសអើង នៅក្នុងបទល្មើសនៃការធ្វើទុក្ខបុកម្នេញក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនមានប្រយោជន៍។*

**៣១៤.** *យុត្តិសាស្ត្រពាក់ព័ន្ធនឹងបទល្មើសធ្វើទុក្ខបុកម្នេញកំណត់និយមន័យអំពើមួយថាជាការរើសអើង នៅពេលដែលជាចារីកំណត់ថាជនរងគ្រោះណាមួយដៅនៃការវាយប្រហារ ដោយសារតែបុគ្គលនោះជាសមាជិកឬត្រូវបានសន្មតថា ជាសមាជិកនៅក្នុងក្រុមនយោបាយពូជសាសន៍ឬសាសនា ណាមួយ។ ក្រុមគោលដៅនោះ «អាចត្រូវបានចារីកំណត់និយមន័យជាទូទៅក្នុងន័យអវិជ្ជមាន និងរួមទាំងអ្នកដែលមានជាប់ទាក់ទងគ្នាជិតស្និទ្ធ ឬមានសមានចិត្តចំពោះក្រុមជនរងគ្រោះ[...] »។ វិធីសាស្ត្រនេះអាចយកមកអនុវត្តបានដូចគ្នានៅក្នុងការកំណត់និយមន័យនៃក្រុមជាក់លាក់ណាមួយដែលជាគោលដៅនៃការវាយប្រហារ។*

**៣១៥.** *ទំនាក់ទំនងរវាងអំពើរបស់ចារី ឬជនជាប់ចោទ និងការវាយប្រហារ៖ អំពើរបស់ចារីត្រូវតែជាផ្នែកមួយនៃការវាយប្រហារ មានន័យថា បើទោះបីជាអំពើនោះជាអំពើប្រភេទណាឬមានផលវិបាកយ៉ាងណាក៏ដោយ ជាសត្យានុម័តតែជាផ្នែកមួយនៃការវាយប្រហារ។ បន្ថែមពីនេះ អំពើរបស់ជនជាប់ចោទដែលពុំមែនជាចារីផ្ទាល់ចាំបាច់ត្រូវតែជាផ្នែកមួយនៃការវាយប្រហារផងដែរ។ ឧក្រិដ្ឋកម្មមួយដែលត្រូវបានប្រព្រឹត្តឡើងមុន ឬ ក្រោយ ឬ នៅឆ្ងាយពីការវាយប្រហារជាចម្បងប្រឆាំងទៅលើប្រជាជនស៊ីវិលនោះ ក៏នៅតែអាចជាផ្នែកមួយនៃការវាយប្រហារដដែល ប្រសិនបើឧក្រិដ្ឋកម្មនោះមានទំនាក់ទំនងគ្នាជិតស្និទ្ធជាមួយនឹងការវាយប្រហារនោះ។ យ៉ាងណាមិញឧក្រិដ្ឋកម្មមិនអាចជាអំពើដាច់ដោយឡែកបានលុះត្រាតែឧក្រិដ្ឋកម្មនោះនៅដាច់ឆ្ងាយពីការវាយប្រហារ ដែលមិនមានហេតុផលសមស្របណាមួយអាចនិយាយបានថាឧក្រិដ្ឋកម្មនោះ គឺជាផ្នែកមួយនៃការវាយប្រហារក្រោយពីបានពិចារណាលើបរិបទ និងកាលៈទេសៈដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើង។*

**៣១៦.** *ការដឹងឮ៖ ជនជាប់ចោទត្រូវបានដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងបានដឹងថាអំពើរបស់ខ្លួនបង្កើតបានជាផ្នែកមួយនៃការវាយប្រហារនោះ។ ជនជាប់ចោទមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលដៅនៃការវាយប្រហារដែលមានលក្ខណៈធំទូលាយនោះទេ។ ភស្តុតាងអំពីការដឹងនេះអាស្រ័យលើអង្គហេតុនៃករណីជាក់លាក់នីមួយៗ។ ជាលទ្ធផល ការបង្ហាញធាតុផ្សំតាមផ្លូវច្បាប់ថាយ៉ាងណានោះ គឺអាស្រ័យតាមកាលៈទេសៈជាក់ស្តែងនីមួយៗ។*

## ៤.២.២. សំអាងច្បាប់

### ៤.២.២.១. ការវាយប្រហារជាទូទៅឬ ជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល

**៣១៧.** *អង្គជំនុំជម្រះជឿជាក់ថា ចាប់ផ្តើមពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាយុត្តាធិការពេលវេលាក្នុងសំណុំរឿង០០២/០២ មានការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។ ការវាយប្រហារនោះត្រូវបានប្រព្រឹត្តឡើងក្រោមទម្រង់ជាច្រើនរួមទាំង ការធ្វើឲ្យទៅជាទាសករការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញ។ ការវាយប្រហារនេះ បានធ្វើឲ្យប្រជាជនកម្ពុជារាប់លាននាក់នៅទូទាំងប្រទេសកម្ពុជា ក្លាយជាជនរងគ្រោះ និងធ្វើឲ្យមានប្រជាជនជាច្រើនភៀសខ្លួនចេញទៅកាន់ប្រទេសជិតខាង។ ការវាយប្រហារនេះ ត្រូវបានអនុវត្តឡើងដើម្បីជាការជំរុញនិងស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ អង្គជំនុំជម្រះជឿជាក់ថា កាវាយប្រហារនេះមានលក្ខណៈជាទូទៅ ដោយពិចារណាទៅលើវិសាលភាពភូមិសាស្ត្រ និងចំនួនជនរងគ្រោះ។ អង្គជំនុំជម្រះយល់ឃើញផងដែរថា ការវាយប្រហារនេះមានលក្ខណៈ*

ជាប្រព័ន្ធដោយសារតែវិសាលភាព និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះ មិនអាចត្រូវបានប្រព្រឹត្តឡើងដោយគ្មានការរៀបចំជាមុន និងត្រូវបានអនុវត្តធ្វើឡើងជាបន្តបន្ទាប់នៅពេញមួយអំឡុងពេលនៃការចោទប្រកាន់ និងដោយមានចេតនាដើម្បីជំរុញ និងស្របតាមគោលនយោបាយរបស់បក្ស។

៣១៨. ទោះបីជាការវាយប្រហារលើប្រជាជនកម្ពុជាបានកើតមានស្របគ្នាជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជានិងវៀតណាមក៏ដោយ ប៉ុន្តែ ប.ក.ក. ផ្តោតគោលដៅចម្បងរបស់ខ្លួនមកលើប្រជាជនខ្លួនឯង។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះត្រូវបានធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិលនៃប្រទេសកម្ពុជា។ ក្រោយថ្ងៃ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទាហានទាំងអស់នៃអតីតរបបសាធារណរដ្ឋខ្មែរដែលមិនបានចូលរួមដោយផ្ទាល់នៅក្នុងជម្លោះប្រដាប់ដោយអាវុធ ឬយ៉ាងហោចណាស់ក៏ជា ទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ មានសិទ្ធិទទួលបានការការពារដូចប្រជាជនស៊ីវិលដែរ។ គោលការណ៍នេះក៏ត្រូវអនុវត្តដូចគ្នាចំពោះទាហានវៀតណាមដែលមិនបានចូលរួមដោយផ្ទាល់ នៅក្នុងជម្លោះប្រដាប់ដោយអាវុធផងដែរ។ ទោះជាក្នុងករណីណាក៏ដោយ អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ និងទាហានវៀតណាមគ្រាន់តែជាផ្នែកមួយនៃប្រជាជនស៊ីវិលរាប់លាននាក់ដែរត្រូវបានវាយប្រហារតែប៉ុណ្ណោះ។

### ៤.២.២.២. មូលហេតុនៃការរើសអើង

៣១៩. បន្ថែមពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនេះត្រូវបានប្រព្រឹត្តឡើងដោយសារមូលហេតុនយោបាយស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេសប្រឆាំងនឹងខ្មាំងខាងក្នុងនិងខាងក្រៅ។ ដើម្បីសម្រេចបានទិសដៅនេះ បក្សយល់ថា វណ្ណៈទាំងអស់ក្រៅពីវណ្ណៈកម្មករ-កសិករ ត្រូវតែកម្ទេចចោល។ វណ្ណៈសេដ្ឋកិច្ចនិងវណ្ណៈសង្គមផ្សេងទៀត ដូចជា វណ្ណៈអនុធន វណ្ណៈនាយទុន និងវណ្ណៈសក្តិភូមិត្រូវបានគេចាត់ទុកថាជាខ្មាំងខាងនយោបាយ និងខ្មាំងខាងសង្គមរបស់បដិវត្តន៍និងប្រព័ន្ធសមូហភាព។ លើសពីនេះទៀតប្រជាជនកម្ពុជាទាំងអស់ត្រូវតែជាផ្នែកមួយនៃបដិវត្តន៍ និងប្រព័ន្ធសមូហភាពនេះ។ លើសពីនេះទៀតប្រជាជនកម្ពុជាទាំងអស់ត្រូវតែជាផ្នែកមួយនៃបដិវត្តន៍ និងប្រព័ន្ធសមូហភាព។ អ្នកដែលប្រឆាំងឬត្រូវបានគេសន្មតថា បានប្រឆាំងនឹងបដិវត្តន៍និងប្រព័ន្ធសមូហភាពនេះ គឺជាគោលដៅនៃការធ្វើបាបនិងអំពើហិង្សា។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះត្រូវបានអនុវត្តឡើងដោយសារមូលហេតុនយោបាយ។

៣២០. ជាមួយគ្នានេះដែរ ពុទ្ធសាសនិក ក៏ត្រូវបានវាយប្រហារដោយមូលហេតុសាសនារបស់ពួកគេ ជនជាតិចាមដោយមូលហេតុជាតិពន្ធុនិងសាសនារបស់ពួកគេ និងជនជាតិវៀតណាម ដោយមូលហេតុជាតិពន្ធុ ជាតិសាសន៍ និងពូជសាសន៍។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ការវាយប្រហារនេះក៏ត្រូវបានធ្វើឡើងដោយមូលហេតុជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ និងសាសនាផងដែរ។

### ៤.២.២.៣. ចំណងទាក់ទងរវាងអំពើនិងការវាយប្រហារ

៣២១. អង្គជំនុំជម្រះជឿជាក់ទៀតថា មានចំណងទាក់ទងរវាងអំពើរបស់ចារីផ្ទាល់និងជនជាប់ចោទជាមួយនឹងការវាយប្រហារ។ អំពើរបស់ចារីផ្ទាល់ ក៏ដូចជា អំពើរបស់ជនជាប់ចោទទាំងពីរនាក់ ដែរបានប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ត្រូវបានធ្វើឡើងស្របតាមគោលដៅ និងដើម្បីជំរុញគោលដៅរបស់ ប.ក.ក. អនុវត្តឲ្យបានឆាប់រហ័សនូវបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា ស្របតាមពាក្យស្លោក «មហាលោតផ្លោះ មហាអស្ចារ្យ» ដែលបានបង្កើតឡើងដើម្បីការការពារប្រទេសពីខ្មាំង និងដើម្បីប្តូរកម្ពុជាឲ្យទៅជាសង្គមខ្មែរតែមួយដែលគ្មានជំនឿសាសនា និងមានតែវណ្ណៈកម្មករ-កសិករតែប៉ុណ្ណោះ។ គោលនយោបាយ ប.ក.ក. លើករណីនេះពោលគឺដើម្បី បង្កើតនិងដំណើរការសហករណ៍ និងការដ្ឋានការងារនៅទូទាំងប្រទេសកម្ពុជា ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន បំបែក និង«កម្ទេច» ប្រភេទខ្មាំង



*រថក្រោះរបស់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ នៅខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ដ៏គ្រោះថ្នាក់បំផុតនៅតាមមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស និងដើម្បីកំណត់បទបញ្ជាលើអាពាហ៍ពិពាហ៍ ដែលអំពើទាំងនេះនាំឲ្យប្រជាជនកម្ពុជារងគ្រោះជាប្រព័ន្ធ និងជាទូទៅនៅក្នុងអំឡុងពេលនៃការចោទប្រកាន់។ ទាំង នួន ជា និង ខៀវ សំផន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំបង្កើតនិង/ឬអនុវត្តគោលនយោបាយទាំងនេះ ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីចំណងទាក់ទងរវាងការវាយប្រហារ និងអំពើដែលបានប្រព្រឹត្តឡើង។*

### ៤.២.២.៤. ការដឹងឮរបស់ជនជាប់ចោទ

**៣២២.** *ដោយពិចារណាទៅលើទំហំ និងវិសាលភាពនៃការវាយប្រហារនេះ និងចំណុចដែលថាការវាយប្រហារនេះត្រូវបានអនុវត្តឡើងដើម្បីជំរុញនិងស្របតាមគោលនយោបាយ និងផែនការរបស់បក្សនោះ អង្គជំនុំជម្រះជឿជាក់ថាទាំង នួន ជា និង ខៀវ សំផន បានដឹងពីការវាយប្រហារប្រឆាំងនិងប្រជាជនស៊ីវិល។ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈតួនាទីមុខងាររបស់ខ្លួនក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការចូលរួមនៅក្នុងផែនការ និងគោលនយោបាយដែលរួមទាំងការវាយប្រហារផងនោះ នួនជា និង ខៀវ សំផនបានដឹងថាអំពើរបស់ពួកគេគឺជាផ្នែកមួយនៃការវាយប្រហារនោះ។*

**៣២៣.** *ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌទូទៅទាំងអស់សម្រាប់អនុវត្តមាត្រា ៥នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ។*

### ៤.៣ លក្ខខណ្ឌទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ចែងនៅក្នុងមាត្រា៦នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.

**៣២៤.** *ពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទ ដោយអនុលោមតាមមាត្រា៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ រួមមាន (១) ការធ្វើមនុស្សឃាតដោយចេតនា (២) ការធ្វើទារុណកម្ម (៣) ការធ្វើបាបដោយ*

អមនុស្សធម៌ (៤) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬ ឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព (៥) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ (៦) ការនិរទេសជនស៊ីវិលដោយខុសច្បាប់ (៧) ការឃុំខ្លួនជនស៊ីវិលខុសច្បាប់។

## ៤.៣.១. ច្បាប់

**៣២៥.** ការបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងអំឡុងពេលដែល អ.វ.ត.ក. មានយុត្តាធិការ។ ដោយហេតុថាប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៥៨ ដូចនេះហើយប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ក៏ដូចជាការទទួលខុសត្រូវព្រហ្មទណ្ឌដែលភ្ជាប់នៅក្នុងបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលពាក់ព័ន្ធ។ លើសពីនេះទៀត បទប្បញ្ញត្តិទាំងនេះ គឺជាការចងក្រងនៃគោលការណ៍សំខាន់ៗនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួនហាមឃាត់ «ការបំពានយ៉ាងធ្ងន់ធ្ងរ» ដែលបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិ «ដែលត្រូវទទួលបានការការពារ» នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលមានលក្ខណៈអន្តរជាតិ រួមទាំង ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ និងការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព។ បន្ថែមពីនេះអនុសញ្ញាទីក្រុងហ្សឺណែវIII និងអនុសញ្ញាទីក្រុងហ្សឺណែវIV ហាមឃាត់អំពីការបំពានយ៉ាងធ្ងន់ធ្ងរនូវការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់។ លើសពីនេះទៀត ការនិរទេសដោយខុសច្បាប់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ត្រូវបានកំណត់ថា ជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរអនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវIV។

**៣២៦.** ពាក់ព័ន្ធនឹងភាពអាចប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងអំពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដែលត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តីនេះ និងដែលមិនមានភាគីផ្សេងទៀតបានជំទាស់នោះ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការផ្តល់សច្ចាប័នរបស់កម្ពុជាលើអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៥៨ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីបានថ្លឹងថ្លែងលើកត្តាទាំងនេះដោយសត្យានុម័ត អង្គជំនុំជម្រះសន្និដ្ឋានថាជនជាប់ចោទអាចប្រមើលមើលឃើញនិងដឹងជាទូទៅថា (១) ការធ្វើមនុស្សឃាតដោយចេតនា (២) ការធ្វើទារុណកម្ម(៣) ការធ្វើបាបដោយអមនុស្សធម៌ (៤) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរឬឲ្យមានការឈឺចាប់ដល់រាងកាយឬ សុខភាព (៥) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ទៀងទាត់ (៦) ការនិរទេសជនស៊ីវិលដោយខុសច្បាប់និង (៧) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់អាចត្រូវបានផ្តន្ទាទោសជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវត្រឹមឆ្នាំ១៩៧៥។ ហេតុដូច្នេះ ការចោទប្រកាន់នានានៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៥ អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក. ស្របតាមគោលការណ៍នីត្យានុកូលភាព។

**៣២៧.** បទល្មើសដែលមានចែងនៅក្នុងមាត្រា៦នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បង្កើតបានជាការបំពានយ៉ាងធ្ងន់ធ្ងរ ប្រសិនបើមានការបង្ហាញអំពីលក្ខខណ្ឌទូទៅដូចជា (១) មានជម្លោះប្រដាប់អាវុធ (២) ជម្លោះប្រដាប់អាវុធមានលក្ខណៈអន្តរជាតិ (៣) អត្ថិភាពនៃទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ (៤) ជនរងគ្រោះមានឋានៈជា «បុគ្គលដែលត្រូវបានការពារ»ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវនិង (៥) ការដឹងឮរបស់ជនជាប់ចោទ។

**៣២៨.** អត្ថិភាពនៃជម្លោះប្រដាប់អាវុធ៖ មាត្រា២រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវចែងថាបទប្បញ្ញត្តិនានានៃ

អនុសញ្ញា (រួមទាំង បទប្បញ្ញត្តិស្តីពីជម្លោះប្រដាប់អាវុធផ្សេងទៀតដែលអាចកើតមានឡើងរវាងរដ្ឋជាភាគីចំនួនពីរឬច្រើនទោះបីជាស្ថានភាពនៃសង្គ្រាមមិនត្រូវបានទទួលស្គាល់ដោយរដ្ឋជាភាគីទាំងនោះក៏ដោយ»។ «ជម្លោះប្រដាប់អាវុធ» កើតមានឡើងនៅពេលណាដែលមានការដោះស្រាយដោយប្រើកម្លាំងប្រដាប់អាវុធរវាងរដ្ឋនានា (នៅពេលដែលជម្លោះប្រដាប់អាវុធមានលក្ខណៈអន្តរជាតិ) ឬ មានអំពើហិង្សាប្រដាប់អាវុធអូសបន្លាយរវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធ ឬរវាងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធទាំងអស់នោះនៅក្នុងរដ្ឋមួយ (នៅពេលដែលជម្លោះប្រដាប់អាវុធជាជម្លោះផ្ទៃក្នុង)។

**៣២៩.** លក្ខណៈអន្តរជាតិនៃជម្លោះប្រដាប់អាវុធ៖ មាត្រា២រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវកំណត់បន្ថែមថា ជម្លោះប្រដាប់អាវុធត្រូវមានលក្ខណៈជាអន្តរជាតិ។ ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ ក្នុងករណីដែលជម្លោះកើតមានឡើងរវាងរដ្ឋចំនួនពីរឬច្រើន។ បើទោះបីជាមិនមានការទទួលស្គាល់ជាផ្លូវការពីរដ្ឋដែលមានសង្គ្រាមក៏ដោយ ប៉ុន្តែបទប្បញ្ញត្តិស្តីពីការបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅតែអាចយកមកអនុវត្តបានដដែរ។ ដូចគ្នានេះដែរ ការប្រយុទ្ធគ្នាដែលកើតមានឡើងតាមព្រឹត្តហេតុ រវាងរដ្ឋពីរឬច្រើន អាចបំពេញលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវលក្ខខណ្ឌជាអន្តរជាតិ ក្នុងករណីដែលការប្រយុទ្ធគ្នានោះកើតមានឡើងរវាងកម្លាំងរបស់រដ្ឋរៀងៗខ្លួន។ នៅពេលដែលគេអាចបញ្ជាក់បានថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិបានកើតឡើងនៅកន្លែង និងក្នុងអំឡុងពេលពាក់ព័ន្ធនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនោះ ច្បាប់មនុស្សធម៌អន្តរជាតិនឹងត្រូវយកមកអនុវត្តនៅលើដែនដីទាំងមូលរបស់រដ្ឋ ដែលជាប់ពាក់ព័ន្ធ ទោះបីជាការប្រយុទ្ធគ្នានោះកើតឡើងនៅទីនោះ ឬមិនមានក៏ដោយ ហើយច្បាប់នេះ នឹងបន្តអនុវត្តក្រោយពេលនៃការឈប់បាញ់គ្នារហូតទទួលបានសន្តិភាពជាទូទៅ។

**៣៣០.** ចំណងទាក់ទងរវាងការប្រព្រឹត្តរបស់ជនជាប់ចោទនិងជម្លោះប្រដាប់អាវុធ៖ ត្រូវតែមានចំណងទាក់ទងគ្រប់គ្រាន់រវាងការប្រព្រឹត្តរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធដែលនាំឲ្យមានអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ។ ដើម្បីបញ្ជាក់ថា ទំនាក់ទំនងនេះកើតមានឡើង អំពើប្រព្រឹត្តរបស់ជនជាប់ចោទត្រូវតែមាន «ភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធ» ទៅនឹងជម្លោះប្រដាប់អាវុធទាំងមូល។ បទល្មើសអាច «ស្ថិតនៅឆ្ងាយពីការវាយប្រយុទ្ធគ្នាជាក់ស្តែង បើគិតទាំងពេលវេលានិងទីតាំងភូមិសាស្ត្រ» ហើយវានឹងមានលក្ខណៈគ្រប់គ្រាន់ក្នុងករណីដែលបទល្មើសនោះពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការប្រយុទ្ធគ្នាដែលកើតឡើងនៅកន្លែងផ្សេងៗទៀតនៃទឹកដីដែលគ្រួតត្រាដោយភាគីនៃជម្លោះ។ ទោះបីជាទំនាក់ទំនងនោះ ពុំចាំបាច់ជាទំនាក់ទំនងហេតុនិងបច្ច័យក៏ដោយ យ៉ាងហោចណាស់អត្ថិភាពនៃជម្លោះប្រដាប់អាវុធត្រូវរួមចំណែកយ៉ាងសំខាន់នៅក្នុងសមត្ថភាពរបស់ចារីក្នុងការប្រព្រឹត្តបទល្មើសនៅក្នុងសេចក្តីសម្រេចប្រព្រឹត្តបទល្មើស របៀបដែលបទល្មើសត្រូវបានប្រព្រឹត្ត ឬគោលបំណងដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង។

**៣៣១.** ជនរងគ្រោះមានឋានៈជា «បុគ្គលដែលទទួលបានការពារការ»៖ បុគ្គលដែលត្រូវបានទទួលបានការការពារ» មានចែងក្នុងមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III (ពាក់ព័ន្ធនិងឈ្លើយសឹក) និងអនុសញ្ញាទីក្រុងហ្សឺណែវ IV ឈ្លើយសឹកគឺជាជនទាំងឡាយរួមទាំង «សមាជិកនានានៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីដែលមានជម្លោះ» ព្រមទាំង «សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីដែលមានជម្លោះ» ព្រមទាំង «សមាជិកនៃកងជីវពល ឬទាហានស្ម័គ្រចិត្តដែលជាផ្នែកនៃកងកម្លាំងប្រដាប់អាវុធនោះ» ដែលបាន «ធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ»។ មាត្រា៤ (១) នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV កំណត់បុគ្គលដែលត្រូវទទួលបានការពារថា ជាជនទាំងឡាយដែល «ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះ ឬដែលបានការពារថា ជាជនទាំងឡាយណា «ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះឬដែលកាន់កាប់អំណាចដែលពួកគេមិនមែនជាប្រជាជាតិដូចគ្នា»។

**៣៣២.** *សហព្រះរាជអាជ្ញាលើកឡើងថា និយមន័យនៃបុគ្គលដែលត្រូវទទួលបានការការពាររួមបញ្ចូលទាំងជនជាតិវៀតណាមដែលជាពលរដ្ឋខ្មែរ ប៉ុន្តែត្រូវអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យចាត់ទុកថាជាខ្មាំងដែលមានសម្ពន្ធភាពជាមួយនឹងវៀតណាម។ ភាគីដើមបណ្តឹងមិនបានលើកទឡ្ហីករណ៍ពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាដំណោះស្រាយកំណត់ឲ្យបានច្បាស់ពីប្រភេទនៃ «បុគ្គលដែលត្រូវទទួលបានការការពារ» នៅក្នុងសំណុំរឿង០០២ ដោយសំដៅទៅត្រឹម «សមាជិកកងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋខ្មែរ ប៉ុន្តែមានភក្តីភាពចំពោះវៀតណាមអាចត្រូវបានចាត់ទុកថា ជាបុគ្គលដែលត្រូវទទួលបានការការពារដែរឬទេនោះឡើយ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាត្រូវទុកជាមោឃៈ។*

**៣៣៣.** *មេធាវីការពារក្តី នួន ជា អះអាងថា អនុលោមតាមពិធីសារបន្ថែមទីមួយនៃអនុសញ្ញាទីក្រុងហ្សឺណែវ សមាជិកកងកម្លាំងប្រដាប់អាវុធរបស់ភាគីជម្លោះដែលស្ថិតនៅក្នុងអំណាចរបស់គូបដិបក្ខ ខណៈពេលដែលមានការពាក់ព័ន្ធនៅក្នុងការស៊ើបការណ៍ ពុំត្រូវមានសិទ្ធិទទួលបានឋានៈជាឈ្លើយសឹកឡើយ ហើយអាចចាត់ទុកជាពួកចោរកម្ម។ ហេតុដូច្នេះ ពួកគេស្ថិតនៅក្រៅវិសាលភាពនៃបុគ្គលដែលត្រូវបានការការពារ។ ភាគីដើមបណ្តឹងពុំបានលើកឡើងពីទឡ្ហីករណ៍ពាក់ព័ន្ធនឹងបញ្ហានេះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថា ពិធីសារបន្ថែមទីមួយបានចូលជាធរមាននៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៨ ហើយថា ប្រទេសកម្ពុជាទើបតែបានចូលជាភាគីនៃពិធីសារនេះនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩៨ ប៉ុណ្ណោះ។ លើសពីនេះទៀត ពុំមានការបង្ហាញថាមាត្រា៤៦ (១) នៃពិធីសារបន្ថែមទីមួយ បានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥នោះឡើយ។ ទោះបីជាយ៉ាងណាដោយហេតុថា ពិធីសារបន្ថែមទីមួយមានគោលបំណងផ្តល់ការការពារខ្លាំងបន្ថែមទៀតដល់ជនជាប់ចោទនោះ អនុលោមតាមគោលការណ៍ស្តីពីការអនុវត្តច្បាប់ដែលស្រាលជាង អង្គជំនុំជម្រះនិងពិចារណាទៅលើបទប្បញ្ញត្តិនៃពិធីសារបន្ថែមទីមួយចំពោះបញ្ហានេះ។*

**៣៣៤.** *អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តី នួន ជា យល់ខុសចំពោះអត្ថន័យនិងសារសំខាន់នៃមាត្រា ៤៦ (១) នៃពិធីសារបន្ថែមទីមួយនេះ។ ទោះបីជាបទប្បញ្ញត្តិនេះកំណត់ថា បុគ្គលដែលពាក់ព័ន្ធនៅក្នុងការស៊ើបការណ៍បាត់បង់ឋានៈជាឈ្លើយសឹកហើយ «អាចត្រូវបានចាត់ទុកជាពួកចារកម្ម» ក៏ដោយក៏បទប្បញ្ញត្តិនេះមិនបានដកបុគ្គលទាំងនេះចេញពីការការពាររបស់អនុសញ្ញាទីក្រុងហ្សឺណែវឡើយ។ បុគ្គលដែលបាត់បង់ឋានៈជាឈ្លើយសឹកនៅតែទទួលបានការការពារដូចបានកំណត់នៅក្នុងការធានាមូលដ្ឋានដែលមានចែងនៅក្នុងមាត្រា៧៥ នៃពិធីសារបន្ថែមទីមួយនេះ។ សេចក្តីអត្ថាធិប្បាយអំពីសារបន្ថែមទីមួយកត់សម្គាល់ថា «ការដកហូតឋានៈជាឈ្លើយសឹក គឺជាការដាក់ទណ្ឌកម្មរួចទៅហើយ ដូច្នេះហើយការដកហូតនេះអាចកើតមានឡើងតែក្រោយពីមានសេចក្តីសម្រេចរបស់តុលាការប៉ុណ្ណោះ» ហើយថា «សច្ចធាការណ៍នៃឋានៈជាឈ្លើយសឹកគួរតែមានលើសលប់នៅគ្រប់ករណីទាំងអស់ នៅពេលដែលបុគ្គលពាក់ព័ន្ធមិនទាន់ត្រូវបានចោទប្រកាន់ដោយផ្អែកលើភស្តុតាងបឋម។ អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃទៅលើភស្តុតាងនៅក្នុងរឿងក្តីនេះ ថាតើមានកិច្ចដំណើរការនីតិវិធីបែបណា ដែលបានដកហូតឋានៈជាឈ្លើយសឹកពីបុគ្គលដែលពាក់ព័ន្ធទាំងនេះដែរឬទេ។*

**៣៣៥.** *ការដឹងឮ៖ ជនជាប់ចោទត្រូវមានការដឹងឮយ៉ាងគ្រប់គ្រាន់ថា ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិនិងឋានៈរបស់ជនរងគ្រោះដែលទទួលបានការការពារស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ។ ការដឹងឮរបស់ជនជាប់ចោទរដ្ឋបរទេសមានការពាក់ព័ន្ធនៅក្នុងជម្លោះប្រដាប់អាវុធ និងដឹងថាជនរងគ្រោះត្រូវបានគ្រប់គ្រងដោយភាគីបដិបក្ខក្នុងជម្លោះប្រដាប់អាវុធនោះ នឹងមានលក្ខណៈគ្រប់គ្រាន់សម្រាប់បំពេញនូវលក្ខខណ្ឌដឹងនេះ។ លើសពីនេះទៀត ជនជាប់ចោទយ៉ាងហោចណាស់ «ខ្លួនបានដឹងពីកាលៈទេសៈជាក់ស្តែងដែលនឹងនាំឲ្យចៅក្រមធ្វើការសន្និដ្ឋានថាជម្លោះប្រដាប់អាវុធនោះគឺជាជម្លោះអន្តរជាតិ»។*

***(តនៅលេខក្រោយ)***

# ការពិតមិនអាចប្រកែកបានស្តីពី អំពើប្រល័យពូជសាសន៍នៅកម្ពុជា

*លី សុខឃាង*



កងទ័ពស្ម័គ្រចិត្តវៀតណាមពរកុមារដែលនៅរស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ បន្ទាប់ពីរបបខ្មែរដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (ហូ វ៉ាន់តី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាមិនមែនជារឿងព្រេងនិទាន ហើយក៏មិនមែនជាព័ត៌មានក្លែងក្លាយដែរ។ អំពើប្រល័យពូជសាសន៍នេះ គឺផ្នែកមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដែលមិនអាចប្រកែកបានឡើយ។ យ៉ាងហោចណាស់ ប្រវត្តិសាស្ត្រនេះត្រូវការលំហរមួយសម្រាប់ប្រទេសកម្ពុជាដើម្បីបង្កើនការសិក្សាស្រាវជ្រាវ និងការពិភាក្សាវែកញែកឲ្យបានកាន់តែស៊ីជម្រៅថែមទៀត។ ឧបករណ៍ច្បាប់មួយ ពោលគឺ «ច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ត្រូវបានអនុម័តដើម្បីការពារគថ:ភាពប្រវត្តិសាស្ត្រ។ ប៉ុន្តែ ច្បាប់នេះគឺមិនទាន់គ្រប់គ្រាន់នោះទេ។ ជម្រៅនៃអំពើអាក្រក់ និងអំពើឃោរឃៅទាក់ទងនឹងសោកនាដកម្មយ៉ាងធំធេងចំពោះមនុស្សជាតិនៅក្រោមរបបខ្មែរ

*ក្រហម (១៩៧៥-១៩៧៩) មិនអាចពណ៌នាឲ្យអស់សេចក្តីតាមរយៈច្បាប់មួយឡើយ។ ការស្លាប់មនុស្សប្រមាណជា ២៥ភាគរយ នៃប្រជាជនកម្ពុជាក្នុងរយៈពេលជិត៤ឆ្នាំ មិនអាចវាស់វែងនិងមិនអាចរៀបរាប់ហើយមានលក្ខណៈបុគ្គលទៀតផង ដែលការអត្ថាធិប្បាយការផ្តល់សក្ខីកម្ម និងឯកសារជាច្រើន រួមទាំងអត្ថបទដែលសម្តែងមតិនានា គួរត្រូវបានអានឬស្តាប់ ដើម្បីចាប់ផ្តើមស្វែងយល់នូវរាល់ទង្វើនៃការធ្វើទារុណកម្មនៅក្រោមរបបខ្មែរក្រហម។ អ្នកអត្ថាធិប្បាយដែលមានវិជ្ជាជីវៈផ្សេងៗគ្នានៅក្នុងសង្គម គួរត្រូវបានស្តាប់ និងលើកយកមកពិភាក្សាយ៉ាងល្អិតល្អន់ ព្រមទាំងធ្វើការវិនិច្ឆ័យ។ ទោះយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ក៏មានឥទ្ធិពលខ្លះដែរ ក្នុងការថែរក្សាប្រវត្តិសាស្ត្រនិងកេរដំណែលដាក់ស្តែងរបស់ខ្មែរក្រហម ទប់ស្កាត់នូវរាល់ការព្យាយាមបដិសេធមិនទទួលស្គាល់នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងហាមប្រាមជនទាំងឡាយណាដែលព្យាយាមកេងចំណេញដោយសារតែខ្លួនធ្លាប់ជាផ្នែកមួយនៃរបបខ្មែរក្រហម។ បើទោះជាឧបករណ៍ច្បាប់នេះមិនទាន់គ្រប់គ្រាន់ក៏ដោយ ក៏ច្បាប់នេះបានក្លាយជាបទបញ្ញត្តិដ៏សំខាន់ ដែលគួរតែទទួលបាននូវការសាទរ ស្វែងយល់ និងអនុវត្តទាំងអស់គ្នា។ ព័ត៌មានខ្លះៗទាក់ទងនឹងសាវតាររបស់ច្បាប់នេះអាចជាជំនួយឲ្យបានយល់ថែមទៀត។*

*យោងតាមប្រវត្តិសាស្ត្រ ទួលស្លែង គឺជាមន្ទីរសន្តិសុខ ស-២១ របស់ខ្មែរក្រហមដ៏ល្បីល្បាញដែលដាក់អ្នកទោសប្រមាណជា ១មុឺន ៨ពាន់នាក់។ រឿងរ៉ាវនៃការរកឃើញគុកនេះកើតចេញពីការមកដល់នៃកងទ័ពវៀតណាម រួមកម្លាំងគ្នាជាមួយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានផ្តួលរំលំរបបខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ហូ វ៉ាន់តី ដែលជាកងទ័ពវៀតណាមហើយធ្លាប់ធ្វើការឲ្យស្ថានីយ៍ទូរទស្សន៍វៀតណាម បានព្យាយាមស្វែងរកក្លិនអសោចនៃសាកសពស្អុយរលួយនៅក្នុងទីក្រុងភ្នំពេញ ហើយក៏បានប្រទះឃើញគុកដ៏សាហាវយង់ឃ្នងនេះ។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ពោលគឺ តែបីថ្ងៃប៉ុណ្ណោះបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម អ្នកទាំងឡាយដែលបានចូលទៅមើលគុកនោះតែងតែរៀបរាប់ពីក្លិនស្អាបឈាមនៅជាប់នឹងជញ្ជាំង និងកម្រាលឥដ្ឋ ព្រមទាំងសាកសពស្អុយរលួយនៅទីនោះ។ ប្រវត្តិវិទូ ដេវីដ ឆេនដល័រ បានសរសេរក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា «សំឡេងពីមន្ទីរស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត» ៖ នៅក្នុងខែកុម្ភៈ ឬមីនា ក្នុងឆ្នាំ១៩៧៩ វរសេនីយ៍ឯក ម៉ៃ ឡាំ នៃកងទ័ពវៀតណាម ត្រូវបានប្រគល់ភារកិច្ចរៀបចំឯកសារនានាក្នុងបណ្ណសារដ្ឋានមួយដែលបានរកឃើញនៅមន្ទីរ ស-២១ និងប្រែក្លាយទីកន្លែងនេះឲ្យទៅជាសារមន្ទីរនៃសុបិនអាក្រក់របស់កម្ពុជា (បច្ចុប្បន្ន សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)។ ប្រវត្តិវិទូ ឆេនដល័រ ក៏បានសរសេរទៀតថា៖ «ម៉ៃ ឡាំ ចង់រៀបចំអតីតកាលដែលទើបនឹងកើតឡើងថ្មីៗរបស់ប្រទេសកម្ពុជាឲ្យស្របទៅនឹងតម្រូវការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងអ្នកផ្តល់ដំបូន្មានជាជនជាតិវៀតណាមរបស់របបនេះ ក៏ដូចជាសេចក្តីត្រូវការដ៏យូរអង្វែងនានារបស់ប្រជាជនកម្ពុជា។»*

*កិច្ចការខាងលើនេះតែងតែត្រូវបានបកស្រាយផ្សេងៗគ្នាស្តីពី ថាតើទង្វើរបស់វៀតណាមបានផ្តើមចេញពីភាពអាណិតអាសូរនិងការគោរពចំពោះអ្នកទោសទាំងឡាយដែលត្រូវបានសម្លាប់ឬទទួលរងនូវអំពើទារុណកម្មនៅពីក្រោយជញ្ជាំងគុកនោះ ឬក៏ជាឱកាសក្នុងការបង្ហាញដល់ពិភពលោកទាំងមូលអំពីភាពឃោរឃៅនៃរបបខ្មែរក្រហមយ៉ាងណានោះ។ តាមទស្សនៈជាច្រើន សារមន្ទីរនេះបានក្លាយជាផ្នែកមួយនៃការឃោសនានយោបាយដើម្បីប្រមែប្រមូលការគាំទ្រពីអន្តរជាតិចំពោះសកម្មភាពយោធារបស់វៀតណាមមកលើរដ្ឋអធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ព្រមទាំងហេតុផលដែលបង្ហាញថាវត្តមានដ៏ចាំបាច់របស់ខ្លួនក្នុងការបញ្ចប់អំពើប្រល័យពូជសាសន៍និងខ្សែសង្វាក់នៃអំពើឃោរឃៅរបស់ខ្មែរក្រហម។ ទស្សនៈនេះបានឆ្លុះបញ្ចាំងទៅនឹងគោលជំហរនយោបាយរបស់រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា*

ដែលសរសេរថា៖ «ការអនុវត្តនយោបាយទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍បានក្លាយជានយោបាយជាតិ ដែលទទួលបានការគាំទ្រទាំងខាងក្នុងប្រទេស និងក្រៅប្រទេស។»

នៅឆ្នាំ២០១៣ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ច្បាប់នេះបានចូលជាធរមាន ដែល «មានគោលដៅផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយណាដែលមិនទទួលស្គាល់ ឬសម្រាល ឬបដិសេធ ឬជំទាស់អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬលើកតម្កើងឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ»។ ច្បាប់នេះត្រូវបានអះអាងយ៉ាងទូលំទូលាយថា មានចេតនាសំដៅលើជនទាំងឡាយណាដែលបរិយាយថា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលធ្លាប់ជាមន្ទីរសន្តិសុខស-២១ ឬ គុកដ៏សម្ងាត់បំផុតរបស់ខ្មែរក្រហម គឺជាឆាកដែលរៀបចំឡើងដោយវៀតណាម។ ដូច្នេះហើយកន្លងមកនេះ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងត្រូវបានបកស្រាយផ្សេងៗគ្នាថាជា៖ ទីតាំងឧក្រិដ្ឋកម្ម ដែលទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងឆាកដែលរៀបចំឡើងដោយវៀតណាម។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការជាក់ស្តែង និងបន្ទាន់ក្នុងការធ្វើពង្រាង ពិភាក្សា និងអនុម័តច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងពេលវេលាប៉ុន្មានថ្ងៃតែប៉ុណ្ណោះ មុនពេលការបោះឆ្នោតជាតិ ដែលត្រូវបានគ្រោងរួចជាស្រេចនៅក្នុងឆ្នាំនោះ។ បើទោះជា កាំង ហ្កិចអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថា មានពិរុទ្ធភាពចំពោះការគ្រប់គ្រងមន្ទីរស-



តុលាការប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៩ ក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ តុលាការនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងកាត់ទោសមេដឹកនាំ ប៉ុល ពត និង អៀង សារី ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលមានរយៈពេលប្រាំថ្ងៃតែប៉ុណ្ណោះ។ តុលាការនេះផ្តន្ទាទោសប្រហារជីវិត ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខ និងរឹបអូសយកទ្រព្យសម្បត្តិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

២១ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកាត់ទោសឌុចឲ្យជាប់ពន្ធនាគារអស់មួយជីវិតយ៉ាងណាក៏ដោយ អ្នកអត្ថាធិប្បាយផ្នែកសង្គមនិងនយោបាយបានសម្តែងទស្សនៈយល់ឃើញទទៃពីគ្នាជុំវិញកត្តាជម្រុញទឹកចិត្ត និងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ អ្នកអត្ថាធិប្បាយខ្លះចាត់ទុកច្បាប់នេះថា មានបំណងកេងចំណេញផ្នែកនយោបាយនៅក្នុងការបោះឆ្នោត ខណៈដែលអ្នកអត្ថាធិប្បាយដទៃទៀតយល់ឃើញថាច្បាប់នេះ គឺជាឧបករណ៍មិនចាំបាច់ដើម្បីគ្រាន់តែចង់បញ្ជាក់ការពិតអំពីរបបខ្មែរក្រហម។ អ្នកផ្សេងទៀតបានពណ៌នាច្បាប់នេះថា ជាវិធានការដ៏សំខាន់ក្នុងការធ្វើឲ្យប្រវត្តិសាស្ត្រនៅតែរស់រវើក និងចងចាំជានិច្ច។

ឧបករណ៍ច្បាប់នេះមានផលប្រយោជន៍ជាក់ស្តែងមួយចំនួន។ ជនទាំងឡាយដែលធ្លាប់ចូលរួមដោយផ្ទាល់ជាមួយរបបនេះគួរបង្ហាញនូវភាពខ្សឹបខ្សួល វិប្បដិសារី និងភាពអាណិតអាសូរ ចំពោះកំហុសឆ្គងទាំងឡាយដែលខ្លួនធ្លាប់បានប្រព្រឹត្តទៅលើជនរងគ្រោះនៃរបបខ្មែរក្រហម។ ការធ្វើបែបនេះគឺជាកាយវិការប្រកបដោយសីលធម៌។ ខាន់ សុវណ្ណស្រីនិច ដែលជាកូនស្រីរបស់អតីតសមាជិកខ្មែរក្រហមម្នាក់ បាននិយាយថា ខ្លួនមិនសូវចាប់អារម្មណ៍ជាមួយច្បាប់នេះទេ ដោយសារតែមនុស្សគ្រប់រូបមិនគួរត្រូវបានបង្ខំឲ្យជឿលើអ្វីមួយឡើយ។ តែទោះយ៉ាងណាក៏ដោយ ស្រីនិច ដែលមានវ័យ១៧ឆ្នាំ នៅតែជឿថា ការរៀនសូត្រពីប្រវត្តិសាស្ត្ររបស់កម្ពុជានេះគឺពិតជាមានសារសំខាន់សម្រាប់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត៕



អគារសម្រាប់ឃុំឃាំងអ្នកទោស នៅអតីតមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ (សារមន្ទីរទួលស្លែង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ម៉ី មុន្នីរដ្ឋ ៖ សិស្ស



ម៉ី មុន្នីរដ្ឋ នៅខាងឆ្វេង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ម៉ី មុន្នីរដ្ឋ បានរៀបរាប់ប្រាប់ថា ៖**

ខ្ញុំគឺជាកូនប្រុសច្បងក្នុងចំណោមកូនទាំងប្រាំមួយនាក់នៅក្នុងគ្រួសារ។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ី សំអុល គឺជាគិលានុបដ្ឋាកនៅក្នុងមន្ទីរពេទ្យរដ្ឋមួយនៅក្នុងទីក្រុងភ្នំពេញ។ ដោយសារតែគាត់គឺជាមនុស្សដែលមានចិត្តសប្បុរស ពេលខ្លះគាត់ព្យាបាលអ្នកជំងឺដោយពុំគិតគូប្រាក់កម្រៃឡើយ។ ម្តាយរបស់ខ្ញុំឈ្មោះ មេន ម៉ាលីន គឺជាគ្រូបង្រៀនសាលាបឋមសិក្សាមួយ។

នៅដើមឆ្នាំ១៩៧៥ មានការទម្លាក់គ្រាប់បែកយ៉ាងច្រើននៅតាមទីជនបទ។ ដូច្នេះប្រជាជនដែលរស់នៅតាមតំបន់ស្រុកស្រែចម្ការ បានចាប់ផ្តើមផ្លាស់ទីមកកាន់ទីក្រុងភ្នំពេញ។ ប្រជាជនមួយចំនួនបានរស់ក្នុងវត្ត និងទីកន្លែងសាធារណៈផ្សេងទៀត ដូចជានៅមន្ទីរពេទ្យដែលឪពុករបស់ខ្ញុំធ្វើការ។ តម្លៃម្ហូបអាហារមានការកើនឡើងជារៀងរាល់ថ្ងៃ។

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំគឺជាសិស្សម្នាក់ដែលមានអាយុ១២ឆ្នាំ។ នៅថ្ងៃនោះទាហានលន់ នល់ ភ័យស្លន់ស្លោរត់នៅតាមដងផ្លូវ។ ទាហានខ្លះបានផ្លាស់ប្តូរសម្លៀកបំពាក់ទៅជាជនស៊ីវិល។ ខ្ញុំដឹងរឿងនេះ

ដោយសារខ្ញុំបានឃើញសម្លៀកបំពាក់ឯកសណ្ឋានកងទ័ពជាច្រើននៅលើដីក្បែរមន្ទីរពេទ្យ។

ឪពុករបស់ខ្ញុំ និងមិត្តភក្តិរបស់គាត់ពីរនាក់ទៀតបានកាត់សម្លៀកបំពាក់ឯកសណ្ឋានគ្រូពេទ្យរបស់ពួកគាត់ធ្វើជាទង់ពណ៌ស ហើយបង្ហូតវាឡើងទៅលើដងទង់ជាតិរបស់មន្ទីរពេទ្យ។ គាត់ប្រាប់ខ្ញុំថា ទង់ពណ៌សនេះ គឺជាសញ្ញាដែលបញ្ឈប់ពីការចុះចាញ់របស់យើង។ ខ្ញុំឈរនៅពីមុខមន្ទីរពេទ្យមើលរថក្រោះនិងឡានកំពុងបើកបរនៅលើផ្លូវ។ បន្ទាប់មកទៀត ខ្ញុំបានឮសូរសំឡេងកញ្ចក់ធ្លាក់បែកខ្ចាយ និងបានឃើញយោធាខ្មែរក្រហមកំពុងវាយកម្ទេចបំផ្លិចមន្ទីរពេទ្យទាំងអស់។

នៅពេលយោធាខ្មែរក្រហមឃើញឪពុករបស់ខ្ញុំ យោធាទាំងនោះបានយកកាំភ្លើងភ្ជង់ថ្ងាសឪពុករបស់ខ្ញុំហើយស្រែកសួរថា តើមានលាក់ទាហាន លន់ នល់ នៅក្នុងមន្ទីរពេទ្យនេះដែរឬទេ។ យោធាខ្មែរក្រហមទាំងនោះ បានដើររុករក ប៉ុន្តែរកមិនឃើញមានអ្វីទេ។ យោធាម្នាក់ក្នុងចំណោមយោធាខ្មែរក្រហមទាំងនោះ បានប្រាប់ឪពុករបស់ខ្ញុំថា ក្រុមគ្រួសាររបស់ខ្ញុំត្រូវតែចាកចេញពីទីក្រុងរយៈពេលបីទៅបួនថ្ងៃ ព្រោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក។

យោធានោះបាននិយាយទៀតថា អ្នកជំងឺទាំងអស់ដែលអាចដើរបានគួរតែចាកចេញពីមន្ទីរពេទ្យ។ បន្តិចក្រោយមក យោធាខ្មែរក្រហមបានចូលទៅក្នុងមន្ទីរពេទ្យហើយទាញផ្តាច់ខ្សែសេរ៉ូមរបស់អ្នកជំងឺដែលកំពុងសម្រាកព្យាបាល រួចបាញ់សម្លាប់អ្នកជំងឺទាំងនោះចោល។

ឪពុករបស់ខ្ញុំបាននាំក្រុមគ្រួសារដោយជិះឡានសង្គ្រោះបន្ទាន់មួយឆ្ពោះទៅទិសខាងលិច គឺព្រលានយន្តហោះពោធិចិនតុង ប៉ុន្តែពេលនោះយោធាខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើដំណើរទៅភាគខាងជើងនៅតាមបណ្តោយដងផ្លូវដ៏តូចចង្អៀតវិញ។ ដូច្នេះ យើងត្រូវតែបោះបង់រថយន្តសង្គ្រោះបន្ទាន់នោះចោល ហើយយួររបស់ណាដែលសំខាន់និងចាំបាច់ ដូចជា អង្ករជាដើម។ ខ្ញុំមិនអាចជួយអ្វីបានទេ ព្រោះខ្ញុំមានជំងឺស្ពឹកដៃជើង។ ពេលខ្ញុំនៅតូចខ្ញុំមិនអាចដើរបានដោយគ្មានឈើច្រត់បានឡើយ។

ភូមិដែលយើងបានទៅដល់ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។ ប្រជាជនមូលដ្ឋាននិងយោធានៅទីនោះមានសន្តានចិត្តល្អ និងសុភាពរាបសា។ យើងហូបចុកគ្រប់គ្រាន់ ព្រោះមានបឹងដ៏ធំមួយជាទីកន្លែងដែលយើងអាចចាប់ត្រីបាន។

បីខែក្រោយមក យើងត្រូវបានផ្លាស់ប្តូរទីលំនៅទៅខេត្តពោធិ៍សាត់។ ឪពុកម្តាយរបស់ខ្ញុំធ្វើការនៅសហករណ៍ទីនោះ ចំណែកខ្ញុំនៅកងឃ្វាលគោ។ យើងអាចជួបគ្នាបានរហូតដល់យប់ជ្រៅអំឡុងពេលប្រជុំស្វ័យទិតៀន។ កម្មាភិបាលខ្មែរក្រហមដែលមានអាយុប្រហែលខ្ញុំ គឺជាអ្នកបង្រៀនអ្នកភូមិទាំងអស់។ ជំនួសឲ្យការហៅម្តាយរបស់អ្នកថា «ម៉ែ» អ្នកត្រូវហៅគាត់ថា «សមមិត្តម៉ែ» ហើយជំនួសឲ្យការប្រើពាក្យគួរសម «ញ៉ាំ» ឬ «ពិសា» យើងត្រូវនិយាយពាក្យ «ហូប» ជំនួសវិញ។ ខ្មែរក្រហមបាននិយាយថា ពាក្យទាំងនោះជាពាក្យមូលធននិយម និងមានផលប៉ះពាល់ ដូច្នេះយើងត្រូវតែលុបបំបាត់ចោល។

នៅក្នុងឆ្នាំ១៩៧៦ អង្គការបានរៀបចំបងប្អូនជីដូនមួយរបស់ខ្ញុំបីនាក់ឲ្យរៀបការជាមួយយោធាខ្មែរក្រហមដែលពិការ។ បងប្អូនជីដូនមួយរបស់ខ្ញុំទាំងបីនាក់បានបដិសេធ។ នៅយប់នោះអ្នកទាំងបីត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រ។ នៅព្រឹកថ្ងៃបន្ទាប់ ខ្ញុំបានឮសូរឈ្លបភូមិជជែកគ្នា។

ឈ្លបទាំងនោះនិយាយថា ៖ ពួកគេបានដេកជាមួយនារីព្រហ្មណ៍ចារីបីនាក់ដែលមកពីទីក្រុង បន្ទាប់មកបានយកឈើរុកចូលក្នុងប្រដាប់ភេទរបស់នារីទាំងនោះ។ បន្ទាប់ពីនោះមកស្ត្រីទាំងបីនាក់ពុំអាចដកដង្ហើមបាន ហើយក៏ស្លាប់បាត់បង់ជីវិតទៅ។ ខ្ញុំចង់តែយកឈើច្រត់របស់ខ្ញុំវាយក្បាលយោធាទាំងនោះ ប៉ុន្តែខ្ញុំបានត្រឹមតែទប់កំហឹងនៅក្នុងចិត្តប៉ុណ្ណោះ។ នៅពេលដែលខ្ញុំប្រាប់គ្រួសាររបស់ខ្ញុំនៅអ្វីដែលខ្ញុំបានឮពួកគេបានយំយ៉ាងខ្លាំង។

នៅសប្តាហ៍បន្ទាប់ គ្រួសាររបស់ខ្ញុំត្រូវបានផ្លាស់ទៅកាន់ភូមិថ្កុល គឺជាទីកន្លែងដែលខ្មែរក្រហមដាក់ទណ្ឌកម្មទៅលើប្រជាជនថ្មី។ ឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅប៉ែកខាងត្បូងភូមិ។ វាគឺជាទីកន្លែងមួយសម្រាប់ដាក់អ្នកទោសធ្ងន់ធ្ងរ។ ចំណែកយើងដែលនៅសល់ត្រូវបានបញ្ជូនទៅប៉ែកខាងជើងដែលជាកន្លែងសម្រាប់ដាក់អ្នកទោសស្រាល។

យើងរស់នៅសហករណ៍នៅទីនេះ។ យើងមិនត្រូវបានអនុញ្ញាតឲ្យហូបឯកជន ហើយត្រូវប្រគល់របស់មានតម្លៃទាំងអស់ទៅឲ្យអង្គការដាក់ជាកម្មសិទ្ធិរួមជាពិសេសនាឡិកាដៃ។

នៅពេលដំបូងដែលយើងទៅដល់ភូមិថ្កុល មានប្រជាជនប្រហែល ២០០០នាក់ ហើយក្នុងចំណោមប្រជាជនទាំងនោះពាក់កណ្តាលត្រូវបានសម្លាប់នៅអំឡុងពេលរស់នៅទីនោះ។

ប្អូនស្រីរបស់ខ្ញុំម្នាក់បានលួចកាច់ពោតនៅពេលដែលនាងឃ្លាន។ កម្មាភិបាលខ្មែរក្រហមបានវាយនាងនឹងចបកាប់ ហើយកប់នាងនៅក្បែរចម្ការពោតនោះ។ បន្ទាប់ពីការស្លាប់របស់ប្អូនស្រីខ្ញុំ អង្គការបានចោទខ្ញុំថាមានទំនាក់ទំនងជាមួយនឹងខ្មាំង។ ខ្មែរក្រហមបានផ្លាស់ខ្ញុំចេញពីរោងបាយឲ្យទៅឃ្វាលគោ។

ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងដេញគោនៅក្បែរព្រៃ ខ្ញុំបានធំក្លិនសាកសពស្អុយរលួយ។ ខ្ញុំចូលទៅលបមើលក្នុងព្រៃនោះ ក៏បានឃើញសាកសពឪពុករបស់ខ្ញុំ។ ក្បាលរបស់គាត់នៅក្បែរនោះត្រូវបានគាត់ផ្តាច់ចេញពីខ្លួនរបស់គាត់ដោយកាំបិត។ ខ្ញុំបានគោរពសាកសពរបស់គាត់ ហើយយំដោយគ្មានសំឡេងព្រោះខ្ញុំភ័យខ្លាចអង្គការឮ។ នៅយប់នោះខ្ញុំស្នើសុំប្រធានភូមិយកបាយក្រៀម និងសំបកដំឡូងជ្វាទៅឲ្យម្តាយខ្ញុំ។ ខ្ញុំចង់ឲ្យគាត់បានហូបវា នៅពេលដែលខ្ញុំនាំព័ត៌មាននេះទៅប្រាប់គាត់។ គាត់បានយំបន្ទាប់ពីខ្ញុំប្រាប់អំពីការរកឃើញសាកសពឪពុករបស់ខ្ញុំ បន្ទាប់មកគាត់ក៏បានហូបបាយក្រៀមនោះ។

លោកយាយរបស់ខ្ញុំ គឺជាអ្នកបន្ទាប់ដែលបានស្លាប់។ គាត់មានអាយុ ៧០ឆ្នាំ ហើយគាត់គឺជាអ្នកមើលថែក្មេងតូចៗ។ ក្មេងវ័យជំទង់ម្នាក់បានប្រាប់ខ្ញុំថា លោកយាយរបស់ខ្ញុំត្រូវបានចោទប្រកាន់ពីបទលួចបបររបស់ក្មេងៗ។ ដោយហេតុនេះ ប្រធានភូមិបានវាយគាត់នឹងដំបង។ ខ្ញុំបានរត់ទៅផ្ទះរបស់គាត់ និងបានឃើញស្ត្រីចំណាស់២នាក់កំពុងជីករណ្តៅកប់គាត់។ ខ្ញុំបានមកទាន់ពេល ហើយក៏គោរពសាកសពរបស់គាត់។

ចាប់តាំងពីសមាជិកគ្រួសាររបស់ខ្ញុំបានស្លាប់ជាបន្តបន្ទាប់ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ភ័យខ្លាចរបបមួយនេះ និងព្រួយបារម្ភខ្លាចបាត់បង់ម្តាយរបស់ខ្ញុំម្នាក់ទៀត។ ការភ័យខ្លាចរបស់ខ្ញុំបានក្លាយទៅជាការពិត។ នៅព្រឹកព្រលឹមថ្ងៃមួយ ស្ត្រីម្នាក់បានមកប្រាប់ខ្ញុំថា ម្តាយរបស់ខ្ញុំពិបាកដកដង្ហើម។ ពីដំបូងប្រធានកងចល័តរបស់ខ្ញុំមិនអនុញ្ញាតឲ្យខ្ញុំទៅជួបម្តាយរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំបានសុំអង្វរគាត់រហូតដល់គាត់យល់ព្រម។ ខ្ញុំបាននៅជាមួយម្តាយរបស់ខ្ញុំរហូតដល់គាត់ផុតដង្ហើម។ សម្រាប់ខ្មែរក្រហម ការស្លាប់របស់ម្តាយខ្ញុំគឺប្រៀបដូចជាសត្វក្អែ ឬ ឆ្មាមួយក្បាល។ វាមិនមានអ្វីសំខាន់ឡើយ ហើយគ្មានពិធីបុណ្យសព គ្មានព្រះសង្ឃគឺគ្មានអ្វីទាំងអស់។ បន្ទាប់មក ប្អូនបង្កើត៤នាក់ទៀតរបស់ខ្ញុំបានស្លាប់ក្នុងពេលតំណាលៗគ្នាដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ។ រាងកាយរបស់ពួកគេហើម ហើយមើលទៅមិនដូចជាមនុស្សទេ។ ពួកគេបានទទួលយកថ្នូរ ព្រោះស្បែករបស់ពួកគេតឹងខ្លាំង។

**ប៉ាង ពីច័ន្ទ និង ទេនី ខករហ្គៀល**

## «ផេះផង់ធូលី»
## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# សោម សីលា និង ឡាំ សេណា ៖ និស្សិត

***រៀបរាប់ដោយប្អូនស្រីរបស់គាត់ឈ្មោះ ឡាំ ដារ៉ារិទ្ធិ ៖***



ឡាំ សេណា នៅថ្ងៃទទួលសញ្ញាបត្រផ្នែកឱសថសាស្ត្រ នៅឆ្នាំ១៩៧៣។ នៅខាងស្តាំដៃរបស់ ឡាំ សេណា គឺជាម្តាយរបស់គាត់ បន្ទាប់មកកូន និងប្រពន្ធរបស់គាត់ និងនៅខាងឆ្វេងដៃរបស់ ឡាំ សេណា គឺជាឪពុករបស់គាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនៗទាំងអស់នៅក្នុងគ្រួសាររបស់យើងបានខិតខំប្រឹងប្រែងរៀនសូត្រ ហើយយើងទាំងអស់គ្នាចូលចិត្តខាងផ្នែកវិទ្យាសាស្ត្រ។ បងប្រុសច្បងរបស់ខ្ញុំឈ្មោះ សោម សីលា មានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកវិស្វកម្មសេដ្ឋកិច្ចមកពីប្រទេសយូហ្គោស្លាវី ហើយបងប្រុសទីពីររបស់ខ្ញុំ ឈ្មោះ ឡាំ វ៉ារី មានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកវិស្វកម្មសំណង់ស៊ីវិលមកពីប្រទេសរុស្ស៊ី។ បងប្រុសទីបីរបស់ខ្ញុំ ឈ្មោះ ឡាំ សេណា ទទួលបានសញ្ញាបត្រផ្នែកវេជ្ជសាស្ត្រមកពីប្រទេសបារាំង ហើយបងប្អូនប្រុសចញ្ចឹមរបស់ខ្ញុំឈ្មោះ កន សេរីសម្បត្តិ ក៏ទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកច្បាប់មកពីប្រទេសបារាំងដែរ។

ខ្ញុំមិនបានចងចាំច្បាស់លាស់អំពីបងប្រុសច្បងពីរនាក់របស់ខ្ញុំនោះទេ។ អ្នកទាំងពីរបានចាកចេញពីប្រទេសកម្ពុជា ដើម្បីទៅសិក្សានៅបរទេសនៅពេលដែលខ្ញុំមានអាយុ៧ឬ៨ឆ្នាំ។ នៅពេលដែលខ្ញុំបានឃើញរូបថតរបស់បង សីលា ដំបូង ខ្ញុំបានសួរទៅកាន់ម្តាយរបស់ខ្ញុំថា តើគាត់គឺជានរណា? ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា «អ៎! នោះគឺជាថ្ងៃដែល សីលា បានចាកចេញទៅប្រទេសយូហ្គោស្លាវី»។

ខ្ញុំមិនបានចងចាំថាបង វ៉ារី មានរូបរាង និងមុខមាត់ដូចអ្នកណាទេ ព្រោះមិនមានរូបថតរបស់គាត់នៅសេសសល់។ ម្តាយរបស់ខ្ញុំបាននិយាយថា បង សីលា មិនសូវពូកែនិយាយស្តីទេ ហើយក៏មិនទាន់រៀបការដែរ ប៉ុន្តែបង វ៉ារី និយាយច្រើនណាស់។ បង វ៉ារី បានរៀបការជាមួយនារីរុស្ស៊ី ហើយគាត់មានកូនស្រីម្នាក់។

បង សេណា បានបញ្ចប់ការសិក្សាផ្នែកវេជ្ជបណ្ឌិតរបស់គាត់នៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ បន្ទាប់មកគាត់ទទួលបានអាហារូបករណ៍ទៅសិក្សាផ្នែកថ្នាំពេទ្យកុមារនៅប្រទេសបារាំង។ គាត់បានរៀបការមុនពេលដែលគាត់ចាកចេញពីប្រទេសកម្ពុជា និងមានកូនពីរនាក់។ បង សេណា មានសំណាងជាងបង សីលា និងបង វារី ព្រោះគាត់ទទួលបានព័ត៌មាននៅក្នុងប្រទេសបារាំងច្រើនជាងអ្នកដែលសិក្សានៅប្រទេសយូហ្គោស្លាវី និងប្រទេសរុស្ស៊ី។ ដូច្នេះនៅពេលដែលខ្មែរក្រហមប្រកាសថានិស្សិតដែលកំពុងរស់នៅក្រៅប្រទេសគួរតែវិលត្រឡប់មកកម្ពុជាដើម្បីជួយកសាងប្រទេសសាជាថ្មី បងសេណាមិនជឿការឃោសនាទាំងនោះឡើយ ហើយគាត់បានបន្តស្នាក់នៅអឺរ៉ុប។ បងប្រុសរបស់ខ្ញុំពីរនាក់ផ្សេងទៀតបានជឿជាក់នូវអ្វីដែលខ្មែរក្រហមបានឃោសនា ព្រោះគាត់ទាំងពីរនាក់បានមកដល់ផ្ទះរួចមកហើយ។

ក្នុងចំណោមបងប្អូនរបស់ខ្ញុំដែលនៅសេសសល់ ក្រៅពីបងប្អូនដែលមានការអប់រំខ្ពស់នៅបរទេសក៏ត្រូវបានរំខានដោយក្រុមខ្មែរក្រហមដែរ។ បងប្រុសទីប្រាំរបស់ខ្ញុំ ឈ្មោះ ឡាំ តាំង ធរណី គឺមានភាពវៃឆ្លាតខ្លាំងណាស់។ គាត់គឺជាអ្នកដែលនាំបងប្អូនស្រីរបស់ខ្ញុំ និងខ្ញុំឆ្ពោះទៅកាន់ភូមិជីតារបស់ខ្ញុំ នៅពេលដែលយើងត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ។ យើងមិនប្រាកដថាតើគាត់រកឃើញភូមិជីតាដោយរបៀបណានោះទេ ព្រោះយើងធ្វើដំណើរតាមផ្លូវក្រោយដើម្បីជៀសវាងកុំឲ្យអង្គការចាប់បាន។ ប៉ុន្តែ ធរណី បានដឹងថាផ្លូវមួយណាទៅដល់ភូមិដោយស្ទាបដើម




តាំង ធរណី នៅទីក្រុងហូជីមិញនៅឆ្នាំ១៩៧៩។ គាត់បានធ្វើដំណើរទៅប្រទេសវៀតណាម ដើម្បីស្រាវជ្រាវរកដំណឹងបងប្រុសរបស់គាត់ដែលបានបាត់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឈើ។ ប្រសិនបើដើមឈើក្តៅនៅផ្នែកខាងណានៅពេលរសៀល ផ្នែកក្តៅនោះគឺជាទិសខាងលិច។

ធរណី បានសិក្សានៅមហាវិទ្យាល័យសេដ្ឋកិច្ចក្នុងរាជធានីភ្នំពេញ ហើយក៏ទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុន។ ប៉ុន្តែគាត់និយាយថា គាត់អត់ទៅជប៉ុនទេ គាត់ចង់ទៅសិក្សាជាមួយបងប្រុសឈ្មោះ សេណា នៅប្រទេសបារាំងវិញ។ ពីដំបូងគាត់បានរង់ចាំបងប្រុសរបស់ខ្ញុំដើម្បីរកសាកលវិទ្យាល័យសម្រាប់គាត់ បន្ទាប់មកគាត់បានបំពេញឯកសារទាំងអស់រួចហើយក៏បានផ្ញើវាទៅសាលាដែរ។ សាលាបានទទួលពាក្យរបស់គាត់ និងបានជូនដំណឹងមកគាត់វិញមួយថ្ងៃមុនពេលដែលខ្មែរក្រហមមកដល់ទីក្រុងភ្នំពេញ។ គាត់មានការខកចិត្តយ៉ាងខ្លាំង ប៉ុន្តែវាគឺជាកម្មពាររបស់គាត់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ពេលនោះរដ្ឋបានបើកទ្វាគុកទួលស្លែងឲ្យសាធារជនចូលទៅមើលនៅខាងក្នុង ហើយខ្ញុំក៏បានចូលទៅទីនោះដែរ។ ខ្ញុំបានឃើញរូបថតបងប្រុសរបស់ខ្ញុំនៅទីនោះ ហើយក្រោយមកខ្ញុំក៏បានយករូបថតនោះមកឲ្យម្តាយខ្ញុំ។ គាត់បាន



សោម សីលា ទើបនឹងទៅដល់ប្រទេសយូហ្គោស្លាវីដើម្បីបន្តការសិក្សា នៅឆ្នាំ១៩៦៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សោម សីលា នៅឯព្រលានយន្តអន្តរជាតិពោធិ៍ចិនតុងនៅថ្ងៃដែលគាត់ចាកចេញទៅប្រទេសយូហ្គោស្លាវី នៅឆ្នាំ១៩៦៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យំហើយយំទៀតរហូតស្ទើរតែសន្លប់។ គាត់តែងតែគិតថា បងប្រុសរបស់ខ្ញុំគឺនៅរស់រានមានជីវិតនៅឡើយ សូម្បីតែគ្រូទាយក៏និយាយដូច្នេះដែរ។ បងប្រុសរបស់ខ្ញុំឈ្មោះ ធរណី បានទៅប្រទេសវៀតណាមបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបញ្ចប់ ដើម្បីស្រាវជ្រាវរកព័ត៌មានរបស់បងប្អូនគាត់ ប៉ុន្តែមិនបានទទួលដំណឹងសោះឡើយ។

ឡាំ សេណា បានរស់នៅ និងជាឱសថការីនៅប្រទេសបារាំងរហូតដល់ឆ្នាំ២០០៣ នៅពេលដែលគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ។

ឡាំ តាំងធរណី បានផ្លាស់ទៅរស់នៅសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ១៩៨៤ ហើយក៏មិនដែលវិលត្រឡប់មកប្រទេសកម្ពុជាដែរ។

សោម សីលា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៧ នៅពេលដែលគាត់វិលត្រឡប់មកប្រទេសកម្ពុជា បន្ទាប់ពីបានបញ្ចប់ការសិក្សានៅប្រទេសយូហ្គោស្លាវីចាប់តាំងពីឆ្នាំ១៩៦៤។ គាត់បានស្លាប់នៅគុកទួលស្លែងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៧។ ប្អូនប្រុសរបស់គាត់ឈ្មោះ ឡាំ វ៉ារី ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ គាត់បានវិលត្រឡប់មកប្រទេសកម្ពុជា បន្ទាប់សិក្សារយៈពេល១២ឆ្នាំនៅប្រទេសរុស្ស៊ី។ ចម្លើយសារភាពចុងក្រោយរបស់គាត់បានកត់ត្រានៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

**ប៉ាង ពីច័ន្ទ និង ខេនី ខកហ្គៀល**

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ភិន រដ្ឋា ៖ និស្សិត

ខ្ញុំមានស្រុកកំណើតនៅខេត្តតាកែវ ប៉ុន្តែនៅអំឡុងពេលរបប លន់ នល់ គ្រួសាររបស់ខ្ញុំបានរត់ភៀសខ្លួនទៅប្រទេសវៀតណាម ដោយសារតែមិនមានសុវត្ថិភាពនៅក្នុងភូមិរបស់ខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរវៀតណាមបានបញ្ជូនយើងត្រឡប់មកប្រទេសកម្ពុជាវិញ។ យើងបានរស់នៅតាមដងទន្លេក្នុងរាជធានីភ្នំពេញ ជាមួយជនភៀសខ្លួនជាច្រើនទៀត ដោយពឹងផ្អែកទៅលើជំនួយរបស់កាកបាទក្រហមដើម្បីរស់។ កាកបាទក្រហមបានចែកអង្ករ ត្រីងៀត សាប៊ូ ស្ករ ទឹកដោះគោ គ្រែ មុង ភួយ និងកន្ទេលដល់យើង។ ម្ដាយរបស់ខ្ញុំគឺជាស្ត្រីដែលឆ្លាតខ្លាំងណាស់។ កាលណាក្រុមកាកបាទក្រហមបានមកដល់ គាត់ក៏បាននិយាយភាសាបារាំងទៅកាន់ក្រុមកាកបាទក្រហមទាំងនោះ។



ឪពុកម្ដាយរបស់ ភិន រដ្ឋា នៅថ្ងៃរៀបអាពាហ៍ពិពាហ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឪពុករបស់ខ្ញុំបានចូលធ្វើការក្នុងកងរាជអាវុធហត្ថ។ នៅឆ្នាំ១៩៧៤ គាត់មានអារម្មណ៍ថា ស្ថានការណ៍កាន់តែយ៉ាប់យ៉ឺនទៅៗនៅក្នុងប្រទេស ដូច្នេះគាត់បានធ្វើពុតជាមានជំងឺឆ្កួតជ្រូក ទើបគាត់អាចលាឈប់ពីការងារបាន។ នៅទីបំផុតប្រធានរបស់ឪពុកខ្ញុំក៏បានអនុញ្ញាតឲ្យគាត់លាឈប់ពីការងារ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឮស្នូរកាំភ្លើង និងគ្រាប់បែក។ យោធាខ្មែរក្រហមបានស្រែកថា «ប្រជាជនត្រូវតែចាកចេញពីទីក្រុងក្នុងរយៈពេលបីថ្ងៃ ព្រោះអង្គការត្រូវការរៀបចំទីក្រុង។ កុំព្រួយបារម្ភអី»។ ដូច្នេះ យើងបានធ្វើដំណើរដោយថ្មើរជើង ប្អូនស្រីរបស់ខ្ញុំ និងខ្ញុំបានយកខ្សែមកចងដៃគ្នាជាប់ ព្រោះយើងខ្លាចបែកគ្នា។ បីថ្ងៃក្រោយមក មានស្នូរកាំភ្លើងកាន់តែខ្លាំងឡើង ដូច្នេះគ្រួសាររបស់ខ្ញុំបានគិតថា យើងមិនអាចវិលត្រឡប់ទៅភ្នំពេញវិញបានឡើយ។ នៅទីបំផុតយើងក៏បានទៅដល់ខេត្តតាកែវ។

គ្រួសាររបស់យើងបានទៅស្នាក់នៅក្នុងផ្ទះមួយដែលមានដំបូលប្រក់ស្បូវ និងជញ្ជាំងដីឥដ្ឋ។ យើងអាចរស់នៅបានដោយអង្ករដែលយើងបានយកមកពីផ្ទះ រួមជាមួយនឹងក្ដាមខ្យងដែលយើងរកបានពីវាលស្រែ។ ប៉ុន្តែនៅពេលដែលសហករណ៍ចាប់ផ្ដើមបង្កើតឡើង អាហារទាំងអស់គឺជារបស់អង្គការ ហើយយើងអាចបរិភោគឆ្អែតតែនៅពេលរដូវប្រមូលផលតែប៉ុណ្ណោះ។ អង្គការតែងតែហៅប្រជាជនមកប្រជុំទិតៀនអំពីអាហារដែលប្រជាជនបានហូប។ អង្គការបានព្រមានថា អ្នកណាលួចចាប់ខ្ចៅខ្យង ឬបេះបន្លែនឹងត្រូវទទួលទារុណកម្ម។ ប៉ុន្តែដោយសារតែការស្រេកឃ្លាន ដូច្នេះខ្ញុំបានលួចបេះបន្លែជាច្រើនដង។

ឪពុកម្តាយរបស់ខ្ញុំបានធ្វើការនៅខាងឡូតដ្ឋ។ រីឯខ្ញុំគឺធ្វើការនៅក្នុងអង្គភាពកងចល័តកុមារដែលធ្វើការងារនៅឆ្ងាយពីភូមិ។ អង្គការបានអនុញ្ញាតឲ្យខ្ញុំមកលេងឪពុកម្តាយរៀងរាល់បីទៅបួនខែម្តង។ ការងាររបស់ខ្ញុំគឺជីកកណ្តាប់ទៅវាលស្រែ។ កុមារធំៗបានរករឿងខ្ញុំ ហើយខ្ញុំបានវាយតប់ជាមួយ កេះ គឺជាប្រធានកងដែលបានដាក់ទណ្ឌកម្មខ្ញុំយ៉ាងធ្ងន់ធ្ងរ ដូច្នេះខ្ញុំក៏បានរត់ទៅលាក់ខ្លួននៅក្នុងព្រៃអស់រយៈពេល៦ខែ និងបានបេះស្លឹកឈើហូបដើម្បីរស់។ នៅពេលយប់ខ្ញុំបានលួចចូលមកក្នុងភូមិដើម្បីលួចខស ដូច្នេះខ្ញុំអាចបង្កាត់ភ្លើងនៅក្នុងព្រៃដើម្បីចម្អិនត្រីតូចៗហូបបាន។ ខ្ញុំបានរស់នៅក្នុងព្រៃទាំងអត់ឃ្លាន និងវេទនាតែម្នាក់ឯង ហើយនៅពេលដែលខ្ញុំមិនអាចទ្រាំទ្របាន ខ្ញុំក៏បានវិលត្រឡប់ចូលមកក្នុងភូមិវិញ។ ឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំទៅនៅកងចល័តវិញ ប្រសិនបើគាត់មិនធ្វើដូច្នេះទេ គ្រួសាររបស់ខ្ញុំនឹងមានគ្រោះថ្នាក់មិនខានឡើយ។ នៅពេលដែលខ្ញុំបានមកដល់កងចល័ត កេះ បានធ្វើទារុណកម្មខ្ញុំ និងបានព្រមានខ្ញុំមិនឲ្យរត់ចេញពីកងម្តងទៀតទេ។

នាថ្ងៃមួយនៅពេលដែលខ្ញុំសម្រាកបានបន្តិច ស្រាប់តែខ្ញុំបានឃើញផ្លែក្រូចនៅដើមដែលស្ថិតនៅខាងលើក្បាលរបស់ខ្ញុំ។ មានកុមារមូលដ្ឋានម្នាក់បានប្រាប់ខ្ញុំឲ្យបេះផ្លែក្រូចនោះហូប។ ខ្ញុំបានធ្វើតាមកុមារនោះ ហើយពីហូបរួចខ្ញុំបានជូតមាត់យ៉ាងស្អាតដើម្បីកុំឲ្យអ្នកផ្សេងកត់សម្គាល់។ បន្ទាប់មក កេះ បានចោទខ្ញុំពីបទលួចពងមាន់របស់គាត់ហូបកាលពីយប់មុន។ គាត់បានបញ្ជាឲ្យកម្មាភិបាលម្នាក់យកក្រមាមករុំជុំវិញករបស់ខ្ញុំ ហើយបានរឹតកខ្ញុំរហូតដល់ខ្ញុំមិនអាចដកដង្ហើមរួច។ សំណាងល្អ



ភិន រដ្ឋា រូបខាងស្តាំ និង បងស្រី ភិន សុផាណា នៅអំឡុងឆ្នាំ ១៩៧០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានកុមារមូលដ្ឋានម្នាក់បានសុំអង្វរគាត់ឲ្យអត់ទោសដល់ខ្ញុំ ហើយខ្ញុំក៏ត្រូវបានដោះលែងមកវិញ។

ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងដឹកអាចម៍ជ្រូក ខ្ញុំបានដួលកងហើយអាចម៍ជ្រូកនោះក៏ខ្ចាយអស់។ កេះ បានយករំពាត់វាយខ្ញុំ ហើយពេលនោះក៏វាយត្រូវខ្ញុំចំភ្នែករបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមក ភ្នែករបស់ខ្ញុំមើលលែងឃើញច្បាស់ដូចមុន។

ជារឿយៗកម្មាភិបាលបានសួរខ្ញុំអំពីប្រវត្តិគ្រួសារកាលពីអតីតកាល ប៉ុន្តែខ្ញុំមិនដែលប្រាប់ការពិតដល់កម្មា-ភិបាលនោះទេ។ ខ្ញុំបាននិយាយពីជីតារបស់ខ្ញុំ គឺជាកសិករ ឪពុករបស់ខ្ញុំគឺជាអ្នកធាក់ស៊ីក្លូ ចំណែកម្តាយរបស់ខ្ញុំគឺជាអ្នកលក់ផ្កាលីលី។ ជាញឹកញាប់អង្គការបានសួរថា «តើមានអ្នកណាចង់វិលត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញដែរឬទេ?» មានគ្រួសារមួយដែលជាអ្នកជិតខាងរបស់ខ្ញុំនៅឯទីក្រុងភ្នំពេញបានឆ្លើយថាចង់ ហើយអ្នកទាំងនោះត្រូវបានបញ្ជូនត្រឡប់មកផ្ទះវិញ។ គ្រួសារនោះបានបាត់ខ្លួន ហើយអ្នកភូមិបានខ្សឹបប្រាប់ថា អង្គការបានយកគ្រួសារនោះទៅសម្លាប់ចោលទាំងអស់។

នៅមុនឆ្នាំ១៩៧៩ បន្តិចខ្ញុំបានឮស្នូរគ្រាប់ផ្លោង និងគ្រាប់កាំភ្លើងចេញពីទីក្រុងតាកែវ។ កម្មាភិបាលខ្មែរក្រហមបានខ្សឹបប្រាប់ថា សង្គ្រាមអាចនឹងផ្ទុះឡើង។ នៅវេលាម៉ោង១១ព្រឹក ខ្ញុំបានឃើញឡានរថក្រោះជាច្រើននៅតាមបណ្តោយផ្លូវ។ សមាជិកគ្រួសាររបស់ខ្ញុំចាប់ផ្តើមរត់ចេញឆ្ងាយពីយោធាខ្មែរក្រហម។ សំណាងល្អយើងបានជួបកងទ័ពវៀតណាមដែលបានអនុញ្ញាតឲ្យយើងត្រឡប់មកផ្ទះវិញ។

**ប៉ាង ពីច័ន្ទ និង ទេរី ខកហ្គៀល**

# ស្លាបនិកពីរធ្នូ
## (បទភាកគតិ)




ប្រជាជន សិស្សានុសិស្ស គ្រូបង្រៀន កង
កម្លាំងប្រដាប់អាវុធ រដ្ឋអំណាច នៅខេត្តស្វាយរៀង
ប្រារព្ធស្មារតី២ ធ្នូ។ (បណ្ណសារមជ្ឈមណ្ឌល
ឯកសារកម្ពុជា)

១. នឹករឡើងកាលណា ចុកណែនឱរា ចិន្តាចងចាំ
បនក្បត់ខុគ្រិដ្ឋ ឆ្នាំចិតសិបប្រាំ រាស្ត្រខ្មែររងកម្ម
ខាំងបីឆ្នាំប្លាយ។

២. វិបត្តិសែនធ្ងន់ ត្រាំត្រាធុរន់ ពន់អន្តរាយ
ធ្វើស្រែបានស្រូវ តែត្រូវអត់បាយ កូនព្រាត់ពុកម្ដាយ
ឆ្ងាយភាពថ្លៃថ្នូរ។

៣. ទោះជាព្រះសង្ឃ ចាប់ផ្សឹកដោះស្បង់ ឥតមានអាសូរ
លែងគិតបាបបុណ្យ ខានសុន្ទរោ ប្រើដូច សេះ គោ
ខាថ្នូរជីវិត។

៤. រស់សែនលំបាក លំបិនគោកយ៉ាក ហួសពីការគិត
ប្រៀបឋាននរក ខឹងក់ងងឹត ធាំងក្ដីភ័យភិត
ឥតមានល្ហើយល្ហៃ។

៥. បង្ខំធ្វើការ ខាយដំប្រហារ សាសន៍ឯងជាខ្មែរ
ដូចតិរច្ឆាន ប្រៀបបានខ្មោចឆ្អែត ស្លាប់ខាហូរហែ
យកខ្មែរអមិត្ត។

៦. បុព្វហេតុប្រជា កម្លាំងសមគ្គា រួមជាគំនិត
ករណសិរ្ស ផ្ដួបផ្ដុំមូលមិត្ត សច្ចាំព្រឹមជីវិត
ពិតបានត្រកាល។

៧. សម្ដេចមហា ជា ស៊ីម អស្ចារ្យ ធម្មរពោធិសាល
ផ្ដួចផ្ដើមដឹកនាំ បណ្ដុះបណ្ដាល បង្កើតជាថ្នាល
ចលនាតស៊ូ។

៨. ក្រចេះស្រុកស្ងួល នាំគ្នាផ្ដើមផ្ដួល នៅឃុំជើងឃ្លូ
ស្ម័គ្រចិត្តចូលព្រៃ លកលែតស៊ូ ស្នារតីពីរធ្នូ
ឆ្នាំចិតប្រាំបី។

៩. លះបង់ឈាមសាច់ ប្រយុទ្ធប្ដូរផ្ដាច់ ឥតមានស្ដាយអ្វី
ពលីស្រស់ៗ រំដោះទឹកដី ពីអន្យត្តិរ្លិយ
បិសាចសាមាន្យ។

១០. រណសិរ្សពីរធ្នូ ធីរៈគម្រូ ប្ដូរជីពជំនួប្រាណ
កសាងប្រទេស ដោយក្ដីក្លាហាន រកភាពសាន្តត្រាណ
ក្រៀមក្សាន្តជូនជាតិ។

១១. ទោះជួបឧបសគ្គ រយពាន់គ្រោះថ្នាក់ ស្មោះស្ម័គ្រឥតឃ្លាត
ពួតដៃវេញចិត្ត ខ្លាំងឥតរខាត ទើបឡើងព្រោងព្រាត
ឆ្លៀតរំដោះទុក្ខរាស្ត្រ។

១២. រណសិរ្សពីរធ្នូ ប្រយុទ្ធតស៊ូ យកជ័យជម្នះ
ប្រាំពីរមករា ក្ដីថ្លាចាំចង៖ បនក្បត់វិនាស
រាស្ត្រស្រែកសាទរ។

១៣. មានរាស្ត្រមានរដ្ឋ មានអភិវឌ្ឍន៍ អំណត់គាំទ្រ
ប្រជាធិបតេយ្យ សេរីភាពគរ សំឡេងខ្ទារខ្ទរ
ជ័យោ!!កម្ពុជា។

១៤. មានថ្នល់មានស្ពាន មានសាលារៀន មានវត្តវិហារ
មានមន្ទីរពេទ្យ ឃុំ ខេត្ត នានា រាស្ត្ររស់ធូរធារ
លាភាពក្រខ្សត់។

១៥. រណសិរ្សពីរធ្នូ ឧត្ដមគម្រូ វិទូប្រវត្តិ
សម្ដេចទាំងបី ឈ្លាសវៃប្រាកដ ខ្មែរខ្ពស់មុខមាត់
ជ្បិតសន្តិភាព៕

*និពន្ធដោយ:* **លោក គួច សុគន្ធ**
*មន្ត្រីនគរបាលនៃអធិការដ្ឋាន នគរបាលក្រុងព្រៃវែង ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង*
*ទូរស័ព្ទលេខ: ០៩៧ ៧៦១១៥៩/០១០ ៦៣៥៨៦៧*
*ថ្ងៃសៅរ៍ ៤ កើត ខែភទ្របទ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤*
*ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០*

# រឿងពិតរបស់ខ្ញុំ

## ជីវិតក្រោយថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥

ថ្ងៃទី១៧ ខែមេសា ១៩៧៥ ប្រជាជនកម្ពុជាទូទាំងប្រទេសត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុល ពត ជម្លៀសចេញពីទីក្រុង ខេត្ត ឃុំ ភូមិពិសេសទីក្រុងភ្នំពេញឲ្យមករស់នៅតាមជនបទស្រែចម្ការ។

នៅតាមផ្លូវក្រោយសង្គ្រាមពីឆ្នាំ៧០ដល់ឆ្នាំ៧៥ បានបញ្ចប់ ពោរពេញដោយមនុស្សកុះករ អ្នកខ្លះដើរជាជួរ អ្នកខ្លះទូល ខ្លះកណ្ដៀត ខ្លះលីកូនចៅលើស្មា ខ្លះមានរទេះអូសអីវ៉ាន់ទៅតាមខ្លួនបន្តិចបន្តួច ព្រោះយោធាខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចេញពីផ្ទះដោយលើកបានឡើងថា ចេញពីផ្ទះបួនប្រាំថ្ងៃសិន ទម្រាំអង្គការរៀបចំរួច ទើបឲ្យប្រជាជនវិលចូលមកវិញ។

ប្រជាជនខ្លះមានការនឿយហត់ដោយសារថ្ងៃក្ដៅខ្លាំង ព្រោះចំខែមេសា។ ដូច្នេះប្រជាជនខ្លះបាននាំគ្នាឈប់សម្រាកក្រោមម្លប់ដើមឈើ ខ្លះទៀតសម្រាកតាមទីវត្តអារាមដែលគ្រានោះ មិនឃើញព្រះសង្ឃគង់នៅឡើយ។ នៅតាមផ្លូវគ្មានប្រជាជនណាហ៊ាននិយាយអំពីអ្វី ឬរំឭករឿងកាលពីសង្គមចាស់របស់សម្ដេចព្រះ នរោត្តម សីហនុ ឬរបប លន់ នល់ ឡើយព្រោះខ្លាចកងទ័ពរំដោះខ្មែរក្រហមចងយកទៅសម្លាប់។ នៅក្បែរចិញ្ចើមថ្នល់ យើងសង្កេតឃើញមានសាកសពកងទ័ព ប្រជាជនស៊ីវិល អ្នកមានតួនាទីនៅក្នុងរដ្ឋាភិបាល បញ្ញវន្តខ្លះបានស្លាប់ដោយសារជំងឺ ការបាញ់សម្លាប់ ពិសេសអ្នកដែលពាក់ខោអាវទាហាន លន់ នល់។ ខ្មែរក្រហមបានបណ្ដើរកងទ័ពទាំងនោះទៅបាញ់នៅកណ្ដាលព្រៃក្បែរអូរ ឬព្រៃរបោះ ដោយគ្មានអាសូរឡើយ ទោះបីមានការសុំអង្វរករក៏ដោយ។ ខ្មែរក្រហមបានប្រើមធ្យោបាយបោកប្រាស់ប្រជាជន ដោយប្រើពាក្យថា នរណាធ្វើការងារអ្វី ពាក់ស័ក្តិប៉ុន្មាន រៀនដល់ថ្នាក់ណា សូមប្រាប់ការពិត បន្ទាប់មកខ្មែរក្រហមបានយកអ្នកទាំងនោះទៅរៀនសូត្រ និងបានបណ្ដើរទៅបាញ់ចោល។

គ្រួសាររបស់នាងខ្ញុំពេលនោះត្រូវបានខ្មែរក្រហមជម្លៀសចេញពីក្រុងកំពត។ នៅតាមផ្លូវ នាងខ្ញុំពុំដឹងគោលដៅ ថាត្រូវទៅឯណាឡើយ គឺខ្ញុំទៅតាមតែអង្គការបញ្ជាប៉ុណ្ណោះ។ ខ្មែរក្រហមបានចាត់តាំងឲ្យគ្រួសារ នាងខ្ញុំទៅរស់នៅក្នុងភូមិព្រៃស្បូវ ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត តំបន់៣៥។ ខ្ញុំរីករាយក្នុងចិត្តនឹកត្រេកអរយ៉ាងខ្លាំង ព្រោះសង្ឃឹមថាបានជួបបងប្អូន ពូមីង ខាងម្ដាយរបស់នាងខ្ញុំរស់នៅភូមត្រពាំងធំ ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត ប៉ុន្តែបងប្អូនខាងម្ដាយខ្ញុំពោលពាក្យថា ពុំស្គាល់ឬគ្មានបងប្អូនជាអ្នក១៧មេសាទេ។

ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ នាងខ្ញុំព្រមទាំងស្វាមី និងកូនប្រុសអាយុ២ឆ្នាំរបស់ខ្ញុំឈ្មោះ ឡុងស៊ីណាច បានទៅដល់វត្តអង្គស្វាយ ភូមិអង្គស្វាយ ឃុំមានជ័យ ដោយតូចចិត្ត ព្រោះក្នុងរបបខ្មែរក្រហមនេះ អ្នកមូលដ្ឋានទោះបីជាមានបងប្អូនអ្នក១៧ក៏ដោយ ក៏ពុំហ៊ានទទួលស្គាល់យើងដែរ។ អ្នកទាំងនោះខ្លាចពាក់ព័ន្ធខ្សែ ហើយឪពុកម្ដាយក៏ពុំហ៊ានទទួលស្គាល់កូនដែរ គឺត្រូវផ្ដាច់មនោសញ្ចេតនាពីគ្នា។

យើងរស់នៅវត្តអង្គស្វាយ២យប់ ទើបអង្គការបែងចែកឈ្មោះប្រជាជន ១៧មេសា ជាង ៣០០ គ្រួសារ ទៅតាមភូមិដែលអង្គការបានកំណត់។

### ហេតុការណ៍ដែលបានកើតឡើង

ថ្ងៃ២៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវព្រាត់ឪពុកម្ដាយ បងប្អូនប្រុស ស្រី ជីដូនជាទីស្រលាញ់ មករស់នៅភូមិស្រុកដែលខ្ញុំមិនដែលស្គាល់ពីមុនមក ដើម្បីការងារស្រែ និងចម្ការ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំមិនដែលមានពេលសម្រាក និងនិយាយគ្នាជាមួយប្ដីប្រពន្ធកូនឡើយ គឺពេលព្រឹកព្រលឹម ម៉ោង៥ ខ្ញុំនិងប្ដីទៅកាន់ការដ្ឋានការងាររៀងៗខ្លួន។ យើងមិនហ៊ានសុំឈប់សម្រាក ព្រោះខ្លាចអង្គការចោទថាយើងធ្វើពុត ចំណែកឯកូនប្រុសរបស់ខ្ញុំនិងក្មេងដទៃទៀតជាច្រើនត្រូវអង្គការប្រមូលឲ្យរស់នៅម្ដុំ ដោយមានយាយចាស់ៗនៅមើលថែ។ អង្គការបែងចែកតាមក្រុមក្នុងមួយភូមិមាន៨ក្រុម។

ខ្ញុំអាណិតកូនប្រុសខ្ញុំណាស់ព្រោះនៅក្មេងដែលត្រូវទទួលការថ្នាក់ថ្នមពីម្តាយឪពុកនិងត្រូវហូបអាហារដែលមានជីវជាតិ។ ប៉ុន្តែកូនរបស់ខ្ញុំហូបមិនឆ្អែត និងដេកនៅលើស្លឹកត្នោត។

ពេលយប់ប្តីប្រពន្ធដែលត្រឡប់មកពីធ្វើការវិញ និងហូបបាយរួចត្រូវចូលទៅសម្រាកដោយពុំហ៊ាននិយាយគ្នា។ បើទោះបីអ្នកទាំងនោះធ្វើការការងារលំបាកយ៉ាងណាក៏ដោយ ក៏ពុំហ៊ាននិយាយត្អូញត្អែរដែរ ព្រោះពេលយប់កងឈ្លបបានដើរយកការណ៍ពេញភូមិ។ ប្រសិនបើប្រជាជនណាហ៊ាននិយាយថា នឹកបងប្អូនឪពុកម្តាយ និងនឹកផ្ទះ អ្នកទាំងនោះពិតជាត្រូវបាត់ខ្លួនជាមិនខាន ប្រសិនបើឈ្លបស្តាប់ឮ។ ឈ្លបទាំងនោះបានហៅប្រជាជនទាំងនោះទៅរៀនសូត្រ ឬទៅនៅភូមិថ្មី ដែលជាពាក្យសម្ងាត់ដើម្បីកុំឲ្យប្រជាជនមានការភ័យខ្លាច។ ខ្ញុំរស់នៅក្រោមការធ្វើបាបពីស្ត្រីអ្នកមូលដ្ឋានមួយចំនួន។ ស្ត្រីទាំងនោះនិយាយពាក្យម៉ាក់ងាយ រិះគន់ចំអកប្រមាថជាច្រើន ដូចជា «មើលពួកមី១៧ វាដើរដូចលោកស្រី ហេតុតែវាធ្លាប់ជិះជាន់គេ ឥឡូវវាមកដកស្ទូង ប៉ុណ្ណឹងធ្វើពុំបាន! សមតែកម្ទេចវាចោលឲ្យអស់ ទើបសម! មីពួកខ្មាំងចង្រៃ! វាចេញពីក្រុងមកមានស៊ី កុំតែពួកយើងឲ្យវាស៊ី វាបានអីស៊ី! ម្នាក់ៗដើរមើលតែជំទាវ!

នេះជាសម្តីប្រធានក្រុម ដែលជាមនុស្សមានទឹកមុខកំណាច ត្រូវបានខ្មែរក្រហមបន្តុបឲ្យធ្វើមេកើយ។ ប្រធានក្រុមពុំចេះពិចារណាអ្វីក្រៅពីឃើញយើងធ្វើខុសបន្តិចបន្តួចប្រញាប់រាយការណ៍អំពីយើងភ្លាម។ ចរិតប្រធានក្រុម ទាំងនោះពេលខ្មែរក្រហមបានឲ្យធ្វើធំបន្តិច គឺឡើងចាន់ ហើយអ្នក១៧ មេសាធ្វើអ្វីខុសឬត្រូវ គឺមិនខ្វល់ទេ គឺចេះតែម៉្យាង គឺយកទៅសម្លាប់ឥតតវ៉ាបានឡើយ។

ប្រជាជនបានរស់មួយយប់គិតមួយថ្ងៃ គឺយើងរស់ទាំងព្រលឹងចុងសក់។ ថ្ងៃខែឆ្នាំបានវិលផុត នាងខ្ញុំរស់នៅមាននាទីជាអ្នកវែកដីដំបូក។ ពេលរដូវសាប ដកស្ទូង គឺខ្ញុំត្រូវធ្វើ ទោះបី ខ្ញុំពុំចេះធ្វើការងារនេះពីមុនក៏ដោយ។ ខ្មែរក្រហមបានកំណត់ឲ្យខ្ញុំដកសំណាបឲ្យបាន ៣ ឬ ៤ ដួនក្នុងមួយថ្ងៃ។ ពេលប្រជុំក្រុមម្តងៗ ប្រធានដឹកនាំប្រជុំបានទិតៀនស្តីឲ្យខ្ញុំរាល់ពេល។ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៧៦ ខ្ញុំមានជំងឺជាទម្ងន់ដោយកើតពិសនៅថ្កាមខាងឆ្វេង។ ពេលនោះប្តីខ្ញុំគិតខំដើររកគ្រូខ្មែរ និងអង្វរករគ្រូខ្មែរឲ្យជួយព្យាបាលខ្ញុំ ប៉ុន្តែខ្មែរក្រហមពុំអនុញ្ញាតឲ្យប្តីរបស់ខ្ញុំឈប់មើលថែខ្ញុំឡើយ។ ខ្មែរក្រហមថាខ្ញុំធ្វើពុត លុះពេលមកឃើញខ្ញុំផ្ទាល់ក៏និយាយថា បើឈឺដឹកទៅពេទ្យឃុំ នៅផ្ទះគ្មានថ្នាំទេ។ ប្តីរបស់ខ្ញុំបានស៊ើបសួររក តាម៉ៅ ដើម្បីមកព្យាបាលជំងឺឲ្យខ្ញុំ។ កាលជំនាន់នោះមាសប្រាក់គ្មានតម្លៃឡើយ ម្ល៉េះហើយ គាត់ទារប៉ុន្មានក៏ខ្ញុំព្រមឲ្យគាត់ដែរ ឲ្យតែគាត់ព្យាបាលខ្ញុំឲ្យជាសះស្បើយ។

ក្នុងអំឡុងពេលពីរអាទិត្យ ទោះបីប្តីខ្ញុំចេញទៅធ្វើការ ក៏គាត់ឆ្លៀតមកមើលខ្ញុំដែរ។ ខ្ញុំបានជាសះស្បើយ និងហូបចុកបានធម្មតា ព្រោះបានប្តីខ្ញុំជួយមើលថែពេលសម្រាកពីការងារ។ ក្រោយមកនៅឆ្នាំ១៩៧៧ ទើបខ្មែរក្រហមរៀបចំប្រមូលចានឆ្នាំង មកដាក់នៅផ្ទះបាយរួមគ្នា។ នៅតាមក្រុមត្រូវមានរោងបាយមួយដើម្បីហូបជុំគ្នាហើយប្រជាជនគ្មានកម្មសិទ្ធិឯកជនឡើយ។

នៅក្នុងឆ្នាំ ១៩៧៧ នៅក្នុងភូមិឃុំនីមួយៗខ្មែរក្រហមរៀបចំប្រជាជនឲ្យមានគូស្រករ ប្តីប្រពន្ធ ដោយខាងប្រុសឈរនៅម្ខាង និងស្រីឈរនៅម្ខាងដើម្បីស្តាប់ការណែនាំរបស់តំណាងគណៈស្រុកឬឃុំ។ គណៈអធិបតីបានឲ្យខាងប្រុសឬស្រីឡើងមកនិយាយចាប់អារម្មណ៍ និងប្តេជ្ញាទទួលគ្នាជាប្តីប្រពន្ធតទៅ។ ការរៀបការម្តង៧០ ឬ ៨០គូ ហើយទោះបីគូស្រកទាំងនោះមិនពេញចិត្តក៏ដោយ គឺពុំអាចប្រកែកបានឡើយ ព្រោះពិធីនេះអង្គការជាអ្នករៀបចំឲ្យ។

ចាប់ពីពេលនោះមក សភាពលំបាកនិងការកាប់សម្លាប់រង្គាលក៏កាន់តែមានការកើនឡើង។ ក្រោយពេលរៀបការឲ្យនារីនិងយុវជនបានមួយខែឬពីរខែ ខ្មែរក្រហមក៏បានយកប្តីអ្នកទាំងនោះសម្លាប់ចោល រួចខ្មែរក្រហមប្រមូលស្រីមេម៉ាយដាក់ម្តុំ ហើយដាក់ឈ្មោះថាកងមេម៉ាយ។

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៧ យុវជនចំនួន៥នាក់ បាននាំគ្នារត់ភៀសខ្លួន ប៉ុន្តែសំណាងអាក្រក់ យុវជននោះរត់ទើបដល់ច្រកសៀម ជាប់ព្រំប្រទល់តាកែវកំពត ក៏ត្រូវយោធាខ្មែរក្រហមចាប់ខ្លួនបាន។ ខ្មែរក្រហមបានបញ្ជូនយុវជនទាំងនោះមកភូមិនារាយណ៍ ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត ដោយចងដៃ ចងជើង សម្រុតខ្សែ ទម្លាក់ក្នុងពាងទឹកត្រីឲ្យស្លាប់។ ប៉ុន្តែមុននឹងសម្លាប់ ខ្មែរក្រហមបានបញ្ជាឲ្យយុវជនទាំងនោះស្រែកថា សូមមិត្តទាំងឡាយកុំយកតម្រាប់តាមខ្ញុំ ខ្ញុំគឺជាគិញសម្ងាត់ CIA។ ខ្មែរក្រហមបានឲ្យប្រពន្ធជនរងគ្រោះមកឈរមើលខ្លួនសម្លាប់ប្តីយ៉ាងអាណោចអាធ័មជាទីបំផុត។

ពេលឃើញទិដ្ឋភាពដូច្នេះ ខ្ញុំពុំហ៊ានមើលឡើយ។ ខ្ញុំបានលួចឱនមុខចុះនិងស្រក់ទឹកភ្នែកមិនឲ្យខ្មែរក្រហមឃើញ ព្រោះខ្លាចខ្មែរក្រហមចោទប្រកាន់ខ្ញុំ។ ខ្ញុំបានបន់ស្រន់ឲ្យចេញផុតពីរបបព្រៃផ្សៃឃោរឃៅនេះ។ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់ប្រជាជនគ្រប់ភូមិ ឃុំ ស្រុកទៅលើកទំនប់រំលេចខាងជើងស្រុកស្រែក្នុង ដោយទប់ភ្នំពីមួយទៅមួយ។ ខ្ញុំនិងប្តីប្រពន្ធក៏ដូចប្រជាជនដទៃទៀតដែរ គឺត្រូវខ្មែរក្រហមបង្ខំឲ្យទៅរែកដី ដោយត្រូតបង្គីធំម្ខាងពីរៗ តាមពាក្យខ្មែរក្រហមដែលស្រែកថាសម្រុកយកឈ្នះពីភូមិមួយទៅភូមិមួយ។ រយៈពេលជាងមួយខែ ដែលខ្ញុំរែកដីនៅទំនប់រំលេច។ ថ្ងៃមួយកូនរបស់ខ្ញុំឈឺខ្លាំង និងកើតកញ្ច្រិល ខ្ញុំក៏សុំប្រធានកងយកកូនទៅព្យាបាលនៅពេទ្យឃុំពស់ពង នៅក្បែរវត្តនារាយណ៍ ចំណែកប្តីរបស់ខ្ញុំនៅលើកទំនប់រហូតរួចរាល់។

នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៨ ទំនប់រំលេចបានធ្វើរួចរាល់ជាស្ថាពរ។ ប្រជាជនទាំងអស់សប្បាយរីករាយណាស់ដោយបានវិលត្រឡប់មកជួបជុំគ្រួសារវិញ លើកលែងតែប្តីខ្ញុំប៉ុណ្ណោះដែលត្រូវបានខ្មែរក្រហមបញ្ជូនទៅភ្នំបាក់នឹម ដើម្បីកាប់គាស់ដីធ្វើចម្ការដាំដំឡូង និងពោតទៀត។

រយៈពេលជាច្រើនខែហើយដែលខ្ញុំនិងកូនប្រុស ទន្ទឹងរង់ចាំប្តី និងឪពុក។ ឯរូបនាងខ្ញុំនៅតាមភូមិ ត្រូវខ្មែរក្រហមប្រើឲ្យប្រមូលនិងសែងលាមកមនុស្សតាមផ្ទះ យកមកជ្រលាយអាចម៍គោ ទន្ទ្រានខែត្រ ដីដំបូកធ្វើជាជីបាចស្រែ។ ពេលខ្លះខ្មែរក្រហមបានចាត់តាំងខ្ញុំទៅធ្វើស្រែប្រាំងដែលនៅក្នុងភូមិទល់ ឬវាលត្បាល់ដែលមានសុទ្ធតែឈ្លើងគួរឲ្យខ្លាចជាទីបំផុត ប៉ុន្តែខ្ញុំពុំហ៊ានប្រកែកនឹងការចាត់តាំងនេះឡើយ។ ពេលយប់ហូបបាយរួច ខ្មែរក្រហមមិនឲ្យយើងសម្រាកឡើយ គឺខ្មែរក្រហមប្រើយើងឲ្យទៅជញ្ជូនកណ្តាប់ដាក់ទីលានទៀត។ ប្រជាជនខ្លះរែក ខ្លះចងទូលមកដាក់លានរហូតដល់ម៉ោង៩ ឬ ១០ទើបអាចឈប់សម្រាក។ ពេលព្រលឹមម៉ោង៥ ប្រធានកងវាយជួងដាស់ប្រជាជនឲ្យទៅដល់ការដ្ឋានរៀងៗខ្លួន។

ខ្ញុំចាកចេញពីផ្ទះទៅតាមកងពិសេសរយៈពេលជាច្រើនខែជាមួយកូននៅតែពុំទាន់ឃើញប្តីខ្ញុំត្រឡប់មកវិញ។ ថ្ងៃមួយពេលចប់ការងារស្រូវប្រាំងចូលដល់ស្រូវវស្សា ទើបខ្ញុំត្រឡប់មកផ្ទះវិញ ពេលនោះហើយកូនរបស់ខ្ញុំហាក់ដូចមានជំងឺអ៊ុំម៉្យាង ដោយសាច់វាលឿង។ យាយៗ បានប្រាប់ខ្ញុំថា កូនរបស់ខ្ញុំហូបធ្យូង។ ខ្ញុំឆ្លៀតពេលឈប់សម្រាកពីធ្វើការទៅសុំទឹកត្នោត ព្រមទាំងអាចម៍ដែក ដីប្លី ស្លឹកគ្រៃខ្ទបយកមកត្រាំឲ្យកូនខ្ញុំផឹក។ ខ្ញុំអាណិតកូនខ្ញុំណាស់ពេលវាផឹកម្តងៗយំក្អួតមកវិញ។ ដោយខ្លាចកូនស្លាប់ ខ្ញុំបញ្ច្រុកថ្នាំវារហូតបានសាច់ឈាមធម្មតាវិញ។

រហូតកូនរបស់ខ្ញុំបានធូរស្បើយ ទើបបានឃើញប្តីខ្ញុំត្រឡប់មកពីចម្ការបាក់នឹមវិញគឺនៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ១៩៧៨។ ថ្ងៃនោះភ្លៀងកំពុងរលឹមស្រិចៗ ខ្ញុំក្រឡេកទៅឃើញរទេះក្របីមួយនឹមបរចូលមក។ ខ្ញុំមើលសឹងតែពុំស្គាល់ព្រោះព្រលប់ម៉ោងជាង៦ល្ងាចហើយ ទាល់តែឮសូរត្រដោកក្របី ទើបខ្ញុំនឹកថាប្តីខ្ញុំវិលមកវិញ។

ប្តីខ្ញុំបានឈប់នៅមុខផ្ទះ។ ពេលដឹងថាប្តីមកវិញ ចិត្តខ្ញុំត្រេកអរណាស់ព្រោះរយៈពេល៤ខែទើបជួបមុខប្តីម្តង។ មេឃនៅតែរលឹមដដែលព្រោះខែស្រូវបែកគុម្ព។ ក្រឡេកឃើញកូនប្រពន្ធ ប្តីខ្ញុំត្រេកអរណាស់ក៏ស្ទុះមកថើបកូន។

ខ្ញុំបាននិយាយទៅកាន់ប្តីដោយទឹកមុខក្រៀមក្រំ:

-ប៉ាវាអើយ ពីរបីថ្ងៃមុននេះប្រជាជននៅភូមិយើងត្រូវខ្មែរក្រហមហៅទៅទប់ទឹក ហើយ៤នាក់បាត់ខ្លួន។ ជិតអស់ហើយប្រុសៗនៅភូមិយើង ហើយខ្ញុំភ័យខ្លាំងណាស់។

គាត់តបមកខ្ញុំវិញតិចៗ ព្រោះខ្លាចអ្នកជ្រែងឮ

-កុំមាត់អូន បងក៏ដឹងដែរ។ នេះស្បៀងខោអាវទទឹក ដាក់ហាលឲ្យបងផង! ឯណាកូន! នឹកពុកទេ! ពុកសុំថើបមួយ។

កូនប្រុស ខ្ញុំឱបកឪពុកហាក់ដូចជានឹកខ្លាំងណាស់។ និយាយបណ្តើរគាត់ហុចស្បៀងខោអាវឲ្យខ្ញុំរួចក៏បង្ហួសទៅស្រាយក្របីពីនឹម។ គាត់ចងក្របីនឹងដើមស្វា។ ពេលនោះសំឡេងមនុស្សម្នាក់ដែលនៅដៃមានកាន់ចង្កៀងប្រេងកាតដាក់នៅក្នុងប៉ោតឈើនៅពីខាងជើងផ្ទះខ្ញុំក្បែរត្រពាំងទឹក បានបន្លឺសំឡេងយ៉ាងឮសូរមកប្តីខ្ញុំថា:

-ឪអាវងមកវិញហើយ? ហូបបាយនៅ? ដែលជាសម្តីប្រធានក្រុមសេដ្ឋកិច្ចភូមិឈ្មោះនាយផាត ព្រោះ ស៊ីណាច កូនខ្ញុំជំនាន់នោះគេហៅឈ្មោះវាថា អាវងៗ។

ប្តីខ្ញុំបានតបទៅនាយ ផាត វិញទាំងសុភាពរាបសារឯដៃគាត់ម្ខាងអង្អែលក្បាលកូន។

-បាទខ្ញុំហូបរួចហើយបង! ខ្ញុំហូបនៅមន្ទីរឃុំពេលដាក់ពោតទុំរួច!

-អើ! បើរួចហើយយកចបមកទៅទប់ទឹកនឹងគេ ទឹកហូរខ្លាំងណាស់ថ្ងៃមិញខ្លាចបាក់ភ្លឺស្រែប្រញាប់មក!

ពុទ្ធោអើយពុសម្ដីថាទៅទប់ទឹកភ្លាមខ្ញុំស្ទើរក្លាយជាមនុស្សគ្មានវិញ្ញាណទៅហើយ ខ្ញុំសម្លឹងមុខប្ដីខ្ញុំដែលពុំទាន់ផ្លាស់ខោអាវទទឹកចេញផង គាត់ក៏ឆ្លើយតបទៅគេវិញថា

-បាទ បង!

គាត់ទាញយកចបកាប់នៅលើគ្រែខាងមុខកូនខ្ទម ដាក់លើស្មារួចដើរទៅតាមភ្លើងចង្កៀងប្រេងកាតដែលដាក់ក្នុងប៉ោតយួរដើរទៅកាន់ទិសខាងលិចផ្ទះ សំដៅទំនប់ត្រពាំងខ្ញុំ។ ពេលទៅដល់ជួបគេរួចមួយសន្ទុះ ស្រាប់តែមិនដឹងជាហេតុអី គាត់ក៏ត្រឡប់មកវិញចាប់កូនថើបម្ដង ទៀតរួចផ្ដាំខ្ញុំថា

-បើបាត់បងយូរនាំកូនដេកទៅកុំចាំផ្លូវបងអី! ពេលនោះទឹកមុខគាត់ខ្មៅហើយគាត់ដើរមួយៗទៅតាមគេហើយគាត់ងាកក្រោយរហូត។ ខ្ញុំតាមមើលគាត់រហូតបាត់ស្រមោល និងភ្លើងចង្កៀងក្នុងព្រៃងងឹតឈឹងទាំងរលឹមស្រិចៗ មួយសន្ទុះធំ កូនរបស់ខ្ញុំក៏ងងុយដេក ខ្ញុំបានចងអង្រឹងឲ្យវាដេក។ ដោយសារអស់កម្លាំងជាមួយការងារពេលថ្ងៃ និងហូបពុំបានគ្រប់គ្រាន់ផង ខ្ញុំទម្រេតខ្លួនដេកលក់ទៅ។

-យ៉ៃ! យ៉ៃ! យ៉ៃ --ហ៊ឺៗៗៗ

កូនខ្ញុំយំក្នុងអង្រឹង ទន្ទឹមពេលខ្ញុំយល់សប្ដិឃើញប្ដីខ្ញុំមកឈរមាត់ទ្វារមានតែខ្លួនអត់ឃើញមានក្បាលទេ។ ខ្ញុំស្ទុះអង្គុយលើកកូនមកឱបយំ ព្រោះខ្ញុំដឹងថា ពេលនេះជាពេលដែលគេសម្លាប់ប្ដីខ្ញុំប្រាកដណាស់ ព្រោះធម្មតាពេលគេហៅទៅធ្វើការពេលយប់ គឺម៉ោងត្រឹម៩ត្រឡប់មកវិញហើយ។ ការហៅទៅទប់ទឹកនេះមានជាគំរូប៉ុន្មាននាក់មុននេះរួចមកហើយ។ ពេលយប់នោះខ្មែរក្រហមបានហៅទៅមិនមែនតែប្ដីខ្ញុំម្នាក់ទេ គឺមាន នាយកើត ជាអតីតទាហាន លន់ នល់ ប្ដីខ្ញុំឈ្មោះ ជា សំណាង គឺជាអតីតកងរាជអាវុធហត្ថជាតិ។ ខ្ញុំយំមួយយប់រហូតទល់ភ្លឺ។ នៅពេលព្រឹកឡើងថ្ងៃអាទិត្យ ខ្មែរក្រហមប្រមូលអ្នក១៧ ទៅប្រជុំនៅវត្តអង្គស្វាយ ចំណែកខ្ញុំខ្មែរក្រហមមិនឲ្យទៅចូលរួមទេ ថែមទាំងនិយាយផ្ដែផ្ដាឲ្យខ្ញុំទៀត។

-យើម៉ែអាវង! យប់មិញអត់ដេកទេ ឬ បានជាហើមភ្នែកដូច្នេះ? នៃពុំបាច់ទៅប្រជុំទេនៅស្រោចត្រកួនឲ្យហើយសឹមហូបបាយ! បើស្រោចពុំហើយទេកុំហូប! នេះជាសម្ដីប្រធានក្រុមស្រីនិងចុងភៅឈ្មោះ ថាន ប្រពន្ធប្រធានក្រុមសេដ្ឋកិច្ចឈ្មោះ ផាត ដែលជាអ្នកហៅប្ដីខ្ញុំទៅសម្លាប់។

រងត្រកួន ៥០រងយ៉ាងវែងៗ ធ្វើឲ្យខ្ញុំស្រោចដល់ម៉ោងមួយពុំទាន់ហើយ ម្យ៉ាងខ្ញុំអត់ងងុយ ម្យ៉ាងគ្មានកម្លាំង ព្រោះយើងមិនមានអាហារមានជីវជាតិហូបគ្រប់គ្រាន់! រហូតដល់ម៉ោងពីររសៀល និងស្ទើរទន់ជង្គង់ទើបខ្ញុំបានស្គាល់រសជាតិបាយដែលស្ទើរដូចបបរឈ្លោលចូលក្នុងពោះ។ ហូបរួចប្រធានកងឲ្យខ្ញុំសែងផុងបាយឲ្យជ្រូកចំនួន៣០-៤០ក្បាលស៊ីទៀត រហូតដល់យប់ម៉ោង៦ បន្ទាប់មកប្រធានកងឲ្យខ្ញុំទៅសែងដីដាក់ស្រែរហូតម៉ោង១០យប់ទើបខ្ញុំទៅយកកូនមកដេកជាមួយ។

ពេលយប់ខ្ញុំតែងតែដេកយំដោយសារនឹកប្ដី។ ខ្ញុំបន់ស្រន់ឲ្យវិញ្ញាណក្ខន្ធគាត់តាមថែរក្សាប្រពន្ធនិងកូនឲ្យបានសុខ និងបានរស់រានមានជីវិត និងមានអ្នកមានបុណ្យមកជួយរំដោះជីវិតដ៏សែនវេទនានោះ។

ចាប់ពីពេលនោះហើយដែលខ្ញុំរស់នៅជាស្ត្រីមេម៉ាយនៅក្នុងខែកក្កដា ឆ្នាំ១៩៧៨។

## ជីវិតស្រីមេម៉ាយក្រោយពេលប្ដីត្រូវគេសម្លាប់

ថ្ងៃខែកន្លងមកខ្ញុំក៏ពុំបានទៅផ្ទះទៀតដែរ គឺប្រធានកងឲ្យខ្ញុំនៅក្នុងកងស្ត្រីមេម៉ាយ ទៅធ្វើការនៅឆ្ងាយពីផ្ទះពីឃុំមួយទៅឃុំមួយ ភូមិមួយទៅភូមិមួយដោយមិនឲ្យនៅក្នុងភូមិខ្លួនឯងឡើយ។ សម័យនោះ ខ្ញុំតែងបានជួយយកអាសារប្រជាជនមូលដ្ឋានក្នុងការចាប់ខ្យល់និងជប់ខ្យល់ ពិសេសនាងខ្ញុំត្រូវបានគណៈកងឲ្យឡើងច្រៀងក្នុងពិធីបុណ្យមីទ្ទីងធំៗឬតាមភូមិ ព្រោះកាលពីជំនាន់សម្ដេច នាងខ្ញុំបានធ្លាប់ហាត់របាំព្រះរាជទ្រព្យតាំងពីអាយុ៦ឆ្នាំដល់១៣ឆ្នាំ ទើបឪពុកនាងខ្ញុំផ្លាស់ទៅធ្វើការនៅក្រុងកំពត ទើបនាងខ្ញុំឈប់រាំរបាំនេះទៅ។ ប៉ុន្តែប្រសិនបើខ្មែរក្រហមដឹងថា ខ្ញុំមានប្រវត្តិរូបដូចខាងលើក៏ពុំទុកជីវិតខ្ញុំដែរ។ គណៈកងហៅខ្ញុំទៅច្រៀងដោយសារខ្ញុំខស្សរាហ៍ច្រៀងបទបដិវត្តន៍របបកម្ពុជាប្រជាធិបតេយ្យ។ នាងខ្ញុំទៅធ្វើការនៅភូមិឃុំឆ្ងាយៗហើយកូនៗរបស់ស្ត្រីមេម៉ាយត្រូវបានប្រធានកងប្រមូលទុកក្នុងភូមិហើយចាត់តាំងឲ្យគ្រូស្រីក្មេងៗមើលថែ។

នៅពេលយប់មួយមើលគ្នាពុំយល់ហើយដែលត្រូវពេលស្រូវបែកគុម្ពខ្ពស់ៗជិតចេញផ្លែ ព្រមទាំងមានភ្លៀងរលឹមស្រិច និងមានផ្លេកបន្ទោរព្រាកៗផង ក្រុមតាៗដាំថ្នាំនៅតាមភូមិចុងខាងកើត ភូមិក្រោម ទំនប់អូឃ្លៃ ឮក្មេងយំ៖

-ហ៊ឺៗៗ ម៉ែអើយៗ ម៉ែនៅណា? ហ៊ឺៗ អ៊ំម្នាក់ឈ្មោះ ឈុំ ស្មានថាខ្មោចលង

ក៏ចាំស្តាប់ម្តងទៀត។ សំឡេងកាន់តែឮជិតឡើងៗ គាត់ក៏យកចន្លុះឆ្លុះមើលស្រាប់តែឃើញ កូនណាច របស់ខ្ញុំ ដៃមួយឱបអង្រឹង ដៃមួយញីភ្នែកយំព្រោះភ្លៀងជោកខ្លួនវា។ គាត់ភ្ញាក់ព្រើតរួចស្ទុះមកលើកវាពហើយគាត់សួរថា

-យីអាវងទេតើ! ហើយចៅឯងទៅណាកណ្តាលយប់ភ្លៀងហ្នឹង?

បើមិនជួបតាឯង មិនដឹងដើរទៅដេកត្រង់ណាទេ? ចុះម៉ែទៅឯណា?

គ្រូមើលក្មេងទៅណាពុំដឹងបាត់ក្មេងអុីចឹង? អ៊ឺឈុំ ក៏បានពកូនខ្ញុំយកមកឲ្យគ្រូក្មេង ហើយគាត់ស្តីបន្ទោសគ្រូរៀនមើលក្មេងមិនដឹងថាបាត់ក្មេងឬយ៉ាងម៉េច? នេះវាជួបតាៗដាំថ្នាំ ចុះបើវាពុំជួបវាងងុយដេកឬដើរចូលត្រពាំងលង់ស្លាប់កូនគេទៅតើដោះស្រាយយ៉ាងណាជាមួយម្តាយគេ។ ម្តាយគេទៅធ្វើពលិកម្មគេមិនមែនទៅដើរលេងឯណា។

ដោយសារពិបាកមើលថែគ្រូរៀនក៏សុំអង្គការឲ្យកូនខ្ញុំបានមកនៅជាមួយខ្ញុំវិញ។ មួយខែកន្លងផុត កូនរបស់ខ្ញុំចាប់ផ្តើមកើតកញ្ជ្រឹល។ ពេលនោះខ្ញុំបានមើលថែវាតែពុំបានជិតដល់ទេព្រោះការងារអង្គការដាក់ឲ្យយើងហើយបើឈប់ច្រើនពេកប្រធានកងថាយើងយកលេសកូនឈឺខ្ជិល។ ដូចនេះខ្ញុំត្រូវធ្វើសំបុត្រសុំយកកូនទៅដេកពេទ្យនៅឃុំពស់ពង។ រយៈពេលមួយអាទិត្យ កូនរបស់ខ្ញុំបានធូរស្រាលមានកម្លាំងស្រួលបួលវិញ ក៏ដោយសារតែបានគ្រូពេទ្យឃុំម្នាក់ឈ្មោះ អឿន ជួយមើលថែ និងឲ្យថ្នាំល្អៗ ចំណែកអាហារមានត្រីសាច់គ្រប់បែបយ៉ាង។ ពេលដែល អឿន ធ្វើល្អមកលើខ្ញុំគ្រប់បែបដូចនេះ ធ្វើឲ្យខ្ញុំមានការសង្ស័យថា ពិតជាមានបំណងមិនល្អមកលើរូបខ្ញុំ ដូចនេះខ្ញុំប្រញាប់សុំប្រធានពេទ្យត្រឡប់មកភូមិវិញភ្លាម។ ខ្ញុំខ្លាចណាស់ចំពោះរឿងខុសសីលធម៌ព្រោះខ្មែរក្រហមនឹងវាយចោលភ្លាម ម្យ៉ាងគ្រូពេទ្យគឺជាអ្នកមូលដ្ឋាន ចំណែកខ្ញុំអ្នកថ្មី១៧។ អ្នកមូលដ្ឋានពេលនោះជ្រុលជ្រើមនឹងសម្រស់ស្រី១៧ ណាស់។ ខ្ញុំត្រឡប់ទៅភូមិវិញ ប្រធានកងឲ្យខ្ញុំទៅធ្វើស្រែនៅភូមិវាលត្បាល់រយៈពេលកន្លះខែ ជាមួយកងមេម៉ាយ។

ថ្ងៃ១៥កើតខែអស្សុជ ជាថ្ងៃដែលខ្ញុំត្រឡប់ពីវាលត្បាល់វិញ។ ខ្ញុំឃើញដំបូលខ្ទមលេចមើលឃើញមេឃយ៉ាងច្បាស់ ខ្ញុំក៏សុំស្នើប្រធានក្រុមយកចំបើងដែលគេក្រងជាកណ្តាបដូចស្លឹកត្នោតចំនួន ៣០កណ្តាប មកប្រក់ផ្ទះខ្លួនឯង។ រាត្រី ១៥កើត ខែភ្លឺស្រឡះល្អណាស់ ខ្ញុំបានឡើងប្រក់ផ្ទះខ្លួនឯងបានពាក់កណ្តាល ចំណែកកូនរបស់ខ្ញុំបានដេកលក់យ៉ាងស្រួលក្នុងអង្រឹង។ ប៉ុន្តែពេលនោះកូនខ្ញុំចាប់ផ្តើមលាប់កញ្ជ្រឹល។ ខ្ញុំខំធ្វើការបណ្តើរ ដាំសម្បកឈើឲ្យវាផឹករាល់ថ្ងៃទោះបីវាមិនផឹកក៏ដោយ គឺខ្លាចកូនស្លាប់ ព្រោះពេលបាត់ប្តីទៅខ្ញុំនៅសល់កូនមួយប៉ុណ្ណោះ។

ម៉ោងប្រហែលជា ១០យប់ កំពុងឡើងប្រក់ដំបូលបណ្តើរ ស្រាប់តែខ្ញុំឃើញស្រមោលមនុស្សក្បែរដើមស្វាគៀនផ្ទះខ្ញុំ និយាយមកកាន់ខ្ញុំថា៖

-អាណិតម៉ែអាវងណាស់!

ប្រក់ផ្ទះម្នាក់ឯង!

ពុំគួរណាមិនហ៊ានរកខ្ញុំ ខ្ញុំជួយប្រក់ឲ្យ!

ប្រក់ម្នាក់ឯងដូច្នេះកាលណាហើយ?

-អូពូគីទេឬ? ខ្ញុំពុំហ៊ានរកពូប្រក់ទេ ណាមួយការងារពូច្រើន ខ្ញុំធ្វើបានការងារប៉ុណ្ណឹង។ អីនែយប់អុីចឹងពូគីឯងឈរអុីចឹងមិនសមទេ ពេលគេមើលមក។ ណាមួយប្រពន្ធពូគីឯងកាចណាស់ វីវរយល់ច្រឡំផ្តេសផ្តាសមកលើខ្ញុំ! ខ្ញុំភ័យណាស់ពូទៅវិញទៅ! ខ្ញុំនិយាយផុតពីមាត់មិនទាន់ផង ស្រាប់តែប្រពន្ធពូគី ជាចុងភៅដីកំណាចដើរសំដៅមក ដោយពោលពាក្យពុំគប្បីមកខ្ញុំ៖

-យើ! យប់ហើយឆ្កែញីឆ្កែឈ្មោលវាចាំដើងគ្នាហ្អ! ប្រយ័ត្នខ្លួននាងឯងចង់ងាប់តាមខ្មោចឪអាវងឬ? នាយគីប្រញាប់យាត់ប្រពន្ធគាត់ភ្លាម

-កុំនិយាយអុីចឹងម៉ែវា! ខ្ញុំគ្រាន់តែឃើញម៉ែអាវងប្រក់ផ្ទះម្នាក់ឯងខ្ញុំសរសើរទេតើ! មកទៅវិញ កុំខឹងអីណា! ម៉ែអាវង! នាយគីក៏ដឹកដៃប្រពន្ធគាត់ទៅក្នុងរោងបាយក្រុម ទី២វិញទៅ។

ខ្ញុំក៏ឈប់ប្រក់ ចុះមុជទឹកហើយចូលសម្រាកដោយមានអារម្មណ៍មួម៉ៅ និងខឹងចំពោះការ ប្រមាថរបស់ពួកមូលដ្ឋាននេះណាស់។ ថ្ងៃស្អែកឡើងថ្ងៃអាទិត្យ ប្រធានកងពុំបានឲ្យខ្ញុំអ្នក១៧ធ្វើការទេ។ ខ្មែរក្រហមបានហៅយើងទៅប្រជុំណែនាំយូរៗម្តងកុំឲ្យយើងភ្លេចខ្លួននៅនឹករបបចាស់ទៀត។

បញ្ចប់ការប្រជុំស្រាប់តែប្រធានភូមិបានសម្រេចឲ្យខ្ញុំរៀបចំគ្រួសារថ្មីជាមួយអ្នក១៧ដូចគ្នា គឺគាត់ឈ្មោះ ចាប ឆុន អតីតការីវិទ្យុជាតិជំនាន់ លន់ នល់ ខាងផ្នែកម៉ាស៊ីន ប៉ុន្តែខ្ញុំពុំព្រមព្រោះខ្ញុំស្រឡាញ់រាប់អានគាត់ដូចបងប្រុសបង្កើតខ្ញុំ។ ប្រធានភូមិក៏បានយោគយល់ពុំបង្ខំខ្ញុំ ព្រោះពូ ចាប ឆុន បានបែកប្រពន្ធនាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដោយពុំដឹងជារស់ឬស្លាប់និងគ្មានដំណឹង។ ប្រធានភូមិក៏ពន្យារការស្នើសុំនេះសិនទៅ។

**ជាតិ ប៉ុណ្ណារី**

**(តទៅលេខក្រោយ)**

រូបក្របមុខ៖
សេក សាយ បានផ្តល់បទសម្ភាសន៍ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ ពេលគាត់ទទួលបានរូបថត
ម្តាយ និងឪពុក ដែលត្រូវបានខ្មែរក្រហមចាប់ខ្លួនឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ និងសម្លាប់ចោល។
(សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
សេក សាយ កាន់រូបថតរបស់ឪពុកឈ្មោះ សេក ប្រាក់ អតីតលេខាតំបន់២៥ ហើយខាងស្តាំដៃគឺជាកូនស្រីរបស់គាត់។
(សុភ័ក្ត្រ ភាណា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




## មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥
DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 252, December 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.